## ព្រឹត្តិបត្រប្រចាំខែរបស់ចលនាព្រៃស្រោងពិភពលោក (WRM)

## ប្រធានបទ៖ ព្រឹត្តិបត្រប្រចាំខែកុម្ភៈនិងមីនា ឆ្នាំ២០១៧ ស្តីពី អាស៊ីអាគ្នេយ៍៖ ការភ្ជាប់ទំនាក់ទំនងប្រជាជនដែលប្រឆាំងនឹងការវិនិយោគខ្នាតធំ និងគំនិតផ្តួចផ្តើមស្តីពីការអភិវឌ្ឍ

លេខ ២២៩ - ខែកុម្ភៈ/មីនា ឆ្នាំ២០១៧ - សូមមើលឯកសារនេះលើបណ្តាញអ៊ីនធើណេត

[ចែករំលែក ទ្វីត (TWEET) និងបញ្ជូនបន្ត]

ចុះឈ្មោះដើម្បីទទួលបាននូវព្រឹត្តិបត្ររបស់ WRM
http://wrm.us9.list-manage1.com/subscribe?u=f91b651f7fecdf835b57dc11d&id=ca171adcc2

---

# ទស្សនៈរបស់យើង

១

## អាស៊ីអាគ្នេយ៍៖ ការពង្រឹងចលនាតស៊ូឲ្យហួសពីព្រំដែនកំណត់

*ព្រឹត្តិបត្រថ្នាក់តំបន់ទីបី របស់ចលនាព្រៃស្រោងពិភពលោក (World Rainforest Movement) សម្រាប់អំឡុងពេល១០ខែកន្លងទៅនេះ ផ្តោតលើតំបន់អាស៊ីអាគ្នេយ៍។ វាមានដាក់បញ្ចូលនូវអត្ថបទអំពីប្រទេសឥណ្ឌូណេស៊ី ប៉ាក់ស៊ីស្ថាន ថៃ មីយ៉ាន់ម៉ា ឥណ្ឌូនេស៊ី និងកម្ពុជា ព្រមទាំងមានអត្ថបទមួយស្តីពីទិដ្ឋភាពទូទៅរបស់តំបន់។ ព្រឹត្តិបត្រនេះក៏នឹងមានប្រែសម្រួលជាភាសាមួយចំនួនដែលរៀបរាប់នៅក្នុងតំបន់នោះដែរ។*

# អាស៊ីអាគ្នេយ៍៖ ការភ្ជាប់ទំនាក់ទំនងប្រជាជនដែលប្រឆាំងនឹងការវិនិយោគខ្នាតធំ និងគំនិតផ្តួចផ្តើមពីការអភិវឌ្ឍ

២

## ការវិនិយោគខ្នាតធំ និងគំនិតផ្តួចផ្តើមស្តីពីការអភិវឌ្ឍអាកាសធាតុបំផ្លាញព្រៃឈើនិងដែនដីរបស់មនុស្សជាតិ

*ប្រជាជនមូលដ្ឋានកម្រទទួលបានផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ច និងឧស្សាហូបនីយកម្ម ដែលរីកលូតលាស់នៅអាស៊ី បានកំពុងជំរុញតាមរយៈគំរូនៃ «ការអភិវឌ្ឍ» កំណត់ដោយការវិនិយោគខ្នាតធំ។ ផ្ទុយទៅវិញ ពួកគេបែរជាប្រឈមនឹងការកើនឡើងនៃការគ្រប់គ្រង និងការកេងប្រវ័ញ្ចដោយក្រុមហ៊ុន*

*សាជីវកម្មទៅលើដីធ្លី ព្រៃឈើ ទឹក ធម្មជាតិ រ៉ែ និងកម្លាំងពលកម្ម។ វាក៏ជារឿងអស្ចារ្យនៅទូទាំងតំបន់អាស៊ីដែលប្រជាជនមូលដ្ឋានកំពុងតស៊ូជំនះនឹងអំពើហិង្សាដែលចេះតែកើនឡើងៗ ទៅនឹងចំនុចសំខាន់នៃគំរូអភិវឌ្ឍបែបនេះ។*

៣

## ជម្លោះព្រៃឈើនៅក្នុងប្រទេសថៃ៖ រដ្ឋ តទល់នឹង រាស្ត្រ

*នៅក្នុងប្រទេសថៃ យ៉ាងហោច ៣៨ភាគរយនៃផ្ទៃដីដែលកាន់កាប់ដោយឯកជនត្រូវទុកទំនេរចោល ខណៈដែលមានគ្រួសារកសិករជាង៨០ម៉ឺនគ្រួសារ ពុំមានដីធ្លីជាកម្មសិទ្ធិផ្ទាល់ខ្លួនទាល់តែសោះ។ ច្បាប់ស្តីពីការស្តារព្រៃឈើឆ្នាំ១៩៩៣ បានអនុញ្ញាតឲ្យមានការយកដីរដ្ឋ ដែលធ្លាប់ប្រើប្រាស់ដោយសហគមន៍ទៅបម្រើការដាំដុះដំណាំឧស្សាហកម្មទៅវិញ។ ថ្មីៗនេះ រដ្ឋបានចាប់ផ្តើមលើកឡើងថា ការប្រើប្រាស់ដីធ្លីដោយអ្នកភូមិបានបង្កឲ្យមានការកើនកម្តៅផែនដី ហើយបានចាប់ផ្តើមបណ្តេញកសិករចេញពីដីដែលពួកគេអាស្រ័យផល។*

៤

## ប្រទេសមីយ៉ាន់ម៉ា៖ គោលនយោបាយថ្មីដែលលើកកម្ពស់សិទ្ធិជនជាតិដើមភាគតិច ស្ថិតក្រោមការគំរាមកំហែង

*យោងតាមដំណើរការពិគ្រោះយោបល់និងការពិនិត្យឡើងវិញដែលពុំធ្លាប់មានពីមុនមក កាលពីខែមករា ឆ្នាំ២០១៦កន្លងទៅនេះ រដ្ឋាភិបាលមីយ៉ាន់ម៉ាបានដាក់ចេញនូវគោលនយោបាយជាតិថ្មីមួយស្តីពីការប្រើប្រាស់ដីធ្លី។ គោលនយោបាយនេះគឺចង្អុលបង្ហាញពីការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់មួយ ឆ្ពោះទៅកាន់អភិបាលកិច្ចដីធ្លី ដែលគោរពសិទ្ធិរបស់សហគមន៍ដាច់ស្រយាល និងសហគមន៍ជនជាតិដើម ដែលបានធ្វើការប្តឹងផ្តល់ជាយូរណាស់មកហើយ លើបញ្ហាដណ្តើមដីធ្លីដែលគាំទ្រដោយរដ្ឋ។ ទោះជាយ៉ាងណាក្តី នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៦ គណៈកម្មការពិសេសមួយដែលពុំសូវមានគេស្គាល់តែមានឥទ្ធិពលខ្លាំងនៅក្នុងសភាជាតិបានស្នើឲ្យលុបចោលនូវចំណុចគន្លឹះរបស់គោលនយោបាយនេះ។ ប្រសិនបើសំណើត្រូវបានទទួលយក ការកែសម្រួលទាំងនោះនឹងធ្វើឲ្យគោលនយោបាយនេះមានលក្ខណៈប្រហោងក្នុង។*

៥

## ព្រៃឈើនៅក្នុងភូមិភាគឥសាននៃប្រទេសឥណ្ឌា

*ភាគច្រើននៃរដ្ឋដែលបញ្ចូលគ្នាបង្កើតបានជា «ភូមិភាគឥសាននៃប្រទេសឥណ្ឌា» នោះនៅតែរក្សាបាននូវតំបន់ព្រៃធំៗ ដែលព្រៃភាគច្រើនស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគមន៍។ ទោះជាយ៉ាងណាក្តីសម្ពាធពីខាងក្នុងនិងខាងក្រៅកំពុងកើនឡើងយ៉ាងខ្លាំង ដូចគ្នានិងការបាត់បង់ព្រៃឈើដែរ។ រដ្ឋាភិបាល ឥណ្ឌាចង់ពង្រីកការរុករករ៉ែ ហើយក៏កំពុងតែរៀបចំផែនការទំនប់វារីអគ្គីសនី ជាង១៥០កន្លែង និង ហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ដែលផ្សារភ្ជាប់តំបន់ដីគោកឥណ្ឌា ទៅនឹងតំបន់អាស៊ាន។ អ្នកភូមិបានទទួលរ៉ាប់រងនៃផលប៉ះពាល់ពីភាពបរាជ័យរបស់គម្រោងរេដ បូក (REDD+) និងចម្ការចំណាំល្ហុងខ្វង ដែលត្រូវបានជំរុញក្រោមនាមដើម្បីរក្សាធាតុអាកាស។*

៦

## ប្រទេសឥណ្ឌូនេស៊ី៖ ច្បាប់ដែលស្ទើរឡើងបានគំរាមកំហែង ហើយធ្វើឲ្យមានការគ្រប់គ្រងឡើងវិញដោយក្រុមហ៊ុនសាជីវកម្ម លើកសិជីវចម្រុះ

*នៅឆ្នាំ២០១២ តុលាការធម្មនុញ្ញនៅក្នុងប្រទេសឥណ្ឌូនេស៊ីបានប្រកាសទុកមាត្រាសំខាន់ៗនៃច្បាប់ឆ្នាំ១៩៩២មួយជាមោឃៈ ដែលបានហាមឃាត់កសិករមិនឲ្យបង្កាត់ពូជរុក្ខជាតិ ច្បាប់ពីរដែលបានស្ទើរឡើងបច្ចុប្បន្នកំពុងតែគំរាមកំហែងផ្ទុយពីរដ្ឋធម្មនុញ្ញ ដោយផ្តល់ឲ្យក្រុមហ៊ុនសាជីវកម្មគ្រប់គ្រងឡើងវិញលើកសិជីវៈចម្រុះ។ បើអនុម័តរួមគ្នា ច្បាប់ទាំងនេះនឹងដាក់ចំណេះដឹងបែបប្រពៃណីឲ្យទៅជាសម្បត្តិរបស់ក្រុមហ៊ុនសាជីវកម្ម។*

៧

## ការប្រឆាំងនឹងបណ្តាសានៃការសម្បទាននៅក្នុងប្រទេសកម្ពុជា

*ក្រោយពីការតស៊ូអស់រយៈពេល១៦ឆ្នាំ ការប្តេជ្ញាចិត្តរបស់សហគមន៍តស៊ូទាមទារដើម្បីបានការគ្រប់គ្រងមកវិញលើដីដែលពួកគេបានបាត់បង់ទៅក្នុងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនភាពីម៉ិច នៅក្នុងខេត្តកំពង់ឆ្នាំងនៃប្រទេសកម្ពុជាបានទទួលនូវលទ្ធផលជាផ្លែផ្កាហើយ។ ភាភីម៉ិចបានយល់ព្រមប្រគល់ដីចំនួន១៧ម៉ឺន ហិចតាមកសហគមន៍វិញ។ ជោគជ័យរបស់ពួកគេបានបង្ហាញថាការតស៊ូរបស់សហគមន៍ គឺដូចជាគុម្ពឫស្សី៖ វាផ្តើមលូតចេញមកមួយដើម ហើយយូរទៅវាកាន់តែលូតច្រើន និងកាន់តែរឹងមាំខ្លាំងឡើងៗ។*

៨

## ប្រទេសម៉ាឡេស៊ី៖ ក្រុមជនជាតិដើមភាគតិចមកពីជុំវិញពិភពលោក ចេញសេចក្តីប្រកាសប្រឆាំងនឹងទំនប់

*ក្នុងខែធ្នូ ឆ្នាំ២០១៥ ជនជាតិដើមនៅសារ៉ាវ៉ាក់នៃប្រទេសម៉ាឡេស៊ី បានអបអរសាទរនូវជ័យជំនះដ៏ធំមួយ៖ រដ្ឋាភិបាលប្រចាំរដ្ឋបានប្រកាសឲ្យផ្អាកជាផ្លូវការ បន្ទាប់មកនៅឆ្នាំ២០១៦ បានលុបចោលគម្រោងទំនប់បារ៉ាំដ៏ចម្រូងចម្រាស់នោះ។ ការតស៊ូប្រឆាំងនឹងគម្រោងទំនប់នេះបានក្លាយជាកម្លាំងជំរុញទឹកចិត្តមួយសម្រាប់មនុស្សជាច្រើន ហើយត្រូវបានរំលេចឡើងជាពិសេសក្នុងបទបង្ហាញអំពី «តើមានអ្វីខ្លះដែលកំពុងតែកើតឡើងចំពោះព្រៃឈើរបស់យើងនៅក្នុងប្រទេសម៉ាឡេស៊ី?» នៅឯការជួបជុំមួយនៅទីក្រុងបាងកកកាលពីខែវិច្ឆិកា ឆ្នាំ២០១៦ ដែលមាននៅក្នុងផ្នែកពិចារណកថា* (សម្រង់វិភាគ) *នៃព្រឹត្តិបត្រនេះ។*

## សកម្មភាពប្រជាជន

ប្រទេសហុងឌូរ៉ាស៖ ជាប្រទេសដែលមានអ្នកស្លាប់ច្រើនជាងគេបំផុតលើពិភពលោក ចំពោះភាពសកម្មនិយមបរិស្ថាន។

តំបន់ហ្រ្វេនហ្គុយ៉ាណា៖ រដ្ឋាភិបាលបារាំងកំពុងតែលើកកម្ពស់ឧស្សាហូបនីយកម្ម រុករករ៉ែមាស នៅតំបន់ហ្រ្វេនហ្គុយ៉ាណាដោយស្ងាត់ៗ។

ប្រទេសឥណ្ឌា៖ ការស្រាវជ្រាវស៊ើបអង្កេតរបស់ប៊ីប៊ីស៊ី (BBC) បានបង្ហាញពីចំនួនអ្នកស្លាប់ដោយសារគោលនយោបាយបាញ់សម្លាប់នៅក្នុងតំបន់អភិរក្សសត្វខ្លា។

ប្រទេសម៉ាឡេស៊ី៖ អង្គការស្បៀងអាហារនិងកសិកម្ម (FAO) ត្រូវបានប្រាប់ឲ្យបញ្ឈប់នូវការទទួលស្គាល់ថាចំការដំណាំឧស្សាហកម្មគឺជាព្រៃឈើ។

ប្រទេសឥណ្ឌូនេស៊ី៖ បាតុកម្មនៅចាវ៉ាប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើដោយការពង្រីកឧស្សាហកម្មស៊ីម៉ង់ត៍។

# អនុសាសន៍

របាយការណ៍ប្រជុំ៖ តើមានអ្វីខ្លះដែលកំពុងតែកើតឡើងចំពោះព្រៃឈើរបស់យើង?

វីដេអូរបស់*សង្គ្រោះទន្លេរបស់យើង សង្គ្រោះជីវិតពួកយើង ស្តីពីការគំរាមកំហែងនៃការរុករករ៉ែមាសនៅទន្លេតានីនថារី (*Tanintharyi River*) នៅប្រទេសមីយ៉ាន់ម៉ា។*

របាយការណ៍៖ មូលហេតុ និងរបៀបនៃការធ្វើកសិកម្មបែបអេកូឡូស៊ី?!

របាយការណ៍៖ **មហន្តរាយដែលកំពុងកើនឡើង**៖ក្រុមហ៊ុនសាជីវកម្ម៥០០វិនិយោគលើកសិកម្ម (the Fortune 500 goes farming)

កិច្ចសម្ភាស៖ «គ្មានទេនិរន្តរភាពប្រេងដូងដែលចេញពីឧស្សាហកម្មផលិតកម្មដូងប្រេង»។

របាយការណ៍៖ ការចុះកិច្ចព្រមព្រៀងប្រគល់**អធិបតេយ្យភាព**៖ របៀបដែលកិច្ចព្រមព្រៀងវិនិយោគគំរាមកំហែងដល់បទបញ្ញត្តិលើឧស្សាហកម្មរ៉ែនៅក្នុងប្រទេសហ្វីលីពីន។

---

# ទស្សនៈរបស់យើង

## អាស៊ីអាគ្នេយ៍៖ ការពង្រឹងចលនាតស៊ូឲ្យហួសពីដែនកំណត់

នេះគឺជាព្រឹត្តិបត្រថ្នាក់តំបន់ទីបីរបស់ចលនាព្រៃស្រោងពិភពលោក (the World Rainforest Movement) សម្រាប់រយៈពេល១០ខែកន្លងទៅនេះ។ ការចេញផ្សាយលើកទីមួយ (ព្រឹត្តិបត្ររបស់ចលនាព្រៃស្រោងពិភពលោក ២២៤) (WRM Bulletin 224) មើលទៅលើកត្តានានា ដែលនាំឲ្យមានការដណ្តើមដីធ្លីនៅក្នុងតំបន់អាងទឹកកុងហ្គោនៅអាហ្វ្រិច។ ការចេញផ្សាយលើកទីពីរ (លេខ ២២៦) គឺផ្តោតលើរបៀបដែលប្រជាជនប្រឆាំងទប់ទល់ជាមួយនឹងអតីតអាណានិគម ដែលបន្តដាក់គំនាបនិងហិង្សានៅទូទាំងអាមេរិកកណ្តាល។ ចំណែកឯនៅក្នុងការចេញផ្សាយលើកនេះវិញ គឺផ្តោតទៅលើតំបន់អាស៊ីអាគ្នេយ៍។

តាមរយៈព្រឹត្តិបត្រថ្នាក់តំបន់ទាំងនេះ ចលនាព្រៃស្រោងពិភពលោក (WRM) ចង់ទាញចំណាប់អារម្មណ៍មកលើចលនាតស៊ូនានានៅក្នុងតំបន់ ជាពិសេសតំបន់ដែលរងផលប៉ះពាល់ពីការកាប់បំផ្លាញព្រៃឈើ។ គោលបំណងរបស់ព្រឹត្តិបត្រនេះ មិនត្រឹមតែផ្ដល់ការមើលឃើញជាក់ស្ដែងចំពោះស្ថានភាពនិងការតស៊ូរបស់សហគមន៍ប៉ុណ្ណោះទេ វាថែមទាំងគាំទ្រដល់ដំណើរការដែលប្រឈមខ្ពស់ក្នុងការកសាងបណ្ដាញនិងចលនានានា ក្នុងចំណោមអង្គការសហគមន៍ ក្រុមសកម្មជន និងចលនាសង្គមនៅក្នុងប្រទេសមួយចំនួនក្នុងតំបន់មួយ និងតំបន់ផ្សេងៗទៀត។

ការបង្កើតឲ្យមានព្រឹត្តិបត្រថ្នាក់តំបន់នេះ គឺជាលំហាត់រៀនសូត្រដ៏ល្អមួយ។ ជាឧទាហរណ៍ យើងបានកត់សម្គាល់ឃើញថា បន្ទាត់ព្រំដែនដែលកំណត់ព្រំប្រទល់ប្រទេសនានា ដែលប្រទេសទាំងនោះរួមគ្នាកំណត់បានជាតំបន់ដូចលើកឡើងខាងលើ តែងកាត់ផ្ដាច់ការតស៊ូរបស់សហគមន៍លើការការពារជីវភាពរស់នៅនិងព្រៃឈើរបស់ពួកគេចេញពីគ្នា។ អាស៊ីអាគ្នេយ៍ជាតំបន់ក៏មិនខុសពីការរៀបរាប់ខាងលើដែរ។ ដែនដីបច្ចុប្បន្នដែលបានកំណត់ចេញជាប្រទេសផ្សេងៗ ដូចជាប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ទីម័រខាងកើត ឡាវ ម៉ាឡេស៊ី ប្រ៊ុយណេ ភូមា (មីយ៉ាន់ ម៉ា) ហ្វីលីពីន សឹង្ហបូរី ថៃ និងវៀតណាម ត្រូវបានដាក់រួមបញ្ចូលគ្នាក្រោមឈ្មោះថា «អាស៊ីអាគ្នេយ៍» ប៉ុន្តែប្រទេសប៉ាព័រញូហ្គីនា ខេត្តយូណាននៃប្រទេសចិន ឬរដ្ឋនៅតំបន់ម៉ានីពួររបស់ឥណ្ឌាពុំត្រូវបានមើលឃើញថាជាផ្នែកមួយនៃតំបន់នេះទេ។ ការមិនដាក់បញ្ចូលទីតាំងទាំងនេះបានបង្ហាញថាឈ្មោះ «អាស៊ីអាគ្នេយ៍» មានលក្ខណៈនយោបាយច្រើនជាងការយោងតែលើកត្តាភូមិសាស្ត្រមួយមុខ។ ការយល់ឃើញក្នុងពេលបច្ចុប្បន្នចំពោះឈ្មោះនេះ គឺត្រូវវិលទៅមើលប្រវត្តិពីមុននៅពេលដែលស្ថិតនៅក្រោមអាណានិគមអឺរ៉ុបពួកគេបានចាប់ផ្ដើមបែងចែកទឹកដីតំបន់នោះក្នុងចំណោមក្រុមពួកគេ។ ការដាក់អាណានិគមនេះបានបន្តរហូតមកដល់សព្វថ្ងៃនេះ ខណៈដែលវាត្រូវបានរៀបចំឡើងនៅក្រោមរូបភាពជាគម្រោងផ្សេងៗគ្នា និងមានការចូលរួមពាក់ព័ន្ធពីតួអង្គដែលជាស្ថាប័ននានា។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៦ សហការីនិងមិត្តភក្ដិមកពីបណ្ដាប្រទេសភាគច្រើននៅក្នុងតំបន់ នេះបានមកជួបជុំគ្នានៅទីក្រុងបាងកកប្រទេសថៃ/សៀម ដើម្បីចែករំលែកនូវរឿងរ៉ាវនិងអារម្មណ៍ពីវិបត្តិដែលកើតមានឡើងនៅក្នុងបរិបទមូលដ្ឋានផ្សេងៗគ្នា។ ការជួបជុំនេះផ្ដោតសំខាន់ជុំវិញកង្វល់រួមគ្នាមួយគឺ៖ «តើមានអ្វីខ្លះដែលកំពុងតែកើតមានឡើងចំពោះព្រៃឈើរបស់យើង?» ដោយធ្វើការប្រៀបធៀប ការពិភាក្សា និងការដាក់បញ្ចូលនូវភាពស្រដៀងគ្នាទៅតាមការចងចាំ ដែលអ្នកចូលរួមម្នាក់ៗបាននាំយកមកក្នុងពិធីជួបជុំនេះ សំណួរដែលបានលើកឡើងនេះបានលាតត្រដាងពីសាច់រឿងនៃតំបន់អាស៊ីអាគ្នេយ៍ ដែលជាតំបន់មួយ «អស់ព្រៃ»។ ការយល់ឃើញនេះគឺផ្ទុយស្រឡះទាំងស្រុងពីរូបភាពជាតំបន់ដែលមាន «ការលូតលាស់ និងការអភិវឌ្ឍ» ដែលនេះហាក់ដូចជាត្រូវបានបង្ហាញទាំងមិនពិត ដោយក្រុមអ្នកធ្វើនយោបាយជាន់ខ្ពស់ និងក្រុមអ្នកធ្វើគោលនយោបាយនៅក្នុងស្ថាប័នអន្តរជាតិ។

សេចក្ដីសំយោគនេះគឺរៀបរាប់ពីវិបត្តិនៃអ្នកចូលរួម ហើយបានកំណត់ចេញនូវចំនុចរួមគ្នាមួយចំនួន និងចំនុចពិសេសដោយឡែកពីគ្នានៅក្នុងចំណោមស្ថានភាពរបស់សហគមន៍នៅក្នុងប្រទេសផ្សេងៗពីគ្នា។ ចំនុចរួមមួយក្នុងចំណោមចំនុចរួមទាំងនោះ គឺបទពិសោធមួយដែលគេតែងនិយមហៅថា ក្របខណ្ឌការងារ

«អភិវឌ្ឍន៍បៃតង» ។ ក្របខណ្ឌនេះផ្តោតលើទ្រឹស្តីចាស់ស្តីពីកំណើនសេដ្ឋកិច្ចដែលបានពីការស្រូបយកធនធានធម្មជាតិ ហើយបច្ចុប្បន្ននេះត្រូវបានដាក់ស្លាកថា «បៃតង»។ ពាក្យបៃតងត្រូវបានប្រើដើម្បីបិទបាំងពីដំណើរការបំផ្លិចបំផ្លាញ ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងចាស់ និងអ្នកថ្មី ដែលមិនមែនជាអ្នកនៅតាមមូលដ្ឋាននោះទេ។ ស្របពេលដែលការជជែកពី «ការអភិវឌ្ឍបៃតង» កាន់តែពេញនិយម រដ្ឋាភិបាលនៅក្នុងតំបន់ ក៏កំពុងតែបង្កើនភាពពឹងផ្អែកខ្លាំងឡើងៗ លើការស្រូបទាញយកធនធានធម្មជាតិមកបម្រើដល់ការបន្តជីវិតនយោបាយរបស់ពួកគេ។ ផ្ទុយទៅវិញ ប្រជាជនក្នុងស្រុកបន្តរងនូវការស្តីបន្ទោសដោយមិនត្រឹមត្រូវទៅលើការបំផ្លិចបំផ្លាញបរិស្ថាន និងការអាស្រ័យផលលើដីព្រៃសម្រាប់តម្រូវការចាំបាច់របស់កូនចៅជំនាន់ក្រោយពួកគេ ក្លាយជាមូលហេតុនៃភាពក្រីក្រទៅវិញ។ រីឯការប្រើអំពើហិង្សា និងការជិះជាន់គាបសង្កត់មកលើពួកគេក៏កំពុងតែកើនឡើងដែរ។ ទន្ទឹមគ្នានោះដែរ សហគមន៍ក៏កំពុងតែប្រឆាំង និងតស៊ូមតិកាន់តែច្រើនឡើងៗដោយចេញមុខ និងប្រើយុទ្ធសាស្ត្រស្តីបន្ទោសតបទៅវិញ។

ចំណាប់អារម្មណ៍ដ៏ខ្លាំងបំផុតពីការជួបជុំនៅទីក្រុងបាងកក គឺថាស្ថានភាពព្រៃឈើស្ថិតក្នុងសភាពនៃ «ការវិវឌ្ឍ» បែបបំផ្លិចបំផ្លាញ និងវិនាស បានបង្ហាញពីរឿងរ៉ាវដែលបានចងភ្ជាប់គ្នាជាថ្មី ពីអនុតំបន់ដែនដីគោករួមមានតំបន់ឥណ្ឌាភាគឥសាន និងតំបន់ទន្លេមេគង្គ ទៅនឹងអនុតំបន់នៅដែនកោះរបស់ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងហ្វីលីពីន។ ស្ថាប័នរដ្ឋនិងឯកជនដែលទទួលខុសត្រូវលើការបំផ្លិចបំផ្លាញក្នុងនាម «ការអភិវឌ្ឍ» ក្នុងតំបន់បានប្រឌិតជាសាច់រឿងថ្មីៗបន្តបន្ទាប់ដើម្បីបង្ហាញការបំផ្លិចបំផ្លាញនេះជា «ការរីកចំរើន» ហើយលាបពណ៌ថារចនាសម្ព័ន្ធសង្គម និងការអនុវត្តកសិកម្មបែបក្បែរក្របរិស្ថានដ៏ឈ្លាសវៃ នៅក្នុងសហគមន៍ដែលពឹងផ្អែកលើព្រៃឈើមានលក្ខណៈថយក្រោយ មិនទាន់សម័យ និងមិនមានផលិតភាព។ ទោះយ៉ាងណាការពិតគឺមិនត្រូវច្រលំតាមការបំភាន់នេះទេ។

ជាលទ្ធផលពីសម្ពាធឥតឈប់ឈរនេះ គឺបានធ្វើឲ្យភាពរួមគ្នារវាងបរិស្ថានសង្គមនៅក្នុងចំណោមសហគមន៍ចាប់ផ្តើមញែកចេញពីគ្នា ខណៈដែលការរួមសាមគ្គីគ្នារបស់ប្រជាជន ក្នុងទម្រង់ ស្ថាប័ន និងយន្តការផ្សេងៗគ្នា បានក្លាយទៅជាកម្លាំងដ៏ខ្លាំងសម្រាប់បំបែកការគ្រប់គ្រង។ ជាចុងក្រោយ ការសម្លាប់និងការឆក់ប្លន់ត្រូវបានបិទបាំងដោយពាក្យថ្មី។ ឧទាហរណ៍ជាក់ស្តែងមួយចំនួនមានដូចជា នៅប្រទេសហ្វីលីពីន ការសម្លាប់ហួសពីដែនកំណត់របស់តុលាការ បានស្ថិតក្រោម «បទបញ្ជានិងការបង្ក្រាបតាមច្បាប់» (១) រីឯនៅប្រទេសកម្ពុជាវិញ ការស៊ើបអង្កេតជាផ្លូវការយឺតយ៉ាវដោយសមត្ថកិច្ចលើករណីបាញ់សម្លាប់យ៉ាងសាហាវមួយ ត្រូវបានដាក់ការស្តីបន្ទោសលើគ្រួសារជនរងគ្រោះថាបានរាយការណ៍យឺតទៅប៉ូលីសទៅវិញ (២) ចំណែកឯនៅប្រទេសឥណ្ឌូនេស៊ី ការផ្តល់ទឹកប្រាក់គាំទ្រសម្រួលដល់ការពង្រីកចម្ការដំណាំដូងប្រេង បានប្រើពាក្យគន្លឹះៗដូចជា «ធានាសិទ្ធិដីធ្លីរបស់សហគមន៍មូលដ្ឋាន ដោយការចូលរួមជាមួយនឹងវិស័យចម្ការដំណាំឧស្សាហកម្ម» ឬ «គាំទ្រកិច្ចប្រឹងប្រែងការពារតម្លៃដែលបានពីការអភិរក្ស ឬព្រៃស្តុកកាបូនមានកម្រិតខ្ពស់ នៅក្នុងតំបន់សម្បទានចម្ការដំណាំដូងប្រេង»។ (៣) ដើម្បីរក្សាឲ្យមានភាពស្ងៀមស្ងាត់និងបិទបាំងពីបញ្ហាការកាប់បំផ្លាញព្រៃឈើដែលបង្កឲ្យមានការឈឺចាប់ ក៏ដូចជាការប្រឆាំងតបតរបស់សហគមន៍នៅទូទាំងអាស៊ីអាគ្នេយ៍ មានវិធីសាស្ត្រមួយ គឺអ្នកទទួលខុសត្រូវក្នុងការកាប់បំផ្លាញព្រៃឈើនោះបានកែប្រែស្ថានភាពខូចខាតនេះទៅជាផែនការ «ការអភិវឌ្ឍ» ទៅវិញ។ ជាឧទាហរណ៍ ផែនការសកម្មភាពស្តីពីព្រៃឈើតំបន់ត្រូពិចឆ្នាំ១៩៨៦ (TFAP) របស់

ធនាគារពិភពលោក បានកែពាក្យការបំផ្លិចបំផ្លាញទៅជា «ការអភិវឌ្ឍឧស្សាហកម្មផ្អែកលើព្រៃឈើ» ដោយបន្ថែមការពង្រីកតំបន់អភិរក្ស ដែលជាមធ្យោបាយមួយដើម្បីបន្តការកាប់បំផ្លាញព្រៃឈើ។ បីទសវត្សក្រោយមក ការជួបជុំនៅបាងកកបានមើលឃើញថា ទោះបីជាផែនការសកម្មភាពស្តីពីព្រៃឈើតំបន់ត្រូពិច (TFAP) ត្រូវបានពន្យារពេលមិនអនុវត្តយូរណាស់មកហើយក្តី អ្វីដែលចម្លែកគឺការប្របាច់បញ្ចូលគ្នារវាងពាក្យការការពារព្រៃឈើ និងការកាប់បំផ្លាញព្រៃឈើដែលពួកគេបានណែនាំក្នុងពេលបច្ចុប្បន្ននេះ ដោយប្រើឈ្មោះថ្មីៗដូចជា គោលនយោបាយ កម្មវិធី ឬក៏ក្របខណ្ឌការងារសម្រាប់ «ការអភិវឌ្ឍបៃតង» ជា «គោលនយោបាយ ឈ្នះ ឈ្នះ» ដើម្បី «បរិស្ថាននិងការអភិវឌ្ឍ» ឬក៏ដើម្បី «ការអភិរក្ស និងការកាត់បន្ថយភាពក្រីក្រ» ជាឥណទានកាបូន ឬ «ការទូទាត់សងលើឧស្ម័ន» ដោយទទួលស្គាល់សិទ្ធិ «ច្រករបៀងជីវៈចម្រុះ» ឬ «ការទូទាត់នឹងជីវៈចម្រុះ» (“biodiversity offsetting”) ដើម្បី «ធ្វើការរុករករ៉ែដោយផ្តល់ផលវិជ្ជមានដល់ជីវៈចម្រុះ»។ ដោយមិនផ្តោតលើឈ្មោះថ្មីៗទាំងនេះ ផលប៉ះពាល់នៅតែមានចំពោះសហគមន៍អាស្រ័យលើព្រៃឈើ ដែលស្ថិតនៅក្រោមកម្មវិធីដូចជាផែនការសកម្មភាពស្តីពីព្រៃឈើតំបន់ត្រូពិច (TFAP)៖ ពោលគឺការរឹតត្បិតលើការប្រើ ប្រាស់ដីតាមបែបប្រពៃណី ឬការបាត់បង់ដីក្នុងការដណ្តើមដីធ្លីទស្សនៈបៃតងបែបថ្មី។

ខណៈដែលការបំផ្លាញព្រៃឈើចេះតែបន្តទៅមុខគ្មានដែនកំណត់ បេះដូងនៃកិច្ចប្រជុំនៅក្រុងបាងកកបានបង្ហាញថា ចលនាតស៊ូប្រឆាំង និងការព្យាបាលរម្ងាប់ចិត្តមានឥទ្ធិពលក្នុងការបង្រួបបង្រួមសហគមន៍ និងប្រជាជនឲ្យរួមគ្នាបានលើសពីព្រំដែនកំណត់ដែលមានទៅ ទៀតនៅក្នុងអាស៊ីអាគ្នេយ៍និងនៅជុំវិញសកលលោក។ ព្រឹត្តិបត្រលេខនេះគឺជាវិធីមួយផ្សេងទៀតសម្រាប់គាំទ្រ និងធ្វើការផ្សាយសារទាំងនេះចេញ។ ដើម្បីគាំទ្រដល់ដំណើរការនេះ ព្រឹត្តិបត្រនេះដែលមានអត្ថបទផ្សេងៗមក ពីប្រទេសឥណ្ឌាប៉ែកឥសាន ប្រទេសថៃ ប្រទេសមីយ៉ាន់ម៉ា ប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី និង ប្រទេសកម្ពុជា ព្រមទាំងអត្ថបទអំពីទិដ្ឋភាពទូទៅក្នុងតំបន់ នឹងត្រូវបកប្រែជាភាសាមួយចំនួនដែលប្រើប្រាស់នៅ ក្នុងតំបន់នេះ។

យើងសង្ឃឹមថាអ្នកនឹងរីករាយក្នុងអានព្រឹត្តិបត្រនេះ!

(១) ឌុធើរតេ (Duterte) នៃប្រទេសហ្វីលីពីនបានបង្ហាញពីវិធីស្រដៀងគ្នានឹងអ៊ីត្លែរ (Hitler) នៅក្នុងសង្គ្រាមប្រឆាំងគ្រឿងញៀន។ អា អ៊ែហ្វ ប៉េ (AFP) ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៦ និង
https://www.youtube.com/watch?v=Mu5W5CJAPH4
(២) ប៉ូលីសបានស្តីបន្ទោសលើគ្រួសារចំពោះការបញ្ឈប់ការស៊ើបអង្កេតលើករណីក្មេងប្រុសដែលបាត់ខ្លួន។ ដឹខែមបូឌាដេលី (The Cambodia Daily) ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥។
https://www.cambodiadaily.com/news/police-blame-family-for-stalled-probe-into-lost-boy-93151/
(៣) សម្ព័ន្ធផ្តួចផ្តើមនៅឥណ្ឌូនេស៊ីស្តីពីអាកាសធាតុនិងការប្រើប្រាស់ដីធ្លី។ បញ្ជីទំនាក់ទំនាក់ និងជំនួយ។
http://www.climateandlandusealliance.org/wp-content/uploads/2017/01/Indonesia-Grants-List_2017-Q1.pdf

# អាស៊ីអាគ្នេយ៍៖
# ការភ្ជាប់ទំនាក់ទំនងប្រជាជនដែលប្រឆាំងនឹងការវិនិយោគខ្នាត ធំ និងគំនិតផ្តួចផ្តើមស្តីពីការអភិវឌ្ឍ

## ការវិនិយោគខ្នាតធំ និងគំនិតផ្តួចផ្តើមស្តីពីការអភិវឌ្ឍអាកាសធាតុ បំផ្លាញព្រៃឈើ និងដែនដីរបស់ប្រជាជន

ឧស្សាហូបនីយកម្ម និងកំណើនសេដ្ឋកិច្ចដ៏លឿនរបស់អាស៊ី កំពុងផ្តល់នូវគុណវិបត្តិជាច្រើនអនេក ចំពោះសហគមន៍មូលដ្ឋាន បរិស្ថាន និងសេដ្ឋកិច្ចរបស់ពួកគេ។ នៅទូទាំងតំបន់ «ការអភិវឌ្ឍ» ត្រូវបានកំណត់ ដោយការវិនិយោគខ្នាតធំ ដែលផ្តោតជាចំបងលើការគ្រប់គ្រង និងកេងប្រវ័ញ្ចលើដីធ្លី ព្រៃឈើ ទឹក ធម្មជាតិ រ៉ែ និងកម្លាំងពលកម្ម។ រដ្ឋាភិបាលរបស់អាស៊ាន កំពុងស្វែងរកវិនិយោគទុនឯកជនសម្រាប់ស្ទើរតែគ្រប់វិស័យ ទាំងអស់នៃសេដ្ឋកិច្ចរាប់តាំងពីវិស័យថាមពល ប្រេង រ៉ែ កសិកម្ម និងការកែច្នៃចំណីអាហារ រហូតដល់វិស័យអប់រំ សុខាភិបាល ទេសចរណ៍ កម្មន្តសាល ឱសថ ការដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង។ រីឯប្រភព នៃការវិនិយោគវិញមានផ្សេងៗគ្នា ដែលជាទូទៅអាចប្រព្រឹត្តទៅបានតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងជំនួយថ្នាក់តំបន់ ព្រមទាំងកិច្ចព្រមព្រៀងសេដ្ឋកិច្ច ហើយជាញឹកញាប់ត្រូវបានទំនុកបម្រុងដោយលំហូរ មូលធនសកល និងពិបាកដឹងពីប្រភព។ (១)

ដី ព្រៃឈើ និងទឹក ត្រូវបានរក្សាទុកសម្រាប់គោលបំណងមួយចំនួនដូចជា កសិឧស្សាហកម្ម ចម្ការឈើដាំ វារីអគ្គិសនី ឧស្សាហកម្មរុករករ៉ែ ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍអចលនទ្រព្យ តំបន់សេដ្ឋកិច្ចពិសេស (SEZs) ច្រករបៀងសេដ្ឋកិច្ច និងទិសដៅសាមញ្ញបំផុតនោះគឺដើម្បីផលចំនេញហិរញ្ញវត្ថុ តាមរយៈការបង្កើតឲ្យមានទីផ្សារថ្មី។ ក្នុងរយៈពេលតែប៉ុន្មានខែប៉ុណ្ណោះ ដែនទេសភាពជីវៈចម្រុះ និងប្រព័ន្ធ អេកូឡូស៊ីត្រូវបានកែប្រែឲ្យទៅជាចម្ការដំណាំកៅស៊ូ ដូងប្រេង ឬក៏ដំឡូងមី ប៊ី ឬអាងស្តុបទឹក ដែលបានលាត សន្ធឹងលើផ្ទៃដីព្រៃ ឬតំបន់ដីសើមដែលប្រហែលជាស្ថិតនៅក្នុងតំបន់ការពារ និងត្រូវបានប្រើប្រាស់ដើម្បីជា ចរន្តរកប្រាក់ចំណូលតាមទម្រង់ «បៃតង» (ឬការពារបរិស្ថាន)។ ប្រជាជនក្នុងស្រុកកម្រនឹងទទួលបានផល ប្រយោជន៍ពីតំបន់ទេសភាពដែលកំពុងផ្លាស់ប្តូរ និងទីផ្សារថ្មីទាំងនេះណាស់។ មួយភាគធំគឺពួកគេបានបាត់ បង់នូវជីវភាពរស់នៅ ផ្ទះសម្បែង វប្បធម៌ អត្តសញ្ញាណ និងលទ្ធភាពរកស្បៀងអាហារពីធនធានធម្មជាតិ។ ពួកគេត្រូវបានបណ្តេញចេញនិងប្តូរទៅទីតាំងថ្មីដោយបង្ខំ ហើយបានរុញច្រានឲ្យធ្លាក់ក្នុងការងារដែលទទួល បានប្រាក់ឈ្នួលទាប និងមានគ្រោះថ្នាក់។ (១)

បច្ចុប្បន្ននេះ ការកាន់កាប់ដីកាន់តែមានអត្រាខ្ពស់ពុំធ្លាប់មានពីមុនមក ដែលភាគច្រើននៃម្ចាស់ដីគឺជា ក្រុមអភិជនមានទំនាក់ទំនងក្នុងនយោបាយដូចជានៅក្នុងប្រទេសហ្វីលីពីន កម្ពុជា ឡាវ ម៉ាឡេស៊ី ប៉ាគីស្ថាន ឥណ្ឌា និងឥណ្ឌូនេស៊ី។ កាលពី១០ទៅ ១៥ឆ្នាំមុន រដ្ឋាភិបាលនៅទូទាំងអាស៊ីបានបន្តកែប្រែច្បាប់ជាច្រើន

ដើម្បីដកចេញនូវរបាំងការពារមួយចំនួនដែលកសិករខ្នាតតូច អ្នកនេសាទ ជនជាតិដើមភាគតិច និងអ្នករស់នៅក្នុងព្រៃដែលធ្លាប់អាស្រ័យលើតាមបែបប្រពៃណី ហើយបានធ្វើឲ្យមានភាពរងគ្រោះតាមរយៈការដកហូតយកដីរបស់ពួកគេ ដោយរដ្ឋនិងសហគ្រាសសាជីវកម្ម សម្រាប់ការធ្វើកសិឧស្សាហកម្មខ្នាតធំ ឧស្សាហកម្ម រុករករ៉ែ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង«ច្រករបៀងសេដ្ឋកិច្ច»។ (២) ការផ្លាស់ប្តូរទាំងនេះមានភាពខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ ប៉ុន្តែទាំងនេះត្រូវបានរៀបចំឡើងដើម្បីបង្កភាពងាយស្រួលដល់ក្រុមហ៊ុនក្នុងការទទួលបានដីទំហំធំ ដែលសហគមន៍កំពុងតែប្រើប្រាស់ និងដើម្បីទាញយកនូវឈើព្រៃ រ៉ែ ទឹក និងសម្បត្តិធម្មជាតិផ្សេងៗទៀត ដោយមានតែបទបញ្ញត្តិតិចតួចសម្រាប់ត្រួតពិនិត្យប៉ុណ្ណោះ។

មានអ្នកធ្វើគោលនយោបាយជាច្រើនបានលើកឡើងថា ការគ្រប់គ្រងដីដោយរដ្ឋគឺចាំបាច់ណាស់សម្រាប់ធានាឲ្យមានការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ច។ ប្រទេសឥណ្ឌូនេស៊ី និងឥណ្ឌា កំពុងតែចេញច្បាប់ដែលអនុញ្ញាតឲ្យទទួលបានដីសម្រាប់គម្រោងមេធំៗ ដោយប្រើហេតុផលដើម្បីការអភិវឌ្ឍជាតិ និងប្រយោជន៍សាធារណៈ។ ផែនការមេស្តីពីព្រៃឈើ (FMP) របស់ប្រទេសថៃគឺជាផែនការថ្មីក្រោយគេបង្អស់មួយក្នុងចំណោមការប៉ុនប៉ងជាច្រើនដែលចង់ពង្រីកចម្ការដំណាំឧស្សាហកម្មឯកវប្បកម្មនៅក្នុងប្រទេស។ ដោយបានដាក់ចេញនៅខែមិថុនា ឆ្នាំ២០១៤ ដោយទីបញ្ជាការប្រតិបត្តិការសន្តិសុខផ្ទៃក្នុងនៃប្រទេសថៃ និងក្រសួងធនធានធម្មជាតិនិងបរិស្ថាន។ ផែនការមេស្តីពីព្រៃឈើនេះបានអនុញ្ញាតឲ្យមានការធ្វើសម្បទានដល់ក្រុមហ៊ុនឯកជនសម្រាប់ធ្វើចម្ការដំណាំឧស្សាហកម្មនៅក្នុងតំបន់ព្រៃ ដែលនេះបានធ្វើឲ្យសហគមន៍ដែលកំពុងរស់នៅនិងធ្វើស្រែចម្ការនៅក្នុងព្រៃទាំងនោះប្រឈមនឹងហានិភ័យហើយត្រូវផ្លាស់ប្តូរទីលំនៅដោយបង្ខំ។ (៣)រដ្ឋាភិបាលកម្ពុជាវិញ បានបំលែងដីសាធារណៈរបស់រដ្ឋឲ្យទៅជាដីឯកជនរបស់រដ្ឋវិញ ហើយព្រមទាំងចាត់ទុកព្រៃសហគមន៍គឺជា «ព្រៃរេចរឹល» ទៅតាមការនឹកឃើញ ដើម្បីទុកធ្វើជាសម្បទានសេដ្ឋកិច្ចរយៈពេលវែងឲ្យក្រុមហ៊ុនសាជីវកម្មនៅលើដីទាំងនេះ។

ការពង្រីកនូវចម្ការដំណាំឧស្សាហកម្មបែបឯកវប្បកម្មកាន់តែអាក្រក់ជាងមុន តាមរយៈមូលនិធិថ្មីៗដែលជំរុញឲ្យមានការវិនិយោគឯកជនទៅលើវិស័យកសិកម្មដែលគេកំណត់ថា «គ្មានការកាប់បំផ្លាញព្រៃឈើ»។ សេចក្តីប្រកាសបែបនេះចុងក្រោយគេបង្អស់បានធ្វើឡើងនៅក្នុងវេទិកាសេដ្ឋកិច្ចពិភពលោក (WEF) កាលពីខែមករា ឆ្នាំ២០១៧។ រដ្ឋាភិបាលន័រវេ និងសាជីវកម្មមួយចំនួន ដូចជាខារីហ្វ៊រ (Carrefour) ម៉ាខស៍ & ស្ពែនស៊ើរ (Marks & Spencer) ម៉ារស៍ (Mars) មេត្រូ (Metro) នេស្លស្លេ (Nestlé) តេស្កូ (Tesco) និងយូនីលីវើរ (Unilever) បានសន្យាផ្តល់ជំនួយលើនេះដែលមានចំនួនរហូតដល់ទៅ៤០០លានដុល្លារអាមេរិកឯណោះ។ ជំនួយដែលបានសន្យានេះត្រូវបានអះអាងថា ជាការជំរុញឲ្យមានវិនិយោគខ្នាតធំពីវិស័យឯកជនបន្ថែមទៀត ទៅលើការប្រើប្រាស់ដីជាលក្ខណៈពាណិជ្ជកម្ម ក្នុងរបៀបមួយដែលការពារនិងស្តារព្រៃឈើ ព្រមទាំងដីជាតិដីផងដែរ។ (៤)

ផ្ទុយមកវិញ បើមើលពីបទពិសោធចេញពីកម្មវិធីស្រដៀងគ្នានេះដែល បានអនុវត្តនៅក្នុងប្រទេសវៀតណាម ឥណ្ឌូនេស៊ី ហ្វីលីពីន មីយ៉ាន់ម៉ា និងកម្ពុជា ជំនួយទាំងនេះទំនងជានឹងជំរុញលើកទឹកចិត្តឲ្យមាន

កម្មវិធីកសិកម្មតាមកិច្ចសន្យា ដែលធ្វើឲ្យកសិករខ្នាតតូចធ្លាក់ក្នុងអន្ទាក់នៃការប្រើប្រាស់ដីរបស់ពួកគេសម្រាប់ពង្រីកចម្ការដំណាំឧស្សាហកម្ម។ កម្មវិធីកសិកម្មតាមកិច្ចសន្យាបែបនេះ ហាក់មានទំនោរដាក់រាល់ហានិភ័យទាំងអស់មកលើកសិករខ្នាតតូច ខណៈដែលផ្តល់ឲ្យក្រុមហ៊ុនសាជីវកម្មនូវការគ្រប់គ្រងយ៉ាងជាក់ច្បាស់លើដីរបស់កសិករ។ ពួកគេក៏ធ្វើឲ្យមាននូវឧស្សាហកម្មស្បៀងពិភពលោក ដើម្បីបិទបាំងនូវការពង្រីកការគ្រប់គ្រងរបស់ក្រុមហ៊ុនសាជីវកម្មលើដីកសិកម្ម ក្រោមរូបភាពជាកម្មវិធី «ទំនួលខុសត្រូវសង្គម»។ ជារឿយៗនៅក្នុងកម្មវិធីកសិកម្មតាមកិច្ចសន្យាទាំងនេះ រដ្ឋាភិបាលបង្កើតឲ្យមាននូវខ្សែឥណទានធនាគារពិសេសសម្រាប់កសិករដើម្បីជួយសម្រួលដល់ការខ្ចីប្រាក់សម្រាប់ទិញ គ្រាប់ពូជ និងជី។ល។ ដូច្នេះទើបមានការឧបត្ថម្ភធនដល់គំនិតផ្តួចផ្តើមរបស់សាជីវកម្មទាំងនេះ ដើម្បីឆ្លើយតបទៅនឹងការរិះគន់លើកង្វះសកម្មភាពក្នុងការកាត់បន្ថយផលប៉ះពាល់នៃកសិឧស្សាហកម្មទៅលើបំរែបំរួលអាកាសធាតុ។ ភស្តុតាងដែលប្រមូលបានពីមូលដ្ឋានមកទល់ពេលនេះបង្ហាញថា កម្មវិធីវិនិយោគទុនឯកជនទាំងនេះបានរួមចំណែកតិចតួចណាស់ ក្នុងការបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ ឬក៏កាត់បន្ថយនូវការប្រើប្រាស់ប្រភពធំជាងគេនៃការសាយភាយឧស្ម័នផ្ទះកញ្ចក់ជាសកលចេញពីផលិតកម្មដំណាំឧស្សាហកម្ម ឧទាហរណ៍ការប្រើប្រាស់ជីនីត្រូហ្សែន។ ជាឧទាហរណ៍ នៅក្នុងគម្រោងជាច្រើនដែលរកឃើញនៅក្នុងភូមិភាគកណ្តាលនៃប្រទេសវៀតណាម កសិករត្រូវបានគេណែនាំឲ្យប្រើ ឬក៏ផ្គត់ផ្គង់ឲ្យនូវជីនីត្រូហ្សែន ដោយក្រុមហ៊ុនន័រវេមួយឈ្មោះ យ៉ារ៉ា ដែលជាក្រុមហ៊ុន សាជីវកម្មដ៏សំខាន់មួយនៅពីក្រោយចក្ខុវិស័យថ្មីសម្រាប់វិស័យកសិកម្មរបស់វេទិកាសេដ្ឋកិច្ចពិភពលោក និងដែលជាក្រុមហ៊ុននាំមុខគេមួយនៅក្នុងសម្ព័ន្ធដើម្បីកសិកម្មទ្រទ្រង់អាកាសធាតុ (Alliance for Climate Smart Agriculture)។ (៥)

ខណៈពេលនោះដែរ កសិកម្មបែបប្រពៃណីដែលអនុវត្តដោយកសិករនិងកសិករខ្នាតតូចបានបន្តប្រឈមនឹងឧបសគ្គជាច្រើន។ ឧទាហរណ៍ នៅក្នុងប្រទេសឡាវ អ្នកធ្វើគោលនយោបាយបានមើលឃើញថាកសិកម្មចម្ការវិលជុំគឺជាមូលហេតុចម្បងធំមួយដែលនាំឲ្យមានការកាប់បំផ្លាញព្រៃឈើ។ ឧទាហរណ៍ នៅក្នុងទសវត្សឆ្នាំ៩០ រដ្ឋាភិបាលឡាវបានចាប់ផ្តើមអនុវត្តកម្មវិធីការបែងចែកដីធ្លីនិងព្រៃឈើ ដែលហាមឃាត់ការធ្វើចម្ការវិលជុំ និង បានណែនាំពីរបៀបគ្រប់គ្រងដីប្រភេទផ្សេងៗគ្នា។ ការសិក្សាជាច្រើនបានបង្ហាញថា ផ្ទុយពីក្តីរំពឹងទុកកម្មវិធីការបែងចែកដីធ្លីនិងព្រៃឈើ បានបង្កើនឲ្យមានអសន្តិសុខដីនិងស្បៀង ភាពក្រីក្រនិងការចំណាកស្រុកដោយគ្មានជម្រើស ហើយក៏ពុំបានត្រួតពិនិត្យលើការកាប់បំផ្លាញព្រៃឈើ មុនពេលដែលសហគមន៍មិនទាន់ក្លាយមូលហេតុនៃការកាប់ព្រៃឈើនោះទេ។ (៦) ថ្មីៗនេះ រដ្ឋាភិបាលបានចេញនូវបទបញ្ញត្តថ្នាក់ខេត្ត ស្តីពី «ច្រករបៀងអភិរក្សជីវៈចម្រុះ» បានបង្កើតឲ្យមាននូវមូលនិធិផ្នែកច្បាប់សម្រាប់គ្រប់គ្រងអ្វីដែលហៅថា «ច្រករបៀងជីវៈចម្រុះ» ដោយមានថវិកាចំនួន១២,៨លានដុល្លារអាមេរិក គាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ កម្មវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនេះ មានគោលបំណងធ្វើការសាកល្បងនូវកម្មវិធី «ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព» និងត្រៀមរៀបចំប្រទេសឲ្យទទួលបាននូវហិរញ្ញប្បទានសម្រាប់គម្រោងកាត់បន្ថយការបំភាយឧស្ម័នពីការកាប់បំផ្លាញព្រៃឈើ និងការរេចរឹលនៃព្រៃឈើ (REDD)។ ការធ្វើផែនការប្រើប្រាស់ដីត្រូវបានអនុវត្តនៅក្នុងភូមិចំនួន៦៧ភូមិ ដោយគ្របដណ្តប់លើផ្ទៃដីព្រៃចំនួន៣៥ម៉ឺនហិចតា ជាកន្លែងដែលសហគមន៍មូលដ្ឋានត្រូវបានហាមឃាត់មិនឲ្យបន្តធ្វើចំការវិលជុំតទៅទៀត។ (៧)

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងកិច្ចព្រមព្រៀងវិនិយោគ បានធ្វើឲ្យមានការកាប់បំផ្លាញព្រៃឈើ និងការសឹករេចរិលប្រព័ន្ធអេកូឡូស៊ី និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកែសម្រួលខ្លឹមសារច្បាប់និងគោលនយោបាយ ដោយជួយឲ្យបាននូវទឹកនិងដីធ្លីសម្រាប់ការវិនិយោគខ្នាតធំ ។ ពួកគេអនុវត្តដោយប្រយោលនិងផ្ទាល់ ដែលការអនុវត្តដោយប្រយោលគឺតាមរយៈការជំរុញឲ្យមានផលិតកម្មសម្រាប់នាំចេញ ដោយត្រូវការឯកទេសជាក់លាក់ និងការគ្រប់គ្រងសង្វាក់ផលិតកម្ម ដែលនេះធ្វើឲ្យមានការពង្រីកការរុករករ៉ែ និងចម្ការដំណាំឧស្សាហកម្មតែមួយមុខក្នុងទ្រង់ទ្រាយធំ។ ចំណែកឯដោយផ្ទាល់វិញគឺ តាមរយៈការដាក់ជាកាតព្វកិច្ចដល់រដ្ឋាភិបាលឲ្យដកចេញនូវរបាំងដែលជាឧបសគ្គសម្រាប់វិនិយោគទុនបរទេស។ (៨) ឧទាហរណ៍ នៅក្នុងខែមករា ឆ្នាំ២០១៦ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) បានដាក់ឲ្យដំណើរការនូវសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលជាចេតនាក្នុងការបង្កើតនូវទីផ្សាររួមតែមួយប្រចាំតំបន់ និងមូលដ្ឋានផលិតកម្មប្រកបដោយលក្ខណៈប្រកួតប្រជែងនិងធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក។ (៩) ដើម្បីសម្របសម្រួលដល់ដំណើរការរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន រដ្ឋាភិបាលនៃប្រទេសជាសមាជិករបស់អាស៊ានបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយចំនួន ដើម្បីសម្រួលដល់វិនិយោគិនខ្នាតធំក្នុងការទទួលបានដី ធនធានធម្មជាតិ វត្ថុធាតុដើម និងកម្លាំងពលកម្ម ព្រមទាំងផ្តល់ការការពារផ្នែកច្បាប់សម្រាប់សិទ្ធិរបស់ពួកគេក្នុងការធ្វើប្រតិបត្តិការនិង រកប្រាក់ចំណេញ។ គ្មានការការពារបែបនេះសម្រាប់ប្រជាជនមូលដ្ឋានដែលបាត់បង់ដីធ្លី ព្រៃឈើ ប្រភពទឹក និងជីវភាពរស់នៅ របស់ពួកគេ ដូចជាការការពារគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និង គម្រោងវិនិយោគផ្សេងៗ សម្រាប់ការអភិវឌ្ឍនោះទេ។

នៅក្នុងតំបន់ទន្លេមេគង្គ កម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ចមហាអនុតំបន់ទន្លេមេគង្គ (GMS) ដែលដឹកនាំធ្វើដោយធនាគារអភិវឌ្ឍន៍អាស៊ី មានគោលបំណងប្រែក្លាយធនធានមនុស្សនិងធនធានធម្មជាតិដ៏សម្បូរបែបនៅក្នុងតំបន់ទន្លេមេគង្គឲ្យទៅជាតំបន់ពាណិជ្ជកម្មសេរី និងជាតំបន់វិនិយោគតាមរយៈការវិនិយោគលើពហុវិស័យប្រកបដោយមហិច្ឆតាទៅលើវិស័យដឹកជញ្ជូន (ផ្លូវថ្នល់ ផ្លូវដែក ផ្លូវអាកាស និងផ្លូវទឹក) ថាមពល ការពង្រីកទីក្រុង ទូរគមនាគមន៍ ទេសចរណ៍ ការសម្របសម្រួលពាណិជ្ជកម្ម និងកសិកម្ម។ ចំនុចស្នូលនៃក្របខណ្ឌយុទ្ធសាស្ត្ររបស់មហាអនុតំបន់ទន្លេមេគង្គគឺការអភិវឌ្ឍច្រករបៀងសេដ្ឋកិច្ច ដែលនេះគឺជាការវិនិយោគទុនយ៉ាងច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធ។ ច្រករបៀងសេដ្ឋកិច្ចមួយចំនួនគឺអមទៅដោយ «ច្រករបៀងអភិរក្សជីវៈចម្រុះ» ដូចជានៅក្នុងប្រទេសឡាវ កម្ពុជា និងវៀតណាមជាដើម។ ច្រករបៀងអភិរក្សជីវៈចម្រុះទាំងនេះគឺគ្របដណ្តប់លើផ្ទៃដី និងដីព្រៃចំនួនពីរលានហិចតា ហើយប្រើជាផ្នែក «បៃតង» សម្រាប់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ។ យុទ្ធសាស្ត្រកសិកម្មរបស់មហាអនុតំបន់ទន្លេមេគង្គ ផ្តោតលើការធ្វើសមាហរណកម្មកសិករធ្វើសម្រាប់ហូបក្នុងតំបន់ទៅក្នុងសង្វាក់ផ្គត់ផ្គង់ថ្នាក់តំបន់ និងពិភពលោក ដែលគ្រប់គ្រងដោយក្រុមហ៊ុនសាជីវកម្មកសិពាណិជ្ជកម្ម ហើយបង្វែរទិសដៅផលិតកម្មកសិកម្មពីការផលិតដើម្បីចិញ្ចឹមគ្រួសារ ឆ្ពោះទៅរកការផ្គត់ផ្គង់ចិញ្ចឹមទីផ្សារក្នុងតំបន់និងសកលលោក។

ដោយមិនគិតពីការឃោសនាពីការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយចីរភាពនោះ គំរូនៃការអភិវឌ្ឍដែលលើកកម្ពស់និងគាំទ្រដោយរដ្ឋាភិបាល ម្ចាស់ជំនួយ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ កំពុងបង្កើន

ការស្រូបទាញយកធនធានធម្មជាតិ ហើយបង្កើតភាពអយុត្តិធម៌និងវិសមភាព។ គំរូនេះគឺយកធម្មជាតិ ធនធានមនុស្ស និងវត្ថុធាតុដើម ឲ្យទៅក្រុមហ៊ុនសាជីវកម្មរកផលចំណេញ ហើយវាព្រមទាំងបំផ្លាញនូវប្រព័ន្ធអេកូឡូស៊ី សហគមន៍ និងប្រហែលជាអាចយកទាំងសេចក្តីថ្លៃថ្នូរនៃជីវិតផង។ អំពើហិង្សាលើមនុស្សជាតិនិងធម្មជាតិ គឺជាចំនុចសំខាន់នៃគំរូនេះ។ វាជារឿងអស្ចារ្យដែលប្រជាជននៅទូទាំងអាស៊ីកំពុងប្រឆាំងតបតនឹងការអភិវឌ្ឍបែបនេះ។ ពួកគេប្រឈមមុខនឹងហានិភ័យខ្ពស់ពីនយោបាយនិងសន្តិសុខ ក្នុងការការពារដីធ្លី ទឹក ព្រៃ និងប្រព័ន្ធអេកូឡូស៊ីរបស់ពួកគេ ពីពួកមូលធនដែលកំពុងស្រូបទាញយកធនធានធម្មជាតិឥតឈប់ឈរ។

***ហ្សាលម៉ាលី ហ្គុត្តាល*** ***(Shalmali Guttal)*** *នាយិការបស់ហ្វ៉ូឃើស អន ដឹ គ្លោប៊ល សោតហ៍ (Focus on the Global South)*

***ការទីនី សាមុន*** ***(Kartini Samon)*** *ហ្រ្គេន (GRAIN)*

(១) សាលម៉ាលី ហ្គុត្តាល (Shalmali Guttal)។ សេចក្តីផ្តើម៖ ការកំណត់ន័យអភិបាលកិច្ចឡើងវិញ។ ឧបសគ្គរបស់ទីផ្សារនៅក្នុងការ*រក្សាដីមូលដ្ឋាន៖ ការទាមទារអភិបាលកិច្ចមកវិញពីទីផ្សារ។* ខែតុលា ឆ្នាំ២០១៤។ http://focusweb.org/landstruggles

(២) ហ្រ្គេន (GRAIN)។ ភាពបញ្ច្រាសមកវិញនៃកំណែទម្រង់កសិកម្មរបស់អាស៊ី៖ ច្បាប់ដែលយកដីពីក្នុងដៃរបស់កសិករតូចតាច។ ខែមេសា ឆ្នាំ២០១៥។ https://www.grain.org/article/entries/5195-asia-s-agrarian-reform-in-reverse-laws-taking-land-out-of-small-farmers-hands

(៣) ដាប់ប៊ូលយូ អ អ៊ឹម (WRM)។ ផែនការមេថ្មីស្តីពីព្រៃឈើរបស់ប្រទេសថៃ៖ យុទ្ធសាស្ត្រចាស់ដដែលៗតែតុបតែងនៅក្នុងសំលៀកបំពាក់ថ្មី។ ព្រឹត្តិប័ត្រចលនាព្រៃស្រោងពិភពលោក លេខ២០៨ ខែវិច្ឆិកា ឆ្នាំ២០១៤។ http://wrm.org.uy/bulletins/issue-208/

(៤) វេទិកាសេដ្ឋកិច្ចពិភពលោក។ ការសម្ពោធនូវមូលនិធិជំនួយចំនួន៤០០លានដុល្លារនៅដាវ៉ូស (Davos) ដើម្បីបញ្ឈប់ការកាប់បំផ្លាញព្រៃឈើនៅតំបន់ត្រូពិច និងជំរុញការធ្វើកសិកម្ម។ ខែមករា ឆ្នាំ២០១៧។ https://www.weforum.org/press/2017/01/400-million-fund-launched-in-davos-to-stop-tropical-deforestation-and-boost-farming/

(៥) ហ្រ្គេន (GRAIN)។ ក្រុមហ៊ុនសាជីវកម្ម៥០០វិនិយោគលើកសិកម្ម។ ខែធ្នូ ឆ្នាំ២០១៦។ https://www.grain.org/article/entries/5622-grow-ing-disaster-the-fortune-500-goes-farming

(៦) សម្រាប់ព័ត៌មានបន្ថែម សូមមើល ឧទាហរណ៍ដូចជា៖ សាលម៉ាលី ហ្គុត្តាល (Shalmali Guttal) *ដីរបស់នរណា ធនធានរបស់នរណា?* នៅក្នុងការអភិវឌ្ឍ, ២០១១, ៥៤(១), (៩១-៩៧) ២០១១ សង្គមដើម្បីការអភិវឌ្ឍអន្តរជាតិ ១០១១-៦៣៧០/១១ www.sidint.net/development/

(៧) ធនាគារអភិវឌ្ឍន៍អាស៊ី។ ជំនួយរបស់ធនាគារអភិវឌ្ឍន៍ដើម្បីគាំទ្រដល់និរន្តរភាពនៃការគ្រប់គ្រង ជីវៈចម្រុះ។ ខែតុលា ឆ្នាំ២០១៦។ https://www.adb.org/news/adb-grant-assistance-support-sustainable-biodiversity-management

(៨) ឡូរ៉េនហ្សូ កូទុឡូ (Lorenzo Cotula)។ ដោះស្រាយបញ្ហារបស់ច្បាប់ពាណិជ្ជកម្មដែលផ្តោតលើផ្នែកការដណ្តើមដីធ្លី។ ស្ថាប័នអន្តរជាតិដើម្បីបរិស្ថាននិងអភិវឌ្ឍន៍។ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៣។ http://www.iied.org/tackling-trade-law-dimension-land-grabbing

(៩) http://investasean.asean.org/index.php/page/view/asean-economic-community/view/670/newsid/755/about-aec.html

# ជម្លោះព្រៃឈើនៅក្នុងប្រទេសថៃៈ រដ្ឋតទល់នឹងរាស្ត្រ

នយោបាយព្រៃឈើនៅប្រទេសថៃនាសម័យបច្ចុប្បន្ន បានឆ្លងកាត់ច្រើនដំណាក់កាល។ នៅក្នុងសតវត្សទី១៩ ប្រទេសអង់គ្លេសបានចាប់ផ្តើមកាប់ព្រៃក្នុងប្រទេសដើម្បីយកឈើម៉ៃសាក់។ ក្រោយមកនៅក្នុងសតវត្សទី២០ ឈ្មួញឈើផ្សេងទៀតក៏បានក្តោបក្តាប់យកឈើទាំងស្រុង។ ស្ថាប័នរដ្ឋបានបដិសេធយ៉ាងដាច់អហង្ការមិនព្រមឲ្យព្រៃឈើទៅក្រុមឧទាមនានា ខណៈខ្លួនបានជំរុញនូវកសិពាណិជ្ជកម្ម និងទំនប់វារីអគ្គិសនី ព្រមទាំងការដកហូតព្រៃឈើ។ នៅក្នុងឆ្នាំ១៩៨៩ ដោយសារព្រៃឈើដែលគ្របដណ្តប់ប្រទេសត្រូវបំផ្លាញយ៉ាងធ្ងន់ធ្ងរបំផុត ការកាប់ ព្រៃឈើត្រូវបានហាមឃាត់ជាផ្លូវការ។

ទោះនៅក្នុងសម័យកាលដែលផ្តោតលើ «ការអភិរក្សព្រៃឈើ» និង «ការស្តារព្រៃឈើ» យ៉ាងណាក្តីក៏តំបន់ព្រៃនៅក្នុងប្រទេសបន្តថយចុះ ហើយជម្លោះចេះតែកើនឡើងរវាងរដ្ឋាភិបាលនិងប្រជាជននៅមូលដ្ឋាន។

ជម្លោះទាំងនេះមានឫសគល់ខ្លះពាក់ព័ន្ធនឹងផ្លូវច្បាប់ ដែលត្រូវបានការពារយ៉ាងខ្លាំងនៅក្នុងនាយកដ្ឋានភូមិន្ទព្រៃឈើរបស់ថៃ ដែលកាន់កាប់ទាំងដីព្រៃ និងដីមិនមែនព្រៃយ៉ាងច្រើនលើសលប់។ សហគមន៍ជាង១១ ០០០ នៅទូទាំងប្រទេសកំពុងស្ថិតនៅលើដីកម្មសិទ្ធិរបស់រដ្ឋ ដែលគ្របដណ្តប់៤៧ភាគរយនៃផ្ទៃដីប្រទេស។ ជាងនេះទៅ ទៀត ទោះបីជានាយកដ្ឋានភូមិបាលរបស់ថៃ បានចេញឯកសារដីធ្លីឯកត្តជនជាច្រើនប្រភេទទៅលើដីចំនួនជាង២០លានហិចតា នៃចំនួនផ្ទៃដីជាតិសរុប៥១លានហិចតារួមបញ្ចូលទាំងដីព្រៃរបស់រដ្ឋភាគច្រើនក៏ដោយ ក៏៩០ភាគរយនៃកម្មសិទ្ធិដីធ្លីទាំងនេះ ស្ថិតនៅក្នុងដៃប្រជាជនតិចជាង១០ភាគរយនៃចំនួនប្រជាជនសរុបតែប៉ុណ្ណោះ។ យ៉ាងហោចណាស់៣៨ភាគរយនៃដីកម្មសិទ្ធិឯកជន ហើយប្រហែលជាអាចច្រើនជាងនេះត្រូវបានទុកទំនេរចោល។ នេះជាកត្តាធ្វើឲ្យមានជម្លោះមិនអាចជៀសបានពោលគឺមិនត្រឹមតែគ្រួសារចំនួន១,៥លាន គ្រួសារត្រូវជួលដីធ្វើស្រែប៉ុណ្ណោះទេ ថែមទាំងគ្រួសារកសិករជាង៨០ ម៉ឺនគ្រួសារទៀតក៏គ្មានកម្មសិទ្ធិដីផ្ទាល់ខ្លួនទាល់តែសោះ។

ទន្ទឹមនឹងនេះដែរ ច្បាប់ស្តីពីការស្តារព្រៃឈើឆ្នាំ១៩៩៣ បានដាក់ឲ្យស្របច្បាប់នូវការយកដីរដ្ឋដែលសហគមន៍កំពុងប្រើប្រាស់សម្រាប់ធ្វើកសិកម្ម ទៅធ្វើជាចម្ការដំណាំឧស្សាហកម្មដែលកំពុងមានសន្ទុះខ្លាំងទៅវិញ។ បច្ចុប្បន្ននេះ រដ្ឋប្រើហេតុផលដដែលមួយដើម្បីធ្វើការបណ្តេញប្រជាជនចេញពីតំបន់ដីព្រៃដែលច្បាប់កំណត់។ ហេតុផលនោះគឺសំដៅថា អ្នកភូមិកំពុងបង្កឲ្យកើនកម្តៅផែនដីតាមរយៈការតាំងទីលំនៅរបស់ពួកគេ។

អត្ថបទនេះ ពិភាក្សាអំពីជម្លោះមួយចំនួននៅ ក្នុងខេត្តពីរស្ថិតនៅភូមិភាគខាងជើងនៃប្រទេសថៃ គឺខេត្តផេតចាប៊ុន និង ខេត្តឆៃយ៉ាភូមិ ជាទីតាំងដែលវិធានការអភិរក្សព្រៃឈើជាផ្លូវការបានរំលោភទន្ទ្រានលើទីលំនៅរបស់ប្រជាជន។

**ខេត្តផេតចាប៊ុន**

ហួយរ៉ាហុង ដែលជាភូមិមួយស្ថិតនៅក្នុងខេត្តផេតចាប៊ុន នៅភូមិភាគខាងជើងនៃប្រទេសថៃ និងមានប្រជាជនរស់នៅចំនួន១២០០នាក់ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៧១មកម្ល៉េះ។ អ្នកភូមិភាគច្រើនដែលកំពុងរស់នៅភូមិហួយរ៉ាហុងសព្វថ្ងៃនេះ ពីមុនត្រូវបានបណ្តេញចេញពីភូមិរបស់ពួកគេឈ្មោះសំបុន នៅពេលដែលរដ្ឋាភិបាលបានបង្កើតជាឧទ្យានជាតិណាំណៅ នៅទីនោះក្នុងឆ្នាំ១៩៧១។ ភូមិមួយទៀតនៅក្បែរនោះ គឺភូមិហួយ ខុនតា ដែលមានទំហំតូចជាងត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៦៣។

នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ រដ្ឋាភិបាលបានបង្កើតនូវតំបន់ដែនជម្រកសត្វព្រៃមួយឈ្មោះថាភូផាខែង (ជំរាលភ្នំរ៉េតគ្លីហ្វប) នៅលើដីដែលត្រួតលើទីតាំងរស់នៅរបស់អ្នកភូមិ និងមានព្រៃព្រឹក្សានៅជុំវិញកន្លែងនោះ ហើយបានបង្ហាញនូវចេតនាយ៉ាងច្បាស់ក្នុងការបណ្តេញអ្នកភូមិចេញពីទីនោះ។ អ្នកភូមិហួយរ៉ាយ ដែលជាភូមិតូចមួយនៅជាប់គ្នានឹងភូមិហួយរ៉ាហុង ត្រូវបានបណ្តេញចេញរួចទៅហើយដោយពុំទទួលបាននូវសំណង ឬដីថ្មីសម្រាប់តាំងទីលំនៅឡើយ។ មន្ត្រីខាងឧទ្យានជាតិបានប្រើល្បិចឲ្យគ្រួសារទាំងនោះចាកចេញដោយសន្យាថានឹងផ្តល់សំណង ប្រសិនបើពួកគេព្រមចេញពីភូមិ។ ទោះជាយ៉ាងណាក្តី ដោយសារអ្នកភូមិពុំមានប័ណ្ណកម្មសិទ្ធិដីធ្លី ការសន្យានោះពុំមានអ្វីជាសំអាងតាមផ្លូវច្បាប់នោះទេ ហើយគ្រាន់តែត្រូវបានប្រើជាល្បិចឲ្យអ្នកភូមិចាកចេញ ប៉ុណ្ណោះ។

ភូមិហួយខុនតា ក៏ស្ថិតនៅក្រោមការគំរាមកំហែងឥតឈប់ឈរដែរ។ នៅឆ្នាំ២០០៥ នៅពេលដែលប្រជាជនចំនួន១៣នាក់ (មានកុមារម្នាក់ និងជនពិការម្នាក់) ត្រូវបានអ្នកជិតខាងម្នាក់ជួលឲ្យទៅកាច់ពោតនៅក្នុងចម្ការដែលស្ថិតក្នុងដែនជម្រកសត្វព្រៃនោះ ប្រធានដែនជម្រកនោះបានចោទប្រកាន់ពួកគេពីបទព្រហ្មទណ្ឌឆ្លងកាត់ដោយគ្មានការអនុញ្ញាត។ តុលាការនៅពេលនោះបានច្រានចោលនូវករណីនេះ ដោយនិយាយថាស្ថានភាពរបស់ដីមួយប្លង់តូចដែលកំពុងតែចោទសួរនោះ (តិចជាងមួយហិចតាកន្លះ) គឺគ្មានភាពច្បាស់លាស់នោះទេ។ ប៉ុន្តែការសម្រេចរបស់សាលាឧទ្ធរណ៍គឺផ្ទុយនឹងសេចក្តីសម្រេចរបស់សាលាដំបូង ជាលទ្ធផលដោយកាត់ទោស ដាក់ពន្ធនាគារចំនួនប្រាំមួយខែ (នឹងព្យួរទោសចំនួនពីរឆ្នាំ)។ ក្រោយមកតុលាការកំពូលក៏គោរពទៅតាមការសម្រេចរបស់សាលាឧទ្ធរណ៍ដែរ។

អ្នកភូមិហួយខុនតា ក៏ប្រឈមមុខនឹងរឿងក្តីរដ្ឋប្បវេណីជាមួយនាយកដ្ឋានឧទ្យានជាតិដែរពីបទ «បង្កឲ្យមានការកើនកម្តៅផែនដី» ក្រោមច្បាប់បរិស្ថានឆ្នាំ១៩៩២ ដែលកំណត់ឲ្យអ្នកបំពុលបរិស្ថានទទួលខុសត្រូវចំពោះការខូចខាត។ ច្បាប់នេះដែលជាទូទៅត្រូវអនុវត្តលើឧស្សាហកម្មដែលបំពុលបរិស្ថាននោះ ថ្មីៗនេះបែរជាត្រូវបានយកមកប្រើប្រាស់ជាអាវុធប្រឆាំងនឹងអ្នកភូមិក្រីក្រនៅជនបទទៅវិញ ដោយមានក្រុមបញ្ញវន្តជាប់

កិច្ចសន្យាទទួលកិច្ចការងារនេះ ដែលពួកគេបានបង្កើតនូវរូបមន្តគណនាមួយធ្វើឲ្យកសិករនៅភូមិហួយខុនតាត្រូវបង់ប្រាក់ពិន័យ រហូតដល់ទៅ២៦២៥០ដុល្លារអាមេរិក ក្នុងទំហំដីមួយហិចតា ចំពោះ «ការបង្ក» ឲ្យមានកំណើនសីតុណ្ហភាព សំនឹកដី ការថយចុះនូវសារធាតុចិញ្ចឹមរបស់ដី និងការខូចខាតលើប្រព័ន្ធផ្លូវទឹក។ សរុបមកតាមទ្រឹស្តីអ្នកភូមិអាចត្រូវទទួលខុសត្រូវជាប្រាក់ចំនួន ៧០០០០ដុល្លារអាមេរិក ចំពោះការខូចខាតដែលនេះគឺជាចំនួនសរុបមួយដ៏ច្រើនសម្រាប់ស្តង់ដារនៅមូលដ្ឋាន។ នៅក្នុងករណីមួយនោះ កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ តុលាការបានពិន័យចុងចោទមកពីភូមិហួយខុនតា ចំនួន៣.៥៦២ដុល្លារអាមេរិកក្នុងមួយហិចតា បូកនឹងការប្រាក់ប្រចាំឆ្នាំចំនួន ៧,៥ភាគរយថែមទៀត រាប់តាំងពីឆ្នាំ២០០៥មក។

អ្នកភូមិបន្តប្រយុទ្ធប្រឆាំងជាមួយនឹងអ្វីដែលពួកគេមើលឃើញថាជាភាពអយុត្តិធម៌នៃច្បាប់។ ពួកគេមិនត្រឹមតែដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅតុលាការនោះទេ ពួកគេថែមទាំងដាក់សំណើសុំប្រកបដោយភាពច្នៃប្រឌិតដើម្បីទាមទារ «ប្លង់កម្មសិទ្ធិដីសហគមន៍» ប្រភេទថ្មីមួយ ដែលពួកគេជឿថាវាអាចដោះស្រាយបញ្ហាបានដោយសន្តិវិធីក្នុងពេលយូរអង្វែង។ កម្មសិទ្ធិដីសមូហភាពអាចកាត់បន្ថយនូវហានិភ័យដែលដីត្រូវបានលក់ ឬក៏គ្រួសារត្រូវបានបង្ខំឲ្យបោះបង់ចោលដីទៅតាមវិធីផ្សេងៗដែលអាចទៅរួច ប្រសិនបើវាត្រូវបានចុះឈ្មោះក្រោមប្លង់កម្មសិទ្ធិដីបុគ្គល។ គម្រោងស្នើសុំបានដាក់ចេញនូវដំណើរការមួយសម្រាប់សហគមន៍បង្កើតនូវបទបញ្ញត្តិ និងគណៈកម្មការមួយដែលដឹកនាំដោយសហគមន៍ក្នុងការគ្រប់គ្រងថែរក្សាដីធ្លី។ ជាងនេះទៅទៀត ផលដែលបានមកពីការប្រើប្រាស់ដីដោយសហគមន៍ នឹងរួមចំណែកទៅក្នុង «មូលនិធិដីធ្លី» មួយដែលជួយគាំទ្រដល់សមាជិករបស់សហគមន៍ក្នុងពេលត្រូវការ។

**ខេត្តឆៃយ៉ាភូម** (**Chaiyaphum**)

ជម្លោះលើគម្រោងចម្ការឈើដាំឧស្សាហកម្មខនសាន នៅខេត្តឆៃយ៉ាភូម កើតឡើងនៅក្នុងឆ្នាំ ១៩៧៨ នៅពេលដែលនាយកដ្ឋានភូមិន្ទព្រៃឈើ បានផ្តល់ការអនុញ្ញាតដល់អង្គការឧស្សាហកម្មព្រៃឈើដាំដើមប្រេងខ្យល់ នៅក្នុងតំបន់ត្រួតស៊ីគ្នាជាមួយនឹងទីតាំងដីស្រែចម្ការរបស់ប្រជាជនមូលដ្ឋាន។

អង្គការឧស្សាហកម្មព្រៃឈើ ដែលជាសហគ្រាសរដ្ឋមួយស្ថិតក្រោមក្រសួងកសិកម្ម និងសហប្រតិបត្តិការ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៤៧ បន្ទាប់ពីការសម្បទានដែលបានផ្តល់ឲ្យក្រុមហ៊ុនកាប់ឈើបរទេសត្រូវផុតកំណត់។ តាមប្រវត្តិសាស្ត្រ ការងាររបស់គេគឺអាចដកហូតធនធានឈើតាមលក្ខខណ្ឌតម្រូវនៅពេលដែលពួកគេបានស្តារព្រៃឈើនៅក្នុងតំបន់ដែលបានកាប់បំផ្លាញ។

នេះជាភស្តុតាងបញ្ជាក់ពីបញ្ហាមួយនៅក្នុងខេត្តឆៃយ៉ាភូម ដែលតំបន់ភ្នំនានានៅទីនោះត្រូវបានកាប់បំផ្លាញ ហើយបន្តស្ថិតក្រោមការកាន់កាប់យ៉ាងមាំទាំរបស់គណបក្សកុម្មុយនីយថៃ តាំងពីឆ្នាំចុងទសវត្សឆ្នាំ៧០មកម្ល៉េះ។ ដោយមិនហ៊ានឈានជើងចូលទៅក្នុងតំបន់នោះ អង្គការឧស្សាហកម្មព្រៃឈើនេះក៏បានស្នើសុំស្តារព្រៃឈើឡើងវិញ នៅក្នុងតំបន់ទាបៗជាងនេះជំនួសវិញ រួមបញ្ចូលទាំងនៅក្នុងតំបន់ព្រៃបម្រុងជាតិឈ្មោះ

ភូសំប៉ាក់ណាំ ដែលបានបង្កើតឡើងនៅក្នុង ឆ្នាំ១៩៧៣ ជាផ្នែកមួយដែលក្រោយមកនៅក្នុងឆ្នាំ២០០០ បានក្លាយទៅជាតំបន់ដែនជម្រកសត្វព្រៃ។

ដំបូងឡើយ ចម្ការដើមប្រេងខ្យល់ដែលបានអនុញ្ញាតនោះ ត្រូវបានគេរំពឹងថានឹងគ្របដណ្តប់លើផ្ទៃដី ចំនួន ៣២០០ហិចតា។ តាមជាក់ស្តែង មានផ្ទៃដីចំនួន៧០៤ហិចតាប៉ុណ្ណោះដែលបានដាំដុះ ដោយសារតែមានការតស៊ូប្រឆាំងពីអ្នកកាន់កាប់ដីនៅទីនោះ ប៉ុន្តែអង្គការឧស្សាហកម្មព្រៃឈើ នៅតែបន្តព្យាយាមរហូតដល់ឆ្នាំ១៩៨៦ ក្នុងការបណ្តេញប្រជាជនមូលដ្ឋានចេញដោយប្រើឧបករណ៍ទាំងផ្លូវច្បាប់ និងពួកម៉ាហ្វៀនៅមូលដ្ឋានក្នុងការដាក់សម្ពាធលើពួកគេ។ យុទ្ធសាស្ត្រមួយទៀតគឺគម្រោងស្នើសុំ «ភូមិព្រៃ» ដែលអង្គការឧស្សាហកម្មព្រៃឈើ បែងចែកដីក្រោមមួយហិចតាក្នុងមួយគ្រួសារសម្រាប់សាងសង់ផ្ទះដល់គ្រួសារដែលបានចូលរួមក្នុងគម្រោង ហើយនិងដីសម្រាប់ធ្វើកសិកម្មបន្តិចបន្តួចតែប៉ុណ្ណោះ។ ប៉ុន្តែមានតែគ្រួសារចំនួន ៨០ក្នុងចំណោម១០២គ្រួសារប៉ុណ្ណោះ ដែលរស់នៅក្នុងតំបន់មានជម្លោះនោះ បានសម្រេចចូលរួមក្នុងគម្រោងនេះ។

នៅក្នុងឆ្នាំ២០០៤ គ្រួសារចំនួន២៧៧គ្រួសារដែលរងគ្រោះពីគម្រោងរបស់អង្គការឧស្សាហកម្មព្រៃឈើ បានចូលរួមជាមួយគ្នាជាបណ្តាញមួយ ហើយបានទាមទារឲ្យរដ្ឋាភិបាលលុបចោលនូវការដាំដំណាំឧស្សាហកម្ម ហើយបែងចែកដីទៅឲ្យសហគមន៍វិញ។ ពួកគេបានស្នើឲ្យរដ្ឋាភិបាលចេញនូវប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ និងទទួលស្គាល់ថាសហគមន៍មានសិទ្ធិរៀបចំនិងគ្រប់គ្រងលើដីព្រៃសហគមន៍របស់ពួកគេ។ ពួកគេក៏បានស្នើឲ្យផ្តល់នូវដីមួយប្លង់តូចដល់គ្រួសារនីមួយៗដែលបានចូលរួមទុកសម្រាប់សាងសង់ផ្ទះ និងផលិតស្បៀង ក៏ដូចជាផ្តល់នូវព្រៃសហគមន៍ ដីកសិកម្មសមូហភាព និងដីសម្រាប់សាធារណៈឬសម្រាប់សហគមន៍ប្រើប្រាស់។ មកទល់ពេលនេះ រដ្ឋាភិបាលពុំបានឆ្លើយតបអ្វីនោះទេ។

ក្នុងឆ្នាំ២០០៩ អ្នកភូមិមូលដ្ឋានបានទាមទារយកដីប្រមាណជា ១៥ហិចតា ដែលអង្គការឧស្សាហកម្មព្រៃឈើ បានដាំដើមប្រេងខ្យល់នៅទីនោះនៅក្នុងឆ្នាំ ២០០៤ ដោយចាត់ចែងវាឡើងវិញជាបួនផ្នែកសម្រាប់ការប្រើប្រាស់របស់ពួកគេគឺ ដីលំនៅឋានរបស់គ្រួសារនិងដីកសិកម្ម ដីសមូហភាព ព្រៃសហគមន៍ និងដីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈដូចជាសម្រាប់ធ្វើផ្លូវជាដើម។ អង្គការឧស្សាហកម្មព្រៃឈើ បានវាយបកមកវិញដោយប្តឹងប្រជាពលរដ្ឋចំនួន៣១នាក់ទៅតុលាការរដ្ឋប្បវេណី ហើយជាលទ្ធផលបានចេញបញ្ជាឲ្យជនជាប់ចោទនិងសមាជិកគ្រួសាររបស់ពួកគេត្រូវចាកចេញពីតំបន់នោះ។ មកទល់ពេលនេះ អ្នកភូមិបានបដិសេធមិនអនុវត្តតាមសាលក្រមនោះទេ ។

ក្នុងឆ្នាំ២០១៤ យោធារបស់ថៃបានឡើងកាន់កាប់អំណាច ហើយបានបង្កើតទៅជាក្រុមប្រឹក្សាជាតិដើម្បីរក្សាសន្តិភាព (National Peace Keeping Council (NPKC))។ គោលនយោបាយស្តីពីកំណែទម្រង់ដីព្រៃរបស់ក្រុមប្រឹក្សាជាតិដើម្បីរក្សាសន្តិភាព ដែលមានគោលបំណងបង្កើនទំហំព្រៃរបស់ប្រទេសឲ្យគ្របដណ្តប់ដល់ ៤០ភាគរយនោះ ត្រូវបានកេងចំណេញដោយអាជ្ញាធរប្រចាំខេត្តឆៃយ៉ាភូមិ ធ្វើជាមូលដ្ឋានគ្រឹះសម្រាប់បញ្ជាឲ្យប្រជាជននៅភូមិបូកែវ នៅក្នុងតំបន់ចម្ការដំណាំឧស្សាហកម្មរបស់អង្គការឧស្សាហកម្មព្រៃឈើ រុះរើភូមិរបស់

ពួកគេចេញក្នុងរយៈពេល៣០ថ្ងៃ។ ប៉ុន្តែ ដោយផ្អែកលើការលើកឡើងរបស់ក្រុមប្រឹក្សាជាតិដើម្បីរក្សាសន្តិភាព ដែលបានប្ដេជ្ញាមិនជ្រៀតជ្រែកនឹងជីវភាពរស់នៅរបស់កសិករក្រីក្រ មកទល់ពេលនេះអ្នកភូមិបូកែវនៅតស៊ូប្រឆាំងនឹងបទបញ្ជាបណ្ដេញចេញនេះ។

នៅក្នុងខែមេសា ឆ្នាំ២០១៦ មានមេដឹកនាំមូលដ្ឋានម្នាក់ឈ្មោះ ខេន ខាំឡៃ បានបាត់ខ្លួន ខណៈដែលកំពុងតែប្រមូលចំណីអាហារនៅតំបន់ក្បែរផ្ទះរបស់គាត់ ហើយតាំងពីពេលនោះមកពុំមាននរណាម្នាក់ធ្លាប់បានឃើញគាត់ទៀតឡើយ។ ខេន ជាអ្នកលើកឡើងទាមទារយ៉ាងទទូចថា «យើងជាប្រជាជនក្រីក្រមិនចង់ទទួលរងការចោទប្រកាន់ ហើយក្លាយជាជនអនាថា និងត្រូវសង្គមផាត់ចេញនៅក្នុងប្រទេសរបស់យើងនោះទេ»។ ទោះបីជាប្រជាជនមូលដ្ឋាននិងប៉ូលីសបានរកឃើញនូវតំបន់ដែលបានដុតឆេះ និងមានបំណែកឆ្អឹងនៅក្នុងតំបន់ចន្លោះពីព្រៃសហគមន៍របស់ភូមិគាត់និងតំបន់អភិរក្សរបស់រដ្ឋ ដែលជាកន្លែងខេនបាត់ខ្លួននោះក៏ដោយ ក៏គ្មានការវិវឌ្ឍណាបន្ថែមទៀតដែលត្រូវបានរាយការណ៍ក្នុងការស៊ើបអង្កេតលើករណីនេះដែរ។

**ដំណើរឆ្ពោះទៅអនាគត**

នៅក្រោមរបបគ្រប់គ្រងរបស់ថៃនាពេលបច្ចុប្បន្ន ប្រជាពលរដ្ឋមានហេតុផលច្រើនជាងមុនក្នុងភាពភ័យខ្លាចថាដីនិងព្រៃរបស់ពួកគេនឹងត្រូវបានរឹបអូសយក ហើយប្រគល់ទៅឲ្យឈ្មួញធំៗ និងក្រុមផ្សេងៗទៀតដែលមានឆន្ទៈក្នុងការចែកប្រយោជន៍ជាមួយនឹងពួកយោធា។

ទោះជាយ៉ាងណាក៏ដោយ បណ្ដាញសង្គមស៊ីវិលមួយដែលមានសហគមន៍មកពីគ្រប់ទិសទីនៅក្នុងប្រទេសថៃ ដែលប្រឈមមុខនឹងបញ្ហាស្រដៀងគ្នានឹងអ្នកភូមិដែលកំពុងប្រឈមនឹងបញ្ហានៅក្នុងខេត្តផេតចាប៊ុន និងខេត្តឆៃយ៉ាភូមិដែរនោះ បានធ្វើឲ្យមានការវិវត្តខ្លះៗក្នុងការជំរុញឲ្យមានច្រកសម្រាប់ច្បាប់ថ្មីចំនួន៤ គឺច្បាប់ស្ដីពីកម្មសិទ្ធិដីសហគមន៍ ច្បាប់ស្ដីពីមូលនិធិធនាគារដី ច្បាប់ស្ដីពីមូលនិធិយុត្តិធម៌ និងច្បាប់ស្ដីពីពន្ធអាករដែលនឹងបង្កើននូវការយកពន្ធច្រើនជាងមុនពីម្ចាស់ដីដែលមិនបានប្រើប្រាស់ដីរបស់ពួកគេ។

ប្រសិនបើសំណើច្បាប់ទាំង៤ត្រូវបានអនុម័ត វានឹងជួយដោះស្រាយបញ្ហាជម្លោះដីធ្លី និងកាត់បន្ថយវិសមភាពក្នុងការកាន់កាប់ដី។ ពួកគេថែមទាំងទទួលបាននូវការស្ដាប់ពីរដ្ឋាភិបាលដោយយកចិត្តទុកដាក់និងយោគយល់ លើកលែងតែច្បាប់ស្ដីពីប្លង់កម្មសិទ្ធិដីសហគមន៍ ។ ដោយគោរពសិទ្ធិសហគមន៍លើការកាន់កាប់ដីធ្លី រដ្ឋាភិបាលបានអនុម័តសំណើដោយរឹតត្បិតលើចំនុចដែលពាក់ព័ន្ធនឹងការគ្រប់គ្រងដីធ្លីដោយសហករណ៍ហើយ និងមិនទទួលស្គាល់នូវសិទ្ធិសហគមន៍នៅក្នុងតំបន់ឧទ្យានជាតិ ឬក៏តំបន់អភិរក្សសត្វព្រៃឡើយ។

***អូរ៉ាណុច ផុនពីញ៉ូ (Oranuch Phonpinyo )*** *(lumnampasak5748(at)gmail.com)*
បណ្ដាញកំណែទម្រង់ដីធ្លីភូមិភាគឥសាន (Northeastern Land Reform Network) ប្រទេសថៃ

សម្រាប់ព័ត៌មានបន្ថែម៖

(១) មូលនិធិស្ថាប័នដីធ្លីនៃប្រទេសថៃ (The Land Institute Foundation of Thailand)

(២) សិទ្ធិពលរដ្ឋថៃ និងសារព័ត៌មានបែបស៊ើបអង្កេត៖ http://prachatai.org/english/category/news

*(៣) សារព័ត៌មានប្រាចាថៃ (Prachatai News)* ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣៖ http://prachatai.com/journal/2013/05/46764

# ប្រទេសមីយ៉ាន់ម៉ា៖ គោលនយោបាយថ្មីដើម្បីលើកកម្ពស់ សិទ្ធិជនជាតិដើមភាគតិចកំពុងតែទទួលរងនូវការគំរាមកំហែង

ពីរឆ្នាំកន្លងទៅនេះ គឺជាអំឡុងពេលដែលមានការផ្លាស់ប្តូរដ៏គួរឲ្យកត់សម្គាល់នៅក្នុងប្រទេសមីយ៉ាន់ម៉ា ពោលគឺអ្វីដែលគួរឲ្យកត់សម្គាល់ខ្លាំងបំផុតនោះគឺជាជ័យជំនះរបស់សម្ព័ន្ធប្រជាធិបតេយ្យជាតិ (អ៊ែនអ៊ែលឌី) (១) នៅក្នុងការបោះឆ្នោតកាលពីខែវិច្ឆិកា ឆ្នាំ២០១៥។ ការដាក់ចេញនៅគោលនយោបាយជាតិថ្មីមួយស្តីពីការប្រើប្រាស់ដីធ្លី (NLUP) នៅប្រទេសមីយ៉ាន់ម៉ាកាលពីខែមករា ឆ្នាំ២០១៦ ជារឿងដ៏សំខាន់ពិតប្រាកដមួយដែលមានការរាយការណ៍តិចតួចណាស់ចេញទៅខាងក្រៅប្រទេសមីយ៉ាន់ម៉ា។ គោលនយោបាយនេះត្រូវបានដាក់ចេញជាផ្នែកមួយនៃគំនិតផ្តួចផ្តើមស្តីពីគោលនយោបាយធំចុងក្រោយមួយរបស់រដ្ឋបាលចាញ់ឆ្នោត មុនពេលដែលអំណាចត្រូវបានផ្ទេរទៅឲ្យរដ្ឋបាលសម្ព័ន្ធប្រជាធិបតេយ្យជាតិ (NLD) ដែលបានចូលកាន់អំណាចកាលពីខែមេសាឆ្នាំ២០១៦។ គោលនយោបាយនេះទៀតសោតគឺជាលទ្ធផលនៃដំណើរការនៃការពិគ្រោះយោបល់ និងការពិនិត្យសារឡើងវិញអស់រយៈពេលដ៏យូរមិនធ្លាប់មានពីមុនមក ដែលដំណើរការនេះមួយភាគធំគឺត្រូវបានគ្រប់គ្រងត្រួតពិនិត្យដោយអតីតក្រសួងបរិស្ថាន អភិរក្ស និងព្រៃឈើ ដែលស្ថិតក្រោមការការគាំទ្រពីស្ថាប័នអន្តរក្រសួង ដែលបានបង្កើតឡើងដោយអនុប្រធានាធិបតី។ ដោយពុំធ្លាប់ឃើញមានបែបនេះនៅក្នុងដំណើរអភិវឌ្ឍបង្កើតគោលនយោបាយផ្សេងៗទៀត គោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី (NLUP) ត្រូវបានធ្វើកំណត់ត្រាថា មានការពិគ្រោះយោបល់ជាមួយសាធារណជនយ៉ាងហោចណាស់ចំនួន៩១ដង រួមបញ្ចូលទាំង១៧ដងគឺជាការពិគ្រោះយោបល់ដែលដឹកនាំធ្វើដោយរដ្ឋាភិបាល និងយ៉ាងហោចណាស់៧៤ដងគឺដឹកនាំធ្វើដោយអង្គការសង្គមស៊ីវិលមកពីជាង៤០ក្រុង ហើយរាប់បញ្ចូលទាំងសិក្ខាសាលាពិគ្រោះយោបល់ ថ្នាក់ជាតិធំៗចំនួន៤ដងផ្សេងទៀត។ (២) គោលនយោបាយនេះមានទស្សនៈវិស័យក្នុងការដើរតួនាទីជាឯកសារមគ្គុទេសក៍នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីភូមិបាលជាតិ និងនៅក្នុងការធ្វើកំណែទម្រង់លើច្បាប់ដែលមានស្រាប់ ដូចជាច្បាប់ស្តីពីការទទួលបានដីឆ្នាំ១៨៩៤ ដែលហួសសម័យឬជាច្បាប់ចាស់ ហើយនៅឆ្នាំ២០១២ ច្បាប់គ្រប់គ្រងដីទំនេរ ដីទុកចោល និងដីដែលមិនទាន់ប្រើប្រាស់ ដែលជាគោលការណ៍ច្បាប់សម្រាប់សម្របសម្រួលសម្រាប់បែងចែកដីប្រពៃណីដូនតារបស់ជនជាតិភាគតិចទៅឲ្យវិនិយោគគិន។

ជាលទ្ធផល ឯកសារគោលនយោបាយដែលបានសម្រេច គឺជាឯកសារសម្របសម្រួលមួយមាន១៣ផ្នែកសំខាន់ៗ ដែលសរសេរបង្ហាញអំពីគោលនយោបាយរបស់រដ្ឋាភិបាលចំពោះគម្រោងកម្មវិធីផ្សេងៗគ្នា។ ទាំងនេះរួមបញ្ចូលទាំងផ្នែកដែលមានលក្ខណៈទូលំទូលាយមួយចំនួនដូចជារដ្ឋបាលនៃការប្រើប្រាស់ដី និងការរៀបចំផែនការសម្រាប់ប្រើប្រាស់ដី និងផ្នែកដែលមានលក្ខណៈជាក់លាក់ជាងនេះ ដែលផ្តោតលើការផ្តល់សម្បទានដីរបស់រដ្ឋ នីតិវិធីពាក់ព័ន្ធនឹងការទទួលបានដី និងសំណងលើការតាំងទីលំនៅថ្មី ពន្ធអាករ

ការពិនិត្យនិងវាយតម្លៃដី និងអ្វីដែលសំខាន់បំផុតនោះគឺសិទ្ធិក្នុងការប្រើប្រាស់ដីរបស់ជនជាតិភាគតិច និងសិទ្ធិស្មើគ្នារបស់ស្ត្រីនិងបុរស។ គោលនយោបាយនេះបានទទួលរងការរិះគន់ពីសកម្មជនដីធ្លីមួយចំនួន ដោយសារតែវាមិនមានលក្ខណៈស៊ីជម្រៅគ្រប់គ្រាន់ក្នុងការបញ្ឈប់ការធ្វើសម្បទានដី និងការវិនិយោគទុនពាក់ព័ន្ធនឹងដីធ្លី។ ប៉ុន្តែ គោលនយោបាយនេះក៏មានសារៈសំខាន់ដែរក្នុងការដែលវាបានផ្តល់នូវការកំណែទម្រង់ដ៏សំខាន់មួយចំពោះអភិបាលកិច្ចដីធ្លី ដែលប៉ុនប៉ងដាក់ចេញនូវបទបញ្ញត្តិ បទបញ្ជាហាមឃាត់ និងស្នើជាដំណោះស្រាយតាមបែបគោលនយោបាយ ចំពោះជម្លោះជាច្រើនក្នុងពេលបច្ចុប្បន្នជុំវិញបញ្ហាដីធ្លី រួមបញ្ចូលទាំងការដណ្តើមដីធ្លី និងការផ្ទេរកម្មសិទ្ធិដីពីសម្បទាន និងការជួលដីពីរដ្ឋដែលជាដីប្រពៃណីដូនតារបស់ក្រុមជនជាតិភាគតិចមួយចំនួន។ ជាការពិត គេអាចនិយាយបានថាគោលនយោបាយនេះគឺជាការផ្លាស់ប្តូរដ៏គួរឲ្យកត់សម្គាល់មួយពីក្របខណ្ឌការងារនៃអភិបាលកិច្ចដីធ្លីតាមខ្សែបណ្តោយពីលើចុះក្រោមរបស់ប្រទេសមីយ៉ាន់ម៉ា។ ប្រសិនបើមានការអនុវត្តតាមច្បាប់នេះពិតមែន ការទទួលស្គាល់យ៉ាងម៉ឺងម៉ាត់ចំពោះការ កាន់កាប់ដីប្រពៃណីដូនតានឹងដាក់ឲ្យប្រទេសមីយ៉ាន់ម៉ានៅដាច់ផ្សេងពីប្រទេសជិតខាងមួយចំនួន ដែលផ្តាច់ការជាងខ្លួនដូចជា វៀតណាម កម្ពុជា និងឡាវជាដើម។

គោលនយោបាយនេះមានតម្លៃគួរឲ្យកត់សម្គាល់នៅត្រង់វាមានចែងនូវគោលការណ៍មូលដ្ឋានគ្រឹះដូចជា៖ « ដើម្បីទទួលស្គាល់តាមផ្លូវច្បាប់ និងដើម្បីការពារសិទ្ធិកាន់កាប់ ដូចដែលបានទទួលស្គាល់ដោយសហគមន៍មូលដ្ឋាន ដោយផ្តោតយកចិត្តទុកដាក់ជាពិសេសទៅលើក្រុមដែលងាយរងគ្រោះ ដូចជាកសិករខ្នាតតូច ជនក្រីក្រ ជនជាតិភាគតិច និងស្ត្រី»។ អ្វីដែលគួរឲ្យកត់សម្គាល់ខ្លាំងបំផុតនោះគឺ ថានេះជាលើកទីមួយហើយដែលគោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី (NLUP) មានគោលបំ ណងទទួលស្គាល់និងការពារអំណះអំណាងការកាន់កាប់ដីប្រពៃណីដូនតានិងដីសហគមន៍។ នៅក្នុងករណីនេះ ផ្នែកទី៨និយាយអំពីសិទ្ធិប្រើប្រាស់ដីធ្លីសម្រាប់ជនជាតិភាគតិចគឺជាផ្នែកមួយដែលមានសារៈសំខាន់បំផុត ដែលវាផ្តោតទាំងស្រុងទៅលើការទទួលស្គាល់និងការពារដីប្រពៃណីដូនតាដែលកាន់កាប់ដោយក្រុម ជនជាតិភាគតិចនៅក្នុងប្រទេសមីយ៉ាន់ម៉ា។ មាត្រា៦៤បានចែងថា «ប្រព័ន្ធកាន់កាប់ប្រើប្រាស់ដីប្រពៃ ណីដូនតាគួរតែត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ភូមិបាលជាតិ ដើម្បីធានាថាមានការយល់ដឹង ការអនុលោមតាមនិងការអនុវត្តលើការប្រើប្រាស់ដីតាមបែបប្រពៃណីរបស់ជនជាតិភាគតិច មានការទទួលស្គាល់ជាផ្លូវការនូវសិទ្ធិប្រើប្រាស់ដីប្រពៃណីដូនតា មានការការពារសិទ្ធិទាំងនេះ និងការអនុវត្តលើយន្តការដោះស្រាយវិវាទដែលមានស្រាប់ និងមិនលម្អៀង»។

ផ្នែកស្តីពីសិទ្ធិដីធ្លីរបស់ជនជាតិភាគតិចនៅបន្តនិយាយក្នុងរបៀបដូចខាងលើ។ នៅក្នុងមាត្រាទាំង១១ផ្នែកនេះ មានការទទួលស្គាល់នូវការអនុវត្តការគ្រប់គ្រងដីប្រពៃណីដូនតា មានការការពារដីរបស់ជនជាតិភាគតិច ពីការបែងចែកដីសម្រាប់ធ្វើជាដីសម្បទាន មានការទទួលស្គាល់និងការការពារប្រព័ន្ធធ្វើស្រែចម្ការវិលជុំ មានការទទួលស្គាល់នូវភាពចាំបាច់នៃការចូលរួមដ៏ពិតប្រាកដរបស់ជនជាតិភាគតិច នៅក្នុងការធ្វើការសម្រេចចិត្តទាក់ទិននឹងដីរបស់ពួកគេ ការទទួលស្គាល់នូវសារៈសំខាន់នៃនីតិវិធីដោះស្រាយជម្លោះដីប្រពៃណីដូនតា និងមានដាក់ចេញនូវគោលការណ៍មូលដ្ឋានគ្រឹះមួយចំនួនសម្រាប់ដោះស្រាយជម្លោះដីធ្លី និងការបាត់បង់លំនៅដ្ឋានរបស់ប្រជាជនដែលមានលក្ខណៈជាប្រវត្តិសាស្ត្រ។ ប្រសិនបើអនុវត្តតាមច្បាប់ ការផ្លាស់ប្តូរទាំងនេះគឺនឹង

តំណាងឲ្យការប្រាសចាកពីការអនុវត្តការគ្រប់គ្រងនាពេលបច្ចុប្បន្ន តាមបែបពីលើចុះមកក្រោមនាពេលបច្ចុប្បន្ន ទៅលើដីប្រពៃណីនៅក្នុងប្រទេសមីយ៉ាន់ម៉ា។

សំខាន់ជាងនេះទៅទៀត ផ្នែកទី៩នៃគោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី (NLUP) មានជំពូកមួយផ្តោតជាពិសេសទៅលើសិទ្ធិស្មើគ្នារបស់បុរសនិងស្ត្រី ដាក់បញ្ចូលបន្ទាប់ពីមានការពិភាក្សាដេញដោលជាច្រើន និងការបញ្ចុះបញ្ចូលពីក្រុមសង្គមស៊ីវិលដែលធ្វើការលើបញ្ហាសមភាពយេនឌ័រនៅមូលដ្ឋាន ក្នុងប្រទេសមីយ៉ាន់ម៉ា។ ស្ត្រី គឺជាក្រុមមិនសូវទទួលបានប្រយោជន៍ដែលអាចកត់សម្គាល់បាននៅក្នុងប្រទេសមីយ៉ាន់ម៉ា។ នេះគឺជាការពិតជាពិសេសពាក់ព័ន្ធនឹងដីធ្លី ដែលភាគច្រើនឃើញតែបុរសជាអ្នកឈរឈ្មោះ រីឯស្ត្រីវិញមិនត្រូវបានដាក់បញ្ចូលនៅក្នុងឯកសារចុះឈ្មោះដីធ្លីទេ។ (៣) ផ្នែកទី៩នៃគោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី (NLUP) មិនទូលំទូលាយនោះទេ ដោយមានតែពីរមាត្រាប៉ុណ្ណោះ។ ប៉ុន្តែមាត្រា៧៥ បានបង្ហាញពីសិទ្ធិកាន់កាប់ដីជាក់លាក់ចំនួន៨ចំណុច ដែលគួរតែផ្តល់ដល់ស្ត្រី។ ទាំងនេះរួមបញ្ចូលទាំងសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិជាលក្ខណៈបុគ្គល ឬក៏មានកម្មសិទ្ធិរួមគ្នា សិទ្ធិកាន់កាប់ដីធ្លីនៅពេលដែលប្រពន្ធឬប្តីស្លាប់ ឬក៏នៅពេលដែលទ្រព្យសម្បត្តិត្រូវបានបែងចែងក្នុងករណីលែងលះគ្នា និងសិទ្ធិក្នុងការចូលរួមនិងជាតំណាងរបស់សហគមន៍នៅពេលដែលធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងដីធ្លី។

គោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី (NLUP) ឆ្នាំ២០១៦ ហាក់ដូចជាតំណាងឲ្យការផ្លាស់ប្តូរដ៏សំខាន់មួយរបស់ប្រទេសក្នុងការឆ្ពោះទៅរកប្រព័ន្ធអភិបាលកិច្ចដែលមានការចូលរួម និងមានលក្ខណៈប្រជាធិបតេយ្យជាងមុន ដែលមានការគោរពសិទ្ធិរបស់សហគមន៍ជនជាតិភាគតិច និងសហគមន៍នៅជនបទដែលបានធ្វើការប្តឹងផ្តល់តាំងពីយូរមកហើយចំពោះការដណ្តើមដីធ្លីដែលមានការគាំទ្រពីរដ្ឋ។ ទោះជាយ៉ាងនេះក្តី កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ប្រហែលជា១០ខែបន្ទាប់ពីគោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី (NLUP)បានចេញ មានគណកម្មការមួយដែលមិនមានអ្នកស្គាល់ ប៉ុន្តែមានឥទ្ធិពលខ្លាំងនៅក្នុងសភាជាតិដែលត្រូវគេស្គាល់ថាជា *គណៈកម្មការពិសេសដើម្បីវិភាគលើច្បាប់និងបញ្ហាពិសេសៗ* (ពីពេលនេះតទៅគឺហៅថាគណៈកម្មការពិសេស) បានដាក់ជូននូវឯកសារស្តីពីក្របខណ្ឌប្រតិបត្តិការងារមួយទៅសភា។ បន្ទាប់ពីយោងតាមមាត្រា៣៧នៃរដ្ឋធម្មនុញ្ញឆ្នាំ២០០៨ ឯកសារនេះបានព្រាងដោយពួកយោធា ដែលប្រកាសថារដ្ឋគឺជាជាម្ចាស់ដើមលើធនធានធម្មជាតិ ទាំងលើនិងក្រោមដី បានលើកឡើងថាគោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី (NLUP) មាន «ការពិតដែលមិនសមនិងមិនពាក់ព័ន្ធ» ចំនួន៦ចំណុច ដែលគួរតែដកចេញពីឯកសារនេះ និង «គួរតែដាក់បន្ថែមនូវចំណុចដែលចាំបាច់» ចំនួន៦ចំណុចវិញ។

ដើម្បីរក្សាជាការសំងាត់របស់គណៈកម្មការពិសេសដោយចំហ(៤) ឯកសារក្របខណ្ឌប្រតិបត្តិការងារនេះមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឡើយ ទោះបីជាត្រូវបានដាក់ជូនទៅសភាជាតិរួចទៅហើយក្តី។ ជាការពិតមានតែសហគមន៍ដែលមានកំណែទម្រង់ដីធ្លីប៉ុណ្ណោះទើបបានដឹងថាមានឯកសារនេះ តាមរយៈការលើកឡើងយ៉ាងខ្លីមួយនៅក្នុងកាសែតជាភាសាអង់គ្លេសដែលមានឈ្មោះថាមីយ៉ាន់ម៉ាថៃមស៍ (the Myanmar Times) ជាច្រើនសប្តាហ៍ក្រោយមកដែលត្រូវបានជំរុញឲ្យមានការស៊ើបអង្កេតបន្ថែមទៀតពីសំណាក់ភ្នាក់ងារ

ម្ចាស់ជំនួយ។ ឯកសារនេះត្រូវបានចុះហត្ថលេខាដោយ យូ ស្វី ម៉ាន់ (U Shwe Mann) ដែលជាប្រធានរបស់គណៈកម្មការ និងជាអ្នកនយោបាយដែលមានអំណាចសំខាន់មួយរូបនៅក្នុងរដ្ឋាភិបាល។ អតីតមេទ័ពម្នាក់ប្រធានគណបក្សកាន់អំណាចកាលពីអាណត្តិមុនគឺគណបក្សយូអ៊ែសឌីភី (USDP party) និងអ្នកនាំពាក្យរបស់សភាជាន់ទាបនៃសភាជាតិ ដែលស្ថិតក្រោមរដ្ឋបាលអាណត្តិមុន យូ ស្វី ម៉ាន់ និងគ្រួសាររបស់គាត់បានរក្សានូវប្រយោជន៍សេដ្ឋកិច្ចដ៏គួរឲ្យកត់សម្គាល់នៅទូទាំងប្រទេស រួមបញ្ចូលទាំងការវិនិយោគលើកសិពាណិជ្ជកម្ម។ (៥) ជា ពិសេស យូ ស្វី ម៉ាន់ ត្រូវបានចាត់ទុកថាជាបក្សពួកយ៉ាងជិតស្និទ្ធរបស់ថ្នាក់ដឹកនាំសម្ព័ន្ធជាតិប្រជាធិបតេយ្យ (អ៊ែនអ៊ែលឌី) និងសមាជិកក្រុមប្រឹក្សារដ្ឋ ដអ៊ុងសានស៊ូជី (Daw Aung San Suu Kyi)។ ជាការពិតណាស់ កាលពីឆ្នាំ២០១៥ រឿងទាំងនេះត្រូវបានរាយការណ៍យ៉ាងទូលំទូលាយនៅក្នុងសារព័ត៌មានថា យូ ស្វី ម៉ាន់ ត្រូវបានកម្ចាត់ចេញពីគណបក្សនយោបាយយូអ៊ែសឌីភី (USDP) អាណត្តិមុនដោយសារតែមានភាពជិតស្និទ្ធ ពេកជាមួយនឹងថ្នាក់ដឹកនាំរបស់អ៊ែនអ៊ែលឌី (NLD)។ ខណៈដែល យូ ស្វី ម៉ាន់ (U Shwe Mann) បានបាត់បង់នូវអាសនៈរបស់គាត់ក្នុងការបោះឆ្នោតកាលពីឆ្នាំ២០១៥នោះ គាត់ក៏ត្រូវបានតែងតាំងដោយសមាជិក្រុមប្រឹក្សារដ្ឋ ក្លាយជាគណកម្មការពិសេសដែលមនុស្សមួយចំនួនបានមើលឃើញថានេះគឺជាការផ្តល់នូវរង្វាន់មួយសម្រាប់ការគាំទ្រ ដ ស៊ូជី (Daw Suu Kyi) ក្នុងចេតនាចង់ឲ្យមានការធ្វើកំណែទម្រង់រដ្ឋធម្មនុញ្ញនៅក្នុងអាណត្តិមុន។ (៦)

បើមើលលើចំណុចទាំង៦ដែលបានដាក់ជា «ការពិតដែលមិនសម និងមិនពាក់ព័ន្ធដែលគួរតែត្រូវដកចេញឃើញថា ចំណុចទីមួយនិងចំណុចចុងក្រោយប្រហែលជាចំណុចដែលមានភាពចម្រូងចម្រាសតិចតួចជាងគេ ដែលសំដៅលើការបង្កើតនូវស្ថាប័នគ្រប់គ្រងព័ត៌មានដីធ្លីមួយ និងការដកចេញនូវសេចក្តីយោងមួយពីការធ្វើការពិនិត្យឡើងវិញរៀងរាល់៥ឆ្នាំលើឯកសារគោលនយោបាយ។ ចំណុចទីមួយដែលត្រូវបានដាក់ជាចំណុចយោងនៅក្នុងលិខិតបង្កើតកិច្ចប្រតិបត្តិការងារនោះ គឺសំដៅលើមាត្រា១៨នៃគោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី (NLUP) ដែលស្នើឲ្យមានស្ថាប័នមួយដែល «ធ្វើការតែលើ» ការគ្រប់គ្រងព័ត៌មានដីធ្លីនៅក្នុងទូទាំងប្រទេសប៉ុណ្ណោះ។ រីឯគណកម្មការពិសេសវិញ ដែលបានផ្តល់ជាអនុសាសន៍ប្រឆាំងមិនគាំទ្រឲ្យមានស្ថាប័នប្រភេទនេះទេហាក់ដូចជាពុំបានដឹងទាល់តែសោះថា ស្ថាប័នបែបនេះគឺមានស្រាប់ទៅហើយក្នុងទម្រង់នៃគម្រោងផែនទីមួយនៃមីយ៉ាន់ម៉ា ដែលមានបំណងធ្វើការចងក្រងនូវព័ត៌មាន និងទិន្នន័យដីធ្លីពីក្រសួងពាក់ព័ន្ធផ្សេងៗ។ (៧) នៅចំណុចចុងក្រោយ គណកម្មការពិសេសបានអះអាងថា ការធ្វើបច្ចុប្បន្នភាពតាមកាលកំណត់មួយលើគោលនយោបាយ ទាមទារឲ្យមាននូវការធ្វើបច្ចុប្បន្នភាពតាមកាលកំណត់នេះគឺមិនអាចធ្វើបានឡើយ បើទោះបីជាហេតុផលនៃគំនិតនេះមិនត្រូវថែងទុកក្តី។ ដោយមើលពីសារៈសំខាន់លើគោលនយោបាយដីធ្លី និងស្ថានភាពដែលមានការប្រែប្រួលឥតឈប់ឈរនាពេលបច្ចុប្បន្នក្នុងប្រទេសមីយ៉ាន់ម៉ា វាហាក់ដូចជាមានមូលហេតុពេញលេញក្នុងការពិនិត្យឡើងវិញទាំងលើច្បាប់ និងគោលនយោបាយដីធ្លីរៀងរាល់៥ឆ្នាំម្តង។

បញ្ហាទីពីរដែលគណកម្មការពិសេសបានកំណត់ឲ្យដកចេញនោះ គឺសំដៅលើការដកចេញនូវសេចក្តីយោងពីការបង្កើតនូវតុលាការពិសេសមួយ និងដំណើរការរបស់អាជ្ញាកណ្តាលត្រីភាគីឯក រាជ្យដើម្បីដោះស្រាយទំនាស់ដីធ្លី។ ប្រព័ន្ធនីតិវិធីបណ្តឹងឯករាជ្យមួយបែបនេះ ត្រូវបានស្នើឡើងយ៉ាងជាក់ច្បាស់នៅក្នុងមាត្រា៤២

នៃគោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី ពីព្រោះក្របខណ្ឌការងារច្បាប់បច្ចុប្បន្នមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាវិវាទដីធ្លីជាច្រើន។ នៅក្នុងក្របខណ្ឌការងារច្បាប់នាពេលបច្ចុប្បន្ននេះ គឺគ្មានការទទួលស្គាល់ដីសមូហភាពរបស់សហគមន៍ ភាពជាម្ចាស់លើដីប្រពៃណីដូនតា ឬក៏ការធ្វើចម្ការវិលជុំឡើយ ហើយជាក់ស្តែង អ្វីដែលបានលើកឡើងខាងលើនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងដីទំនេរ ដីទុកចោល និងដីមិនទាន់ប្រើប្រាស់ឆ្នាំ២០១២នោះ បច្ចុប្បន្ននេះបានដាក់ឲ្យស្របច្បាប់នូវការផ្តល់ដីសមូហភាពប្រពៃណី និងដីទំនេរទៅឲ្យវិនិយោគិនឯកជន។ ដោយការកំណត់ឲ្យដកស្ថាប័នអាជ្ញាកណ្តាលឯករាជ្យ (ទោះបីជាមិនទាន់បានបង្កើតឡើងនៅឡើយក្តី)គណកម្មការពិសេសហាក់ដូចជាបានធ្វើសារបញ្ជាក់យ៉ាងច្បាស់មួយរួចជាស្រេចថាស្ថានភាពនៃការក្តោបក្តាប់ដីរបស់រដ្ឋគួរតែបន្តតាមបែបនោះដដែរ។

បញ្ហាទីបីដែលត្រូវកំណត់ឲ្យដកចេញដោយគណកម្មការពិសេសនោះ គឺប្រហែលជាអ្វីដែលគួរឲ្យព្រួយបារម្ភជាងគេបំផុតពោលគឺការដកផ្នែកទី៨ចេញទាំងស្រុង ដែលចែងពីសិទ្ធិដីធ្លីរបស់ជនជាតិភាគតិច ដូចបានពន្យល់នៅផ្នែកខាងលើ ផ្នែកទី៨គឺជាជំពូកសំខាន់នៅក្នុងគោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី (NLUP) ដែល ផ្តល់នូវការណែនាំយ៉ាងច្បាស់អំពីការផ្តល់នូវសន្តិសុខដល់ការកាន់កាប់លើប្រព័ន្ធកម្មសិទ្ធិដីធ្លីក្រៅផ្លូវការ និង ការរៀបចំកាន់កាប់ដីសមូហភាពប្រពៃណី ព្រមទាំងប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិដែលបច្ចុប្បន្ននេះវាមានភាពគ្របដណ្តប់លើអភិបាលកិច្ចដីធ្លីរបស់ជនជាតិភាគតិចនៅក្នុងមីយ៉ាន់ម៉ា ជាពិសេសសម្រាប់អ្នកដែលរស់នៅតំបន់ភ្នំនៃប្រទេសមីយ៉ាន់ម៉ា។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះ គឺគណកម្មការពិសេសបានលើកហេតុផលពីការដកផ្នែកទី៨ ចេញពីការអនុវត្តថាច្បាប់បច្ចុប្បន្ននេះ (ជាពិសេសច្បាប់ស្តីពីដីធ្លី និងចំណូល ច្បាប់ស្តីពីភូមិនិងក្រុង ច្បាប់ស្តីពីការគ្រប់គ្រងដីទំនេរ ដីទុកចោល និងដីមិនទាន់បានប្រើប្រាស់ និងច្បាប់ស្តីពីដីកសិកម្ម និងច្បាប់ព្រៃឈើ បានគោរពតាមសិទ្ធិទំនៀមទម្លាប់រួចហើយ ហើយទាំងនេះជាក់ស្តែងត្រូវបានគ្រប់គ្រងចាត់ចែងដោយនាយកដ្ឋានទទួលបន្ទុក។ ប៉ុន្តែពាក្យថា «ទំនៀមទម្លាប់» និង «ប្រពៃណី» មិនមានឃើញលេចឡើងសូម្បីតែមួយនៅក្នុងច្បាប់ស្តីពីព្រៃឈើ (១៩៩២) ច្បាប់ស្តីពីដីកសិកម្ម (២០១២) ឬនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងដីទំនេរ ដីទុកចោល និងដីដែលមិនទាន់បានប្រើប្រាស់។ ជាងនេះទៅទៀត ច្បាប់ស្តីពីការគ្រប់គ្រងដីទំនេរ ដីទុកចោលនិងដីដែលមិនទាន់បានប្រើប្រាស់ ត្រូវបានរិះគន់ដោយក្រុមអ្នកធ្វើការលើសិទ្ធិជនជាតិភាគតិចភាគច្រើនថា ជាវិធីសាស្ត្រគោលមួយដែលរដ្ឋរបស់មីយ៉ាន់ម៉ាបច្ចុប្បន្នកំពុងតែសម្របសម្រួលឲ្យមានការផ្ទេរពីដីប្រពៃណីរបស់ជនជាតិភាគតិច និងធនធានធម្មជាតិទៅឲ្យវិនិយោគិនឯកជនក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍។ នេះជាប្រភពចំបងមួយនៃទំនាស់រវាងរដ្ឋាភិបាលសហភាពមីយ៉ាន់ម៉ា និងក្រុមជនជាតិភាគតិច។ លើសពីនេះទៅទៀត ជំពូកទី៨គឺជាផ្នែកតែមួយគត់នៅក្នុង គោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី (NLUP) ដែលបានអំពាវនាវជាពិសេសឲ្យមានច្បាប់ភូមិបាលថ្មីមួយ ដែលទទួលស្គាល់នូវការកាន់កាប់ដីតាមទំនៀមទម្លាប់ និងផ្តល់នូវមធ្យោបាយក្នុងការចុះបញ្ជីក្នុងការរៀបចំកាន់កាប់ដីប្រពៃណីបច្ចុប្បន្នជាផ្លូវការតាមច្បាប់។ ការដកជំពូកទី៨ចេញ នឹងធ្វើឲ្យមានការរាំងស្ទះយ៉ាងខ្លាំងដល់ការរៀបចំការកាន់កាប់ដីប្រពៃណីរបស់ក្រុមជនជាតិភាគតិច ដោយសារតែមិនបានគិតគូរពីជីវភាពរស់នៅជាក់លាក់ និងប្រព័ន្ធអភិបាលកិច្ចដីធ្លីរបស់ពួកគេ។

ចំពោះការការពារនិងការទទួលស្គាល់នូវការធ្វើចម្ការវិលជុំវិញ គឺជាគោលដៅក្នុងការដកចេញស្រដៀង

គ្នាដែរ ដោយគណកម្មការពិសេស ដោយលើកឡើងថាការអនុវត្តប្រព័ន្ធកសិកម្មបែបប្រពៃណីរបស់ក្រុមជនជាតិភាគតិចនៅតំបន់ភ្នំ «ធ្វើឲ្យបរិស្ថានធម្មជាតិត្រូវបំផ្លាញខ្លាំងឡើងៗ»។ គណកម្មការនេះបានធ្វើការតស៊ូមតិឲ្យមានការផ្លាស់ប្តូរប្រព័ន្ធនេះ «ជំនួសដោយការអនុវត្តធ្វើស្រែតាមបែបទំនើប ដូចជាការធ្វើស្រែនៅលើភ្នំ ការធ្វើស្រែនៅតាមជម្រាលភ្នំ និងការធ្វើកសិកម្មដាំដុះដើមឈើព្រៃ ។ ការអំពាវនាវឲ្យដកចេញនូវសេចក្តីយោងនានាដែលការពារដល់ប្រព័ន្ធធ្វើកសិកម្មដាំដុះដើមឈើព្រៃបែបប្រពៃណីនេះ បានបង្ហាញពីចំនុចខ្សោយក្នុងការយល់ដឹងអំពីភាពស្មុគ្រស្មាញនៃការរៀបចំការកាន់កាប់ដីនៅក្នុងតំបន់ជនបទរបស់ប្រទេស។ ការដកចេញនេះហាក់ដូចជា មានគោលបំណងរក្សាទុកគោលនយោបាយលុបបំបាត់ចោលនូវការធ្វើចម្ការវិលជុំដែលមានស្រាប់ហើយអនុវត្តមិនបានជោគជ័យទេនៅក្នុងប្រទេសមីយ៉ាន់ម៉ា និងក្នុងតំបន់ទាំងមូល។ ជីវភាពរស់នៅរបស់ជនជាតិភាគតិច ជាពិសេសអ្នកដែលរស់នៅតំបន់លើភ្នំនៃប្រទេសមីយ៉ាន់ម៉ា បច្ចុប្បន្ននេះមានភាពងាយរងគ្រោះខ្លាំង ដោយសារតែមានស្ថានភាពអសន្តិសុខយ៉ាងខ្លាំងចំពោះការកាន់កាប់ដីធ្លីនៅក្នុងតំបន់ទាំងនោះ ដែលមិនបានគិតគូរពីដីប្រពៃណីរបស់ពួកគេ និងប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិ។ សព្វថ្ងៃនេះប្រព័ន្ធបែបនេះមិនត្រូវបានទទួលស្គាល់ ឬការពារនៅក្នុងច្បាប់របស់មីយ៉ាន់ម៉ាឡើយ ហើយជំពូកទី៨នៃគោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី (NLUP)ដែលពាក់ព័ន្ធវិញ មិនត្រឹមតែផ្តល់នូវទិសដៅជារួមមួយសម្រាប់ការបង្កើតនូវក្របខណ្ឌការងារស្តីពីអភិបាលកិច្ចដីធ្លីនាពេលអនាគតជុំវិញបរិបទជាក់លាក់របស់ជនជាតិភាគតិចដែលជាអ្នករស់នៅក្នុងតំបន់លើភ្នំ ថែមទាំងផ្តោតលើសិទ្ធិកាន់កាប់ដីធ្លីតាមបែបទំនៀមទម្លាប់ដូនតាដែរ។ ការទាមទារឲ្យដកចេញនូវសេចក្តីយោងនានាក្នុងការការពារនិងការទទួលស្គាល់នូវប្រព័ន្ធធ្វើចម្ការវិលជុំ ក៏ដូចជាការលុបចោលនូវសិទ្ធិដីធ្លីរបស់ជនជាតិភាគតិច អាចនឹងត្រូវបានយល់ឃើញថាជាទង្វើក្បត់មួយទៅលើដំណើរការពិគ្រោះយោបល់ដែលមានលក្ខណៈចូលរួម និងបើកចំហអំពីគោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី (NLUP) ដែលបានធ្វើឡើងអស់រយៈពេលយូរឆ្នាំមកហើយ។ បន្ថែមពីនេះទៅទៀត យោងតាមកិច្ចសម្ភាសជាមួយអ្នកសង្កេតការណ៍នៅមីយ៉ាន់ម៉ាដោយក្រុមអ្នកស្រាវជ្រាវនៅមូលដ្ឋានរបស់ចលនាព្រៃស្រោងពិភពលោក (WRM) បានឲ្យដឹងថាការផ្លាស់ប្តូរបែបនេះបង្ក ឲ្យមានហានិភ័យធំមួយក្នុងការបំផ្លាញទំនុកចិត្តរវាងអង្គការសង្គមស៊ីវិលរបស់ជនជាតិភាគតិច និងអ្នកតំណាងក្រុមជនជាតិភាគតិចប្រដាប់អាវុធ ដែលបច្ចុប្បន្ននេះកំពុងតែធ្វើការជាមួយនឹងរដ្ឋាភិបាលមីយ៉ាន់ម៉ាដើម្បីចរចាឲ្យមានកិច្ចព្រមព្រៀងសន្តិភាព និងបទឈប់បាញ់នៅទូទាំងប្រទេសលើជម្លោះមិនឈប់ឈរដែលញាំញីប្រទេសមីយ៉ាន់ម៉ាក្នុងរយៈពេល៥ទៅ៦ទសវត្សចុងក្រោយនេះ។ ការផ្លាស់ប្តូរនេះក៏រឹតតែស្តែងឲ្យឃើញថាសេចក្តីថ្លែងជាសាធារណៈ សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សអ៊ែនអែលឌី (NLD) បានធ្វើការប្តេជ្ញា «ដោះស្រាយបញ្ហារវាងក្រុមជនជាតិភាគតិចតាមរយៈកិច្ចសន្ទនាដែលប្រកបដោយការគោរពគ្នាទៅវិញទៅមក»។ (៨)

ប្រសិនបើការអំពាវនាវឲ្យដកចេញនូវសិទ្ធិដីធ្លីរបស់ជនជាតិភាគតិចនិងសេចក្តីយោង ដែលការពារនិងទទួលស្គាល់នូវការធ្វើចម្ការវិលជុំ មិនទាន់អាក្រក់ណាស់ណាទេនោះ ជំហានបន្ទាប់ទៀតគឺគណកម្មការ នឹងអំពាវនាវ ឲ្យដកចេញនូវសេចក្តីយោងទាំងឡាយណាដែលពាក់ព័ន្ធនឹងសិទ្ធិស្មើគ្នារវាងស្ត្រីនិងបុរសទាក់ទិននឹងការកាន់ កាប់ដីធ្លីរួមទាំងក្នុងផ្នែកទី៨ (អេ) នៃគោលការណ៍គ្រឹះដែលបានលើកឡើងពីខាងដើម និងប្រហែលក្នុងផ្នែកទី៩ផងដែរដែលស្តីពី «សិទ្ធិស្មើគ្នារវាងស្ត្រីនិងបុរស»។ បើតាមហេតុផលប្លែកៗរបស់គណកម្មការពិសេស

វិញការអំពាវនាវឲ្យដកចេញនូវវិធានការទាំងនោះត្រូវបានលើកឡើងដោយភាពភ័យខ្លាច ដែលមើលឃើញថាភាពរួបរួមគ្នារបស់បណ្តាជនជាតិភាគតិចនឹងត្រូវប៉ះពាល់ ដោយសារតាមការសន្មតក្រុមជនជាតិភាគតិចមានបំណងចង់បន្តនូវការរើសអើងប្រឆាំងនឹងស្ត្រីក្នុងការធ្វើជាម្ចាស់កាន់កាប់ដីធ្លី។ គ្មានភស្តុតាងណាមួយបានបញ្ជាក់អំពីការលើកឡើងបែបនេះឡើយ។ សេចក្តីថ្លែងនេះកើតចេញដោយផ្អែកខ្លាំងលើគំនិតផ្ទាល់ខ្លួនរបស់សមាជិកនៃគណកម្មការពិសេស ដែលសមាជិកទាំងអស់នោះសុទ្ធតែជាបុរស ជាជាងផ្អែកលើភស្តុតាងជាក់ស្តែងណាមួយពិតប្រាកដ។ ជាការពិតណាស់ ខណៈដែលសកម្មភាពអបអរទិវាអន្តរជាតិនារី៨មីនា នៅជុំវិញពិភពលោកត្រូវបានផ្តោតជាថ្មីម្តងទៀត ស្ថានភាពបច្ចុប្បន្ននៃសិទ្ធិដីធ្លីរបស់ស្ត្រីរួមទាំងនៅមីយ៉ាន់ម៉ាដែរបានបង្ហាញថា វាមានភាពចាំបាច់ដែលគួរពិចារណាក្នុងការលើកកម្ពស់ចំណេះដឹងអំពីសិទ្ធិស្ត្រីក្នុងអភិបាលកិច្ចដីធ្លីដល់ភ្នាក់ងារមន្ត្រីរដ្ឋាភិបាលនៅមីយ៉ាន់ម៉ានិងនៅទីកន្លែងផ្សេងៗទៀត ។

បន្ទាប់ពីមានសេចក្តីថ្លែងពីការដកចេញនូវចំណុចខាងលើ គណកម្មការពិសេសបានបង្ហាញចេញនូវចំនុចលម្អិតចំនួន៦ ដែលគួរតែដាក់បន្ថែមទៅក្នុងគោលនយោបាយបច្ចុប្បន្ន។ ចំណុចខ្លះពាក់ព័ន្ធនឹងមុខងារអង្គភាពរដ្ឋបាលផ្សេងៗរបស់រដ្ឋាភិបាល។ ប៉ុន្តែទំនោរភាគច្រើននៃការកែតម្រូវដែលបានស្នើឡើងមកនេះពាក់ព័ន្ធនឹងការរក្សាផលប្រយោជន៍ជំនួញ និងលទ្ធភាពរបស់រដ្ឋក្នុងការទទួលបានដីដែលត្រូវបានចាត់ទុកថាចាំបាច់ទាំងអស់ដោយគ្មានលក្ខខណ្ឌ។ ទទ្បីករណ៍នោះ អាចត្រូវសង្ខេបរួមបានក្នុងហេតុផលដូចខាងក្រោយនេះដែលយកចេញពីអនុប្រយោគទី៦របស់លិខិតបង្កើតកិច្ចប្រតិបត្តិការងារដែលថា៖ «ក្នុងនាមរដ្ឋដែលជាម្ចាស់ដើមនៃធនធានដីទាំងអស់ ក្នុងករណីចាំបាច់មានសិទ្ធិពេញលេញក្នុងការយកនិងគ្រប់គ្រងលើដី ដើម្បីជាប្រយោជន៍សាធារណៈដែលគួរតែត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយនេះ។ ការផ្លាស់ប្តូរការប្រើប្រាស់ដី ពីប្រភេទដីស្រែទៅជាដីប្រភេទផ្សេងទៀត និងការកាន់កាប់ដីផ្តាច់មុខនាំឲ្យតម្លៃដីកើនឡើងខ្ពស់ ហើយជាលទ្ធផលវិនិយោគិនក្នុងស្រុកនិងបរទេសប្រឈមនឹងឧបសគ្គជាច្រើន។ ដូច្នេះ សហជីព ឬរដ្ឋ ឬក៏រដ្ឋាភិបាលប្រចាំតំបន់ត្រូវយកដីមកកាន់កាប់ដោយផ្តល់ជាសំណងក្នុងតម្លៃជាក់លាក់ ដើម្បីឲ្យមានការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាពនិងមានប្រយោជន៍។»

បច្ចុប្បន្ននេះ គ្មាននរណាដឹងថាតើការជំនះរបស់គណកម្មការពិសេសទៅនឹងការធ្វើកំណែទម្រង់ដីធ្លីដែលជាការចង់បានរបស់ប្រជាជនភាគច្រើន ហើយដែលប្រព្រឹត្តទៅក្នុងដំណើរការមួយយូរឆ្នាំមកហើយនោះនឹងទៅជាបែបណានោះទេ។ លិខិតបង្កើតកិច្ចប្រតិបត្តិការងាររបស់គណកម្មការពិសេសកំពុងតែធ្វើដំណើរសន្សឹមៗតាមផ្លូវរបស់រដ្ឋាភិបាល។ ប៉ុន្តែសំណួរដែលលេចឡើងនោះគឺថា តើចេតនាខាងភាគីរដ្ឋាភិបាលក្នុងការសម្របសម្រួលនូវវិធានការទាំងនោះឲ្យទៅមុខជាឯកតោភាគី នឹងជះឥទ្ធិពលអ្វីខ្លះដល់ទំនុកចិត្តនិងឆន្ទៈដែលបានកសាងកន្លងមករវាងរដ្ឋាភិបាលនិងប្រជាពលរដ្ឋ សង្គមស៊ីវិលនិងក្រុមជនជាតិភាគតិច ដែលបានចូលរួមក្នុងដំណើរការ ពិគ្រោះយោបល់ជាយូរឆ្នាំលើគោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី (NLUP) នេះ។ ជាងនេះទៅទៀត តើការផ្លាស់ប្តូរបែបនេះ មិនត្រូវបានមើលឃើញថាជាការច្រានចោលចំពោះការចាប់ផ្តើមនូវកិច្ចខិតខំប្រឹងប្រែងលើដំណើរការពិគ្រោះយោបល់នៅពាសពេញផ្ទៃប្រទេស ជុំវិញការបង្កើតគោលនយោបាយនិងច្បាប់ទេឬ? បើមើលពីខាងក្រៅ ការវាយប្រហារលើគោលនយោបាយជាតិស្តីពីការប្រើប្រាស់ដី (NLUP) បាន

លេចចេញឡើងជាផ្នែកនៃការប្រយុទ្ធជាចំហមួយ ដែលមានការចូលរួមពីភាគីម្ខាងជាអ្នកដែលស្រេកឃ្លានចង់បានដី និងការធ្វើកំណែទម្រង់ដីកសិកម្មបម្រើជាប្រយោជន៍ និងភាគីម្ខាងទៀតជាក្រុមអ្នកជំនួញ ដែលចង់រក្សាការគ្រប់គ្រងដដែល។

ប៉ុន្តែអ្វីដែលប្រហែលជាបញ្ហាសំខាន់បំផុតសម្រាប់ករណីនេះ គឺថាអង្គភាពរបស់សភាមួយដែលមិនបានឆ្លងកាត់នូវការបោះឆ្នោតជ្រើសតាំង ប៉ុន្តែមានអំណាចយ៉ាងខ្លាំងក្នុងភាពអាចកំបាំងនោះ បានលេចរូបរាងឡើងជាអង្គភាពដែលមានឥទ្ធិពលដ៏គួរឲ្យកត់សម្គាល់ទៅលើរបៀបវារៈនៃការធ្វើកំណែទម្រង់ដីធ្លីនៅក្នុងប្រទេសមីយ៉ាន់ម៉ា។ តើរដ្ឋាភិបាលមីយ៉ាន់ម៉ានឹងអនុញ្ញាតឲ្យបំណងប្រាថ្នារបស់ប្រជាពលរដ្ឋប្រែជាក្រឡាប់ចាក់ដោយសារតែស្ថាប័នសម្ងាត់មួយនោះដែរឬទេ?

**អត្ថបទនេះបានចងក្រងដោយអគ្គលេខាធិការដ្ឋានរបស់ចលនាព្រៃស្រោងពិភពលោក (*WRM Secretariat*)** ដោយផ្អែកលើព័ត៌មានមកពីក្រុមស្រាវជ្រាវនៅមូលដ្ឋានរបស់ចលនាព្រៃស្រោងពិភពលោក (*WRM*) និងព័ត៌មានយោងពីឯកសារខាងក្រោមនេះ៖

(១) អ៊ែនឌីអ៊ែល (NDL) មានន័យពេញថាសម្ព័ន្ធជាតិដើម្បីប្រជាធិបតេយ្យ (The National League for Democracy)។ គណបក្សនេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៨៨ ហើយបច្ចុប្បន្ននេះកំពុងតែបម្រើតួនាទីជាគណបក្សកាន់អំណាចនៅក្នុងប្រទេសមីយ៉ាន់ម៉ា ដោយមាន ដ អ៊ុង សានស៊ូជី (Daw Aung San Suu Kyi) ជាប្រធាន និងជាសមាជិកក្រុមប្រឹក្សារដ្ឋនៅមីយ៉ាន់ម៉ា។

(២) ហ្វ៊ើបស៍ (Forbes) អ៊ី (E.) (២០១៧)។ ការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងការធ្វើគោលនយោ បាយដីធ្លី៖ បទពិសោធន៍នៃការច្នៃបង្កើតថ្មីរបស់មីយ៉ាន់ម៉ាមុនពេលកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីគោលនយោបាយជាតិស្តីពីការប្រើប្រាស់ដីធ្លី។ គម្រោងគ្រប់គ្រងដីសម្រាប់តំបន់ទន្លេមេគង្គ។ វៀងច័ន្ទ និងយ៉ាន់ហ្គោន។

(៣) ណាម៉ាទី (Namati) (២០១៦)។ ទស្សនៈនានាស្តីពីយេនឌ័រនៅក្នុងសិទ្ធិដីធ្លីនៅក្នុងប្រទេសមី យ៉ាន់ម៉ា៖ ភស្តុតាងពីករណី Paralegal Casework។ ទំព័រ ៥-៦។

(៤) http://frontiermyanmar.net/en/law-reform-a-daunting-challenge

(៥) http://www2.irrawaddy.com/article.php?art_id=14151&page=3

(៦) http://www.mmtimes.com/index.php/national-news/nay-pyi-taw/18853-thura-u-shwe-mann-appointed-to-head-own-legislative-commission.html

(៧) https://cdeweb4.unibe.ch/Pages/News/149/OneMap-Myanmar-New-CDE-project-launched.aspx

(៨) http://www.burmalibrary.org/docs21/NLD_2015_Election_Manifesto-en.pdf

# ព្រៃនៅភូមិភាគឥសានរបស់ឥណ្ឌា

តំបន់នេះជាទូទៅត្រូវបានស្គាល់ថាជា «ភូមិភាគឥសានរបស់ប្រទេសឥណ្ឌា» ឬក៏ហៅត្រឹមថា «ភូមិភាគឥសាន» ដែលភ្ជាប់មកឥណ្ឌាដីគោកយ៉ាងស្តួចតាមរយៈដីដុះដែលមានប្រវែងប្រហែល២០គីឡូម៉ែត្រ ហើយព័ទ្ធជុំវិញដោយប្រទេសនេប៉ាល់ ប៊ូ តាន ចិន មីយ៉ាន់ម៉ា និងបង់ក្លាដេស។ មានសហគមន៍ជនជាតិដើម និងកុលសម្ព័ន្ធជាង២០០ក្រុម កំពុងរស់ក្នុងតំបន់នេះដែលភាគច្រើនមានវប្បធម៌ ម្ហូបអាហារ សំលៀកបំពាក់ សេដ្ឋកិច្ច និង នយោបាយស្រដៀងៗគ្នា ហើយមានក្បួនច្បាប់ដ៏សម្បូរបែបនិងមានស្ថាប័នជាក់លាក់សម្រាប់កុលសម្ព័ន្ធនីមួយៗ។

ថ្វីបើនគរូបនីយកម្មកំពុងមានកំណើន ជាពិសេសនៅក្នុងទីក្រុងដែលជារាជធានីនោះ ជីវិតរបស់សហគមន៍ដែលកំណត់ន័យភាគច្រើនទៅតាមបែបធម្មជាតិនៅតែមាន។ ព្រៃ ភ្នំ និងទន្លេ ជាជីវិតរបស់ពួកគេ។ ស្របគ្នានេះដែរ រដ្ឋនិងក្រុមហ៊ុនសាជីវកម្មបន្តជំរុញនូវកម្មវិធី «អភិវឌ្ឍន៍» របស់ពួកគេ ហើយមានសន្ទុះកាន់តែខ្លាំងនាពេលបច្ចុប្បន្ននេះដោយសារមូលធនពិភពលោក និងឧស្សាហកម្មរុករករ៉ែ កំពុងចូលទៅក្នុងតំបន់ដាច់ស្រយាល។ នៅក្នុងបរិបទនៃកម្មវិធី «អភិវឌ្ឍន៍» ជឿនលឿននេះ អត្ថន័យ និងការប្រើប្រាស់ព្រៃឈើត្រូវបានកំណត់ន័យសារឡើងវិញ។

នៅក្នុងស្ថិតិ រដ្ឋភាគច្រើននៅក្នុងតំបន់មានចំនួនព្រៃគ្របដណ្តប់លើសពី៧០ទៅ៨០ភាគរយ។ វាគឺជាតំបន់មួយក្នុងចំណោមតំបន់ពីរបីដែលនៅសេសសល់នៅលើផែនដីនេះ ដែលមានប្រព័ន្ធអេកូឡូស៊ីដ៏សម្បូរបែប និងមិនខូចខាត។ នៅក្នុងព្រៃទាំងនេះ មានសហគមន៍ដែលរីកលូតលាស់។ ពួកគេ «គឺជាម្ចាស់» និង «គ្រប់គ្រង» តំបន់ព្រៃទាំងនេះក្រោមការគ្រប់គ្រងរបស់សហគមន៍។ រដ្ឋពុំមានសិទ្ធិអំណាចដោយផ្ទាល់ទៅលើព្រៃសហគមន៍ទាំងនេះឡើយ លើកលែងតែតំបន់បម្រុងទុក និងតំបន់ ការពាររបស់រដ្ឋតែប៉ុណ្ណោះ។ ឧទាហរណ៍ រដ្ឋម៉ានីពួរមានផ្ទៃដី៧៧ភាគរយនៃទំហំផ្ទៃដីសរុបទាំងអស់ជាតំបន់ព្រៃ ប៉ុន្តែក្នុងនោះមានដីប្រហែលជា៧ភាគរយប៉ុណ្ណោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលប្រចាំរដ្ឋ។ ចំពោះដីព្រៃដែលនៅសល់វិញ សហគមន៍គឺជាអ្នកគ្រប់គ្រងដោយផ្ទាល់។ ទោះជាយ៉ាងណាក្តីនៅរដ្ឋអាសាម (Assam) វិញ ព្រៃបឋមមួយភាគធំត្រូវបានបំផ្លាញ នៅពេលភ្នាក់ងារអាណានិគមអង់គ្លេសបាននាំចម្ការដំណាំតែដែលមានលក្ខណៈពាណិជ្ជកម្មចូលមក។ សព្វថ្ងៃនេះ ចម្ការតែគ្របដណ្តប់លើផ្ទៃដីចំនួន ៣១២,២១០ហិចតានៅរដ្ឋអាសាម (Assam) ហើយត្រូវបានគេជឿថាវាជាតំបន់ដាំដុះតែធំជាងគេតែមួយគត់នៅលើពិភពលោក។

ការដាំដុះដំណាំឧស្សាហកម្មសម្រាប់ធ្វើពាណិជ្ជកម្ម ជាពិសេសដំណាំកៅស៊ូដែលមិនមែនជារឿងថ្មីទេសម្រាប់តំបន់នេះ កំពុងវាតទីលើតំបន់ព្រៃបឋមកាន់តែច្រើនឡើងៗ។ ចម្ការតែនិងកាហ្វេកំពុងតែត្រូវបានពង្រីកទៅក្នុងតំបន់ព្រៃភ្នំ។ នៅទ្រីពូរ៉ា (Tripura) ការកាប់បំផ្លាញព្រៃឈើបានចាប់ផ្តើមរួចមកហើយ ដើម្បីយកដីទំហំ១០ម៉ឺនហិចតាបន្ថែមទៀតសម្រាប់ចម្ការកៅស៊ូ។ ទ្រីពូរ៉ា (Tripura) គឺជាតំបន់ផលិតកៅស៊ូធម្មជាតិដែលធំជាងគេទីពីរនៅក្នុងប្រទេសឥណ្ឌារួចទៅហើយ។ ការពង្រីកនេះធ្វើឡើងនៅលើដីព្រៃរបស់កុលសម្ព័ន្ធ ក្រោមការគ្រប់

គ្រងរបស់អាជ្ញាធរមូលដ្ឋាន។ ចម្ការកៅស៊ូក៏ត្រូវបានពង្រីកទៅក្នុងរដ្ឋអារុណាចាល់ (Arunachal) និងរដ្ឋណាហ្គាលែន (Nagaland) ផងដែរ។

មានការពង្រីកចម្ការដំណាំឧស្សាហកម្មមួយផ្សេងទៀត គឺដំណាំដូងប្រេងនៅមីហ្សូរ៉ាម (Mizoram)។ រដ្ឋាភិបាលមីហ្សូរ៉ាម (Mizoram) មានគោលបំណងបង្កើននូវចម្ការដូងប្រេងទំហំប្រហែលជា១៥ម៉ឺនហិចតា។

នៅមេហ្គាឡាយ៉ា (Meghalaya) ផលប៉ះពាល់លើបរិស្ថាន ជាពិសេសពីការកាប់បំផ្លាញព្រៃឈើដើម្បីរុករករ៉ែធ្យូងថ្ម និងថ្មកំបោរ ត្រូវបានចងក្រងទុកជាឯកសារបានយ៉ាងល្អ ហើយការបន្តរុករករ៉ែធ្យូងថ្មក៏ត្រូវបានហាមឃាត់ដោយតុលាការកំពូលដែរ។ (១) ភាពរីកចម្រើននៃចម្ការដំណាំសម្រាប់ធ្វើពាណិជ្ជកម្ម និងការរុករករ៉ែខ្នាតធំនៅលើដីដែលគ្រប់គ្រងដោយសហគមន៍ ក៏បង្ហាញនូវការផ្លាស់ប្តូរលក្ខណៈដើមរបស់សង្គម/ភូមិ និងសម្ពាធមកលើសង្គម/ភូមិដែរ។

**ច្បាប់និងស្ថាប័ន**ដែលគ្រប់គ្រងព្រៃឈើនៅក្នុងតំបន់នេះមានលក្ខណៈផ្សេងៗគ្នា។ ច្បាប់ទម្លាប់ប្រពៃណី និងស្ថាប័ន មានលក្ខណៈខុសៗគ្នាពីកុលសម្ព័ន្ធមួយ ទៅកុលសម្ព័ន្ធមួយទៀត ប៉ុន្តែពួកគេគឺផ្តោតលើភាពជាសហគមន៍។ ជាធម្មតាថ្នាក់ដឹកនាំភូមិ ឬក៏ក្រុមប្រឹក្សាភូមិ និង/ឬកុលសម្ព័ន្ធ បែងចែកដីព្រៃឲ្យគ្រួសារមួយសម្រាប់ធ្វើចម្ការវិលជុំ។ ប្រសិនបើដីមួយប្លង់ណាត្រូវបានបោះបង់ចោល ដីនោះត្រូវឲ្យសហគមន៍វិញ។ ការលក់ដីគឺមិនត្រូវបានអនុញ្ញាតនោះទេ ហើយក៏មិនអនុញ្ញាតឲ្យយកដីសហគមន៍ដែលជាកេរមរតកប្រពៃណី ឬក៏ផ្ទេរដីទៅជាកម្មសិទ្ធិរបស់បុគ្គលដែរ។ ប៉ុន្តែទាំងការលក់ដី និងការផ្ទេរកម្មសិទ្ធិដីទៅជាកម្មសិទ្ធិបុគ្គលឯកជន នោះកំពុងធ្វើឡើងទាំងបំពាន ដែលនេះជាលទ្ធផលនៃសម្ពាធពីខាងក្នុងនិងខាងក្រៅ។ សព្វថ្ងៃនេះ ថ្នាក់ដឹកនាំកុលសម្ព័ន្ធមូលដ្ឋានត្រូវបានគេដឹងថា បានប្រគល់ដី/ព្រៃតាមរយៈអ្វីដែលហៅថា «ប័ណ្ណមិនជំទាស់» ឲ្យទៅការវិនិយោគបែបពាណិជ្ជកម្ម ដែលបានផ្តល់នូវឯកសារបញ្ជាក់ពីការបានឆ្លងកាត់ការត្រួតពិនិត្យលើផ្នែកបរិស្ថាននិងការការពារផ្សេងៗរួចហើយ។ ចំពោះករណីផ្សេងទៀត ក្រុមប្រឹក្សាភូមិបានដកទុកការអនុញ្ញាតឲ្យរុករករ៉ែ ដើម្បីបញ្ជាក់ឡើងវិញនូវភស្តុតាងដែលបានព្រមព្រៀងគ្នា និងបញ្ជាក់ថាការប្តេជ្ញារបស់ខ្លួនពេលខ្លះ ពិតជាមានប្រយោជនសម្រាប់ថ្ងៃអនាគតដែរ។

ច្បាប់ស្តីពីក្រុមកុលសម្ព័ន្ធ និងអ្នករស់នៅក្នុងព្រៃបែបប្រពៃណីដទៃទៀត (ការទទួលស្គាល់សិទ្ធិព្រៃឈើ) ឆ្នាំ២០០៦ គឺជាគោលនយោបាយជាតិមួយដែលមានការវិវត្តក្នុងគោលបំណងដោះស្រាយនូវភាពអយុត្តិធម៌ក្នុងប្រវត្តិសាស្ត្រដែលក្រុមកុលសម្ព័ន្ធ និងអ្នករស់នៅព្រៃបែបប្រពៃណីបានជួបប្រទះ។ វាក៏ត្រូវបានហៅថា ច្បាប់ស្តីពីសិទ្ធិព្រៃឈើ ច្បាប់ស្តីពីសិទ្ធិកុលសម្ព័ន្ធ ច្បាប់កុលសម្ព័ន្ធ និងច្បាប់ស្តីពីដីរបស់កុលសម្ព័ន្ធ ផងដែរ (សូមមើលព្រឹត្តិបត្ររបស់ចលនាព្រៃស្រោងពិភពលោក ២០៥ (WRM Bulletin 205))។ វាជាលើកដំបូង ហើយដែលច្បាប់នេះក្នុងចំណោមច្បាប់ដទៃទៀត បានទទួលស្គាល់និងផ្តល់អំណាចលើសិទ្ធិព្រៃឈើ និងការកាន់កាប់នៅក្នុងដែនដីរបស់ក្រុមកុលសម្ព័ន្ធ និងអ្នករស់នៅព្រៃបែបប្រពៃណីដទៃទៀតដែលកំពុងរស់នៅក្នុងព្រៃនេះតជំនាន់មកហើយ ប៉ុន្តែសិទ្ធិរបស់ពួកគេមិនត្រូវបានកត់ត្រាទុកនោះទេ។ លើកលែងតែនៅរដ្ឋអាសាម (Assam) និងទ្រីពូរ៉ា (Tripura) រដ្ឋប្រាំមួយផ្សេងទៀតនៅភាគឥសានពុំបានអនុវត្តច្បាប់នេះទេ ដោយ

មូលហេតុថាមានកម្មសិទ្ធិសហគមន៍ទៅលើព្រៃឈើរួចមកហើយ ហើយមានភាពភ័យខ្លាចថាច្បាប់ពីខាងក្រៅអាចនឹងគ្របលើអាជ្ញាធរមូលដ្ឋានដែលមានស្រាប់នៅពេលក្រោយ។

**កត្តានានាដែលអាចប៉ះពាល់យ៉ាងខ្លាំងដល់ព្រៃឈើនៅក្នុងតំបន់នៅប៉ុន្មានឆ្នាំខាងមុខនេះ** រួមបញ្ចូលទាំងការពង្រីកការរុករករ៉ែ ទំនប់ ផ្លូវហាយវ៉េ និងការពង្រីកផ្លូវដែក ហេដ្ឋារចនាសម្ព័ន្ធ ការពង្រីកនូវចម្ការដំណាំឧស្សាហកម្ម និងសកម្មភាពផ្សេងៗដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

ការរុករករ៉ែធ្យូងថ្មគឺជាបញ្ហាដ៏សំខាន់មួយនៅក្នុងរដ្ឋអាសាម(Assam)និងមេហ្គាឡាយ៉ា(Meghalaya)។ ដោយសារតែមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបរិស្ថាន សវនាការបៃតងថ្នាក់ជាតិនៃតុលាការកំពូលបានហាមមិនឲ្យមានការរុករករ៉ែធ្យូងថ្មទៀតទេនាពេលបច្ចុប្បន្ន (១)។ ការកំពប់ប្រេងហៀរហូរនៅក្នុងតំបន់ប្រតិបត្តិការរបស់សាជីវកម្មប្រេង ធម្មជាតិ និងឧស្ម័ន នៅក្នុងស្រុកវ៉ូខា (Wokha) នៃ តំបន់ណាហ្គាលែន (Nagaland) បានបង្កឲ្យមានការបំផ្លាញយ៉ាងខ្លាំងទៅលើព្រៃឈើ និងដីស្រែ។ (២) អង្គការមូលដ្ឋានបានឡើងទៅតុលាការដើម្បីទាមទារសំណងនិងការស្តារឡើងវិញ។ មានគម្រោងស្នើសុំរុករកប្រេងជាច្រើនរួចទៅហើយនៅក្នុងរដ្ឋមីហ្សូរ៉ាម (Mizoram) ម៉ានីពួរ (Manipur) និងអារុណាចាល់ (Arunachal)។ គម្រោងស្នើសុំទាំងអស់នេះអាចធ្វើឲ្យតំបន់ព្រៃរងការបំផ្លិចបំផ្លាញ និងការបង្វែរព្រៃទៅប្រើប្រាស់ជាអ្វីផ្សេងទៀត។

ជាងនេះទៅទៀត រដ្ឋាភិបាលមានគម្រោងសាងសង់ទំនប់ជាង ១៥០កន្លែងបន្ថែមទៀត ដែលភាគច្រើនជាគម្រោងខ្នាតធំ។ គ្រាន់តែនៅក្នុងរដ្ឋអារុណាចាល់ (Arunachal) មួយប៉ុណ្ណោះ រដ្ឋាភិបាលបានចុះហត្ថលេខាលើអនុស្សារណៈព្រមព្រៀងគ្នាជាច្រើន ដើម្បីសាងសង់ទំនប់ចំនួន១២៧កន្លែងនៅតាមទន្លេចំនួន៤២ ជាមួយក្រុមហ៊ុនទំនប់ចំនួន៥៩ក្រុមហ៊ុន ក្នុងគោលបំណងផលិតថាមពលអគ្គិសនីចំនួន៤២,៥៩១មេហ្គាវ៉ាត់។ ទំនប់ទាំងអស់នេះនឹងឈ្លានពានចូលទៅក្នុងតំបន់ព្រៃក្រាស់ៗនិងព្រៃបឋមជាទ្រង់ទ្រាយធំ។ នៅម៉ានីពួរ (Manipur) គម្រោងទំនប់ខ្ពស់ទីប៉ៃមុខហ៍ (Tipaimukh High Dam) ដ៏ចម្រូងចម្រាសត្រូវបាន «លុបចោល»។ ការសាងសង់ទំនប់នេះអាចនឹងវាតទីលើផ្ទៃដីព្រៃចំនួន ២២.៧៧៧ ហិចតា។ ការជំទាស់របស់អ្នកស្រុករួមនឹងការប្រឆាំងតវ៉ាពីថ្នាក់ជាតិនិងអន្តរជាតិបានសម្របសម្រួលឲ្យករណីដ៏កម្រមួយនៃការសង់ទំនប់នេះត្រូវបានបញ្ឈប់ ដែលទំនប់នេះអាចនឹងរំលោភលើតំបន់ព្រៃដ៏ធំមួយ និងប៉ះពាល់ដល់ជីវភាពរស់នៅរាប់មិនអស់ដែលអាស្រ័យលើព្រៃទាំងនេះ។

ផ្លូវហាយវ៉េ ផ្លូវដែក និងហេដ្ឋារចនាសម្ព័ន្ធគឺជាអាទិភាពនៅក្នុងគម្រោងផែនការរបស់រដ្ឋាភិបាលឥណ្ឌាក្នុងការ «បើកចំហ» តំបន់នេះ។ ការបើកចំហនោះរួមមាន «ការបើកចំហ» នូវវប្បធម៌ និង «សម្រស់» របស់តំបន់សម្រាប់ទេសចរណ៍ «ការបើកចំហ»ព្រៃឈើសម្រាប់ការទាញយកធនធានឈើធ្វើជាបរិក្ខារ សម្រាប់ស្តុកកាបូនមឱសថបុរាណជាដើម «ការបើកចំហ»សម្រាប់ការប្លន់យកធនធានរ៉ែ និងហេដ្ឋារចនាសម្ព័ន្ធដើម្បីផ្សារភ្ជាប់ឥណ្ឌាទៅតំបន់អាស៊ានដែលជាតំបន់មានឥទ្ធិពលផ្នែកភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ច។ មានហេដ្ឋារចនាសម្ព័ន្ធពីរសំខាន់ៗ គឺផ្លូវហាយវ៉េអន្តរអាស៊ី (Trans Asian Highway) និង ផ្លូវដែកអន្តរអាស៊ី (Trans Asian

Railway) ដែលបច្ចុប្បន្នកំពុងតែស្ថិតក្នុងការសាងសង់។ ប្រព័ន្ធឧស្ម័ននិងប្រេងដ៏ធំមួយដែលភ្ជាប់អាស៊ីខាងត្បូងនឹងអាស៊ីអាគ្នេយ៍កំពុងត្រូវបានរៀបចំជាផែនការ ហើយស្ថានីយ៍ថាមពលអគ្គិសនី មួយប្រចាំតំបន់ក៏កំពុងតែសាងសង់ដែរ។ ការអភិវឌ្ឍលើហេដ្ឋារចនាសម្ព័ន្ធទាំងអស់នេះ នឹងមានផលប៉ះពាល់ដោយផ្ទាល់លើជីវិតនិងជីវភាពរស់នៅរបស់ប្រជាជននៅក្នុងព្រៃ និងបំផ្លាញតំបន់ព្រៃជាច្រើន។

**ការប្រែប្រួលអាកាសធាតុ និងព្រៃឈើ**

ខណៈសហគមន៍ដែលរស់នៅអាស្រ័យព្រៃឈើដូចជាសហគមន៍ដែលឃើញមាននៅពាសពេញតំបន់ភាគឥសាននោះ មានភាពឈានមុខគេចំពោះរបៀបរស់នៅដែលមានការបញ្ចេញកាបូនតិចបំផុត ប៉ុន្តែការប្រែប្រួលអាកាសធាតុកំពុងប៉ះពាល់ដល់របៀបរស់នៅនិងជីវភាពរបស់ពួកគេរួចទៅហើយ។ ផលប៉ះពាល់ទាំងនោះកាន់តែធ្ងន់ធ្ងរឡើងៗ ដោយសារតែការអនុវត្តសកម្មភាពដែលពាក់ព័ន្ធនឹងព្រៃឈើពីរប្រភេទ ដែលមានបំណងជួយកាត់បន្ថយនូវការកើនកម្តៅពិភពលោក។ សកម្មភាពទីមួយគឺជាការស្តារឡើងវិញនូវដីដែល «សឹករេចរឹល» ឬក៏ «ការការពារ» ព្រៃដែលនៅមានស្រាប់ ដោយចាត់ទុកវាជាកន្លែងស្តុកកាបូន (carbon stores) ឬអាងស្រូបកាបូន (carbon sinks)។ សកម្មភាពទីពីរគឺចម្ការដំណាំឧស្សាហកម្មជីវៈម៉ាស់ (ការដាំដុះប្រភេទរុក្ខជាតិ/ឈើដែលអាចដុតយកថាមពលប្រើប្រាស់បាន) សម្រាប់យកប្រេងរុក្ខជាតិ ឬផលិតថាមពល។ ចម្ការដំណាំឧស្សាហកម្មដែលបង្កើតឡើងដើម្បីគោលបំណងទាំងនេះ ដែលភាគច្រើនជាចម្ការដំណាំឯកវប្បកម្មលើផ្ទៃដីធំៗ ហើយគ្រប់គ្រងកាន់កាប់ដោយក្រុមហ៊ុនសាជីវកម្មនោះ មិនអាចត្រូវរាប់ថាជាព្រៃឈើដាច់ខាត។

ស្ថាបត្យករមួយក្នុងចំណោមស្ថាបត្យករនៃគម្រោងកាបូនព្រៃឈើនៅភូមិភាគឥសាន គឺធនាគារពិភពលោក។ ដោយជាផ្នែកមួយនៃការសិក្សារបស់ធនាគារពិភពលោកស្តីពី «ធនធានធម្មជាតិ ទឹក និង ទំនាក់ទំនងបរិស្ថាន (Environment Nexus) ដើម្បីការអភិវឌ្ឍនិងការរីកចម្រើននៅភូមិភាគឥសាននៃប្រទេសឥណ្ឌា» (៣) ការសិក្សាពីប្រវត្តិ «ហិរញ្ញប្បទានកាបូននិងវិស័យព្រៃឈើនៅភូមិភាគឥសានរបស់ឥណ្ឌា» គាំទ្រនិងត្រួសត្រាយផ្លូវយ៉ាងច្បាស់ឲ្យមានការបំលែងដីកសិកម្មនិងដីព្រៃឲ្យក្លាយជាគម្រោងកាបូនព្រៃឈើដែលមាន«ផលចំណេញ» ជាងមុន។ ឯកសារប្រវត្តិមួយបន្ថែមទៀតសម្រាប់ការសិក្សាដូចគ្នានេះដែរ ដែលមានចំណងជើងថា «ការពិនិត្យឡើងវិញលើវិស័យព្រៃឈើនៅភូមិភាគឥសានរបស់ឥណ្ឌា» ក៏បានចង្អុលបង្ហាញពីកម្មវិធីដែលផ្តោតលើកាបូននៅក្នុងតំបន់ដែរ។ ចេតនាយ៉ាងច្បាស់របស់ធនាគារពិភពលោកក្នុងអន្តរាគមន៍ទៅលើវិស័យព្រៃឈើនៅភូមិភាគឥសាន (NE) ទំនងជាថាគម្រោងជីវភាពរស់នៅនៃភូមិភាគឥសាន (NE) របស់ធនាគារពិភពលោក នឹងមានគម្រោងពាក់ព័ន្ធនឹងកាបូនជាពិសេស។ ប្រសិនបើធនាគារពិភពលោក គ្រោងបញ្ចូលភូមិភាគឥសានទាំងមូលក្នុងគម្រោងនេះ ហើយប្រសិនបើអាងស្រូបកាបូន ជាផ្នែកមួយរបស់គម្រោងនេះនៅក្នុងស្រុកនីមួយៗនោះ តំបន់ទេសភាពនិងសហគមន៍នៅក្នុងភូមិភាគឥសានទាំងមូល(NE) នឹងរងផលប៉ះពាល់ជាអវិជ្ជមានដោយសារតែដំណោះស្រាយមិនត្រឹមត្រូវចំពោះវិបត្តិអាកាសធាតុ។

សហគមន៍ព្រៃឈើអន្តរជាតិ (CFI)) ដែលមានទីតាំងនៅសហរដ្ឋអាមេរិកបានចាប់ផ្តើមគម្រោងរេដបូកម៉ាវផ្លាង ដែលជាគម្រោងសាកល្បងដំបូងគេនៅក្នុងតំបន់កាលពីឆ្នាំ២០១១។ (៤) គម្រោងរេដបូកម៉ាវផ្លាង

មានទីតាំងនៅតំបន់ខ្ពង់រាបខាស៊ីភាគខាងកើត ដែលស្ថិតនៅក្នុងស្រុកម៉េហ្គាឡាយ៉ា ហើយពេលខ្លះវាត្រូវបាន សហគមន៍ព្រៃឈើអន្តរជាតិ ហៅថា «គម្រោងរេដបូកនៅសហគមន៍ខ្ពង់រាបខាស៊ី» ។ គម្រោងនេះគ្របដណ្តប់លើផ្ទៃដីចំនួន១៥.២១៧ហិចតា ដែលរួមបញ្ចូលទាំងតំបន់ព្រៃក្រាស់ៗប្រហែលជា៩២៧០ហិចតា និងព្រៃទូលាយ (ព្រៃឈើដែលមានគម្របដើមឈើពី១០ ទៅ ៤០ភាគរយ) ចំនួន៥៩៤៧ហិចតា នៅក្នុងឆ្នាំ២០១០។ ព្រៃដែលបានដាក់បញ្ចូលទៅក្នុងគម្រោងរេដបូក (REDD+) ជាប្រភេទព្រៃកម្រតាំងពីដូនតាមក។ សហគមន៍ព្រៃឈើអន្តរជាតិ (CFI)) បានធ្វើបញ្ជីឈ្មោះអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអង្គភាពមួយចំនួន ដែលជាដៃគូសហប្រតិបត្តិការដូចជា ដឺ បែតថានីសូសាយអឹធី (the Bethany society) ក្រុមប្រឹក្សាស្រុកស្វយ័តនៃតំបន់ខ្ពង់រាបខាស៊ី (the Khasi Hills Autonomous District Council) សកម្មភាពភពផែនដី (Planet Action) និងមូលនិធិឯកជនវ៉តធើលូដែលមានមូលដ្ឋាននៅចក្រភពអង់គ្លេស (UK-based private Waterloo Foundation)។ ដឺ ឡូខល កា ស៊ីនជុក គី ហ៊ីម៉ា អាលីយ៉ាង វ៉ាហ៍ យូមីយ៉ាំ (The local Ka Synjuk Ki Hima Arliang Wah Umiam) ម៉ាវផ្លាងវេលហ្វែសូសាយអឹធី (Mawphlang Welfare Society) ត្រូវបានដាក់ក្នុងបញ្ជីជាក្រុមគាំទ្រគម្រោងជាមួយនឹងសហគមន៍ព្រៃឈើអន្តរជាតិ (CFI))។ មូលនិធិវ៉តធើលូ (Waterloo Foundation) បានផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុចំនួន១០ម៉ឺនផោន ដល់គម្រោងនេះ សម្រាប់ឆ្នាំ២០១១ដល់២០១២។ យោងទៅតាមឯកសាររបស់គម្រោង សិទ្ធិកាបូនសម្រាប់ព្រៃឈើដែលបានដាក់បញ្ចូលទៅក្នុងគម្រោងរេដបូក (REDD+) គឺនៅជាមួយនឹងសហព័ន្ធម៉ាវផ្លាងវេលហ្វែសូសាយអឹធី និង កាស៊ីនជុកហ៊ីម៉ាអាលីយ៉ាងវ៉ាហ៍យូមីយ៉ាំ (Ka Synjuk Ki Hima Arliang Wah Umiam, Mawphlang Welfare Society Federation)។ គម្រោងរេដ នៅសហគមន៍ខ្ពង់រាបខាស៊ី (The Khasi Hills Community REDD Project) ត្រូវបានទទួលស្គាល់ ក្រោមបទដ្ឋានឬស្តង់ដារនៃផែនការវីវ៉ូ (Plan Vivo standards) (នៅទីក្រុងអ៊ីឌីនប៊ើកហ៍ ចក្រភពអង់គ្លេស (Edinburgh, UK)) នៅខែមីនា ឆ្នាំ២០១៣។ នៅខែមិថុនា ឆ្នាំ២០១៣ មានវិញ្ញាបនប័ត្រទូទាត់កាបូន (carbon offset certificates) ចំនួន២១.៨០៥សន្លឹកបានចេញនៅក្នុងបញ្ជីចុះឈ្មោះម៉ាគីត (Markit Registry) ដែលជាប្រព័ន្ធរក្សាទិន្នន័យមួយរបស់វិស័យឯកជនសម្រាប់តាមដានលើការចេញឥណទានសំរាប់គម្រោងរេដបូក (REDD+ credits)។ ឯកសារគម្រោងបានលើកឡើងថាគម្រោងនេះកំពុងតែឈានចូលដល់ដំណាក់កាលទីពីរនៃការអនុវត្តហើយ នៅក្នុងឆ្នាំ២០១៧។

ខណៈដែលឯកសារនៅលើបណ្តាញអ៊ីធើណេត (អនឡាញ) មានផ្ទុកនូវគ្រប់ព័ត៌មានទាំងនេះ ដូចដែលបានដាក់ជាចំណុចយោងខាងលើ ប្រជាជននៅមូលដ្ឋានដែលជា «ម្ចាស់» ពិតប្រាកដរបស់ ព្រៃព្រឹក្សាពុំបានដឹងថារេដបូក (REDD+) គឺជាអ្វីនោះទេ។ មានអ្នកភូមិជាច្រើនបានដាំដំណាំនៅលើកូនភ្នំតូចៗ។ ប៉ុន្តែនៅពេលដែលគម្រោងរេដបូក (REDD+) បានចាប់ផ្តើមពួកគេត្រូវដើរមើលរក កន្លែងផ្សេងទៀតដើម្បីដាំដំណាំរបស់ពួកគេ។ គម្រោងរេដបូក (REDD+) នេះផ្តល់អត្ថប្រយោជន៍តិចតួចណាស់ដល់អ្នកភូមិ។

គម្រោងរេដបូក (REDD+) ថ្មីមួយទៀតដែលគ្របដណ្តប់លើតំបន់មួយមានទំហំ ៤៤.៣៩១ហិចតា មានទីតាំងស្ថិតនៅក្នុងស្រុកអៃហ្សាវល៍ (Aizawl) និងស្រុកម៉ាមិត (Mamit) នៃតំបន់មីហ្សូរ៉ាម (Mizoram)។ កម្មវិធីថ្មីនេះត្រូវបានអនុវត្តរួមគ្នាដោយក្រុមប្រឹក្សាស្រាវជ្រាវនិងអប់រំអំពីព្រៃឈើរបស់ឥណ្ឌា (ICFRE)) មជ្ឈម

ណ្ឌលអន្តរជាតិដើម្បីការអភិវឌ្ឍភ្នំរួមគ្នា (ICIMOD)) ប្រទេសនេប៉ាល់ និងភ្នាក់ងារសម្រាប់សាជីវកម្មអន្តរជាតិអាល្លឺម៉ង់ (ជីអាហ្សែត/GIZ)។(៥) ជាមួយនឹងគម្រោងរេដបូកម៉ាវផ្លាង អ្នកភូមិនិងអ្នកទទួលបន្ទុកការងារការិយាល័យនៃក្រុមប្រឹក្សាភូមិ បានទទួលព័ត៌មានតិចតួចឬក៏មិនបានទទួល ព័ត៌មានទាល់តែសោះអំពីគម្រោងរេដបូក ពីដំណើរការនិងផលប៉ះពាល់របស់វា។ នៅក្នុងឯកសាររបស់ពួកគេ គម្រោងរេដបូក ត្រូវបានបង្ហាញថាជាវិធីសាស្ត្រមួយដែលអាចធ្វើបានក្រៅពីការធ្វើចម្ការវិលជុំ ហើយថាសកម្មភាពនៃការទូទាត់សងនូវកាបូនព្រៃឈើថ្មីៗទាំងនេះ អាចបំពេញនូវតម្រូវការហិរញ្ញវត្ថុរបស់ភូមិបាន។ នៅក្នុងភូមិចំនួនពីរដែលអ្នកនិពន្ធបានចុះទៅទស្សនកិច្ចនាពេលកន្លងមកនេះ ព្រៃដែលមានស្រាប់ត្រូវបានអភិរក្សអស់ជាច្រើនឆ្នាំក្រោមគំនិតផ្តួចផ្តើមរបស់ភូមិ មុនពេលដែលមានគម្រោងរេដបូក ចូលមកដល់ទៅទៀត។ គម្រោងកាបូនបានរកផលចំណេញ និង «បានក្តោបក្តាប់យកព្រៃ» ពីអ្នកភូមិដែលជាអ្នកខិតខំប្រឹងប្រែងយ៉ាងខ្លាំង និងមានការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តក្នុងការការពារព្រៃឈើតាំងពីយូរមកហើយ មុនពេលដែលគម្រោងរេដបូក នេះមកដល់ទៅទៀត។ នេះគឺជាយុគសម័យថ្មីមួយដែលសហគមន៍បាត់បង់នូវការគ្រប់គ្រងព្រៃរបស់ពួកគេទៅឲ្យអង្គការខាងក្រៅទៅវិញ។

សកម្មភាពទីពីរដែលបានលើកកម្ពស់ក្នុងនាមការពារអាកាសធាតុ ដែលសកម្មភាពនេះបានប៉ះពាល់ដល់ព្រៃនិងជីវភាពរស់នៅរបស់ប្រជាជននៅភូមិភាគឥសាននោះ គឺជាចម្ការដំណាំឧស្សាហកម្មយកប្រេងរុក្ខជាតិដែលភាគច្រើនគឺល្ហុងខ្វង។ គណកម្មការរៀបចំផែនការរបស់រដ្ឋាភិបាលឥណ្ឌាបានបង្កើតនូវគណកម្មាធិការសម្រាប់លើកកម្ពស់ដំណាំឧស្សាហកម្មយកប្រេងរុក្ខជាតិ ដោយពួកគេបានវិនិយោគទៅលើការអភិវឌ្ឍផលិតផល ការសិក្សាលើផ្នែកវិស្វកម្ម ការសម្រួលលើបទបញ្ញត្តច្បាប់ ការកំណត់ប្រភេទជាក់លាក់នៃដំណាំឧស្សាហកម្ម និងការធ្វើទីផ្សារជាដើម។ នៅភូមិភាគឥសាន ក្រុមហ៊ុន ឌីវ័ន វីល្លាមសុន មេហ្គ័រ (D1-Williamson Magor) ដែលជាក្រុមហ៊ុនចូលរួមបណ្តាក់ទុន គឺជាអ្នកឃោសនាចម្បងពីដំណាំល្ហុងខ្វង។ ក្រុមហ៊ុន ឌីវ័ន អ័លស៍ ត្រេដឌីង អ៊ែលធីឌី យូខេ (D1 Oils Trading Ltd.,U.K.) គឺជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនដំបូងគេបង្អស់ដែលទទួលបានដីសម្រាប់ធ្វើផលិតកម្មប្រេងរុក្ខជាតិ ហើយវីល្លាមសុន មេហ្គ័រ (Williamson Magor) គឺជាក្រុមអ្នកដាំតែដ៏ធំជាងគេបំផុតនៅឥណ្ឌា។ ពួកគេមានផែនការពង្រីកបន្ថែមធំមួយ ដែលមិនត្រឹមតែសម្រាប់ចម្ការដំណាំល្ហុងខ្វងក្នុងភូមិភាគឥសានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រីកនៅទូទាំងប្រទេសនៅអាស៊ី និងអាហ្វ្រិច។ គ្រាន់តែនៅក្នុងភូមិភាគឥសានតែមួយ ពួកគេបានប្រកាសនូវផែនការដាំល្ហុងខ្វងលើផ្ទៃដី១០ម៉ឺនហិចតា ហើយកសិករនិងអ្នកភូមិដែលធ្វើចម្ការវិលជុំ (ជុំម្ចាស់/*Jhumias*) ត្រូវបានទាក់ដោយកម្ចីឥណទានពីធនាគារ និងការធានាទិញយកទិន្នផលមកវិញ ។ ដូចនៅកន្លែងផ្សេងៗទៀតដែរ ការពិសោធលើដំណាំល្ហុងខ្វងហាក់ដូចជាបរាជ័យ ប៉ុន្តែការចំណាយគឺធ្លាក់ទៅលើអ្នកភូមិ ហើយគ្មានប្រេងល្ហុងខ្វងសម្រាប់លក់នោះទេ។ ចំណែកទីតាំងចម្ការដំណាំវិញ គឺគ្រប់ដណ្តប់ដោយរុក្ខជាតិដែលមានជាតិពុល។ ការធ្វើទស្សនកិច្ចនៅទីតាំងផ្ទាល់ បានបង្ហាញថាដីស្រែដែលបានបោះបង់ចោល និងដីចម្ការវិលជុំ (*jhum* lands) ត្រូវបានគ្របដណ្តប់ដោយដើមល្ហុងខ្វង។ អ្វីដែលជាការភ័ន្តច្រលំខ្លាំងបំផុតនោះ គឺថាអ្នកភូមិនិងសហគមន៍ទាំងនោះដែលជាអ្នករួមចំណែកធ្វើឲ្យមានការប្រែប្រួលអាកាសធាតុយ៉ាងតិចតួចជាងគេបំផុត បែរជាត្រូវបានស្នើឲ្យទទួលយកនូវកិច្ចការដ៏សំខាន់ក្នុងការកាត់បន្ថយការបំភាយកាបូនដ៏តិចតួចរបស់ពួកគេទៅវិញ។ មានព័ត៌មានថាការពង្រីកឧស្សាហកម្មប្រេងរុក្ខជាតិ នឹងចាប់ផ្តើមដាក់ឲ្យដំណើរការឡើងវិញ ជាមួយនឹងកម្លាំង

ថាមពលថ្មី។ ប្រសិនបើផែនការទាំងនេះចេញជារូបរាងមែននោះ វានឹងជាដំណឹងអាក្រក់សម្រាប់ព្រៃឈើ និងផលិតផលស្បៀងសម្រាប់ចិញ្ចឹមជីវិតនៅតាមមូលដ្ឋាននោះ។

*រ៉ាម វ៉ាំងខៃរ៉ាក់ផាំ* (***Ram Wangkheirakpam*** ) wangkheilakpa(at)gmail.com
នាយកប្រតិបត្តិនៃទស្សនៈវិស័យរបស់ជនជាតិដើមភាគតិច អ៊ីមផាល (Imphal) ម៉ានីពួរ (Manipur)

(១) អត្ថបទមួយស្ដីពីការសម្រេចចិត្តរបស់តុលាការកំពូលក្នុងការហាមឃាត់មិនឲ្យមានការរុករករ៉ែធ្យូងថ្មនៅក្នុងភូមិភាគឥសាន (NE) នៃប្រទេសឥណ្ឌា អាចរកបាននៅ៖
http://www.downtoearth.org.in/news/meghalaya-suspends-rathole-coal-mining-44432

(២) http://kanglaonline.com/2011/09/pil-seeking-rs-1000-crore-compensation-filed-for-oil-spill-in-nagaland/

(៣) ការសិក្សារបស់ធនាគារពិភពលោកស្ដីពី «ធនធានធម្មជាតិ ទឹកនិងទំនាក់ទំនងបរិស្ថាន (Environment Nexus) ដើម្បីការអភិវឌ្ឍនិងការរីកចម្រើននៅភូមិភាគឥសាននៃប្រទេសឥណ្ឌា» ការសិក្សាពីប្រវត្តិ «ហិរញ្ញវត្ថុកាបូន និងវិស័យព្រៃឈើនៅភូមិភាគឥសានរបស់ឥណ្ឌា» និង «ការពិនិត្យឡើងវិញលើវិស័យព្រៃឈើនៅភូមិភាគឥសានរបស់ឥណ្ឌា»

(៤) រេដបូក (REDD+) នៅក្នុងប្រទេសឥណ្ឌា និងគម្រោងរេដបូកដំបូងបំផុតរបស់ឥណ្ឌា៖ការពិសោធដ៏សំខាន់មួយ។ រាយការណ៍ដោយស៊ូមីត្រា ហ្គូសហ៍ (Soumitra Ghosh)។ អាចរកបាននៅ៖
http://www.redd-monitor.org/wp-content/uploads/2011/11/03_Mausam_Sept-2011.pdf ;
សេចក្ដីសង្ខេប និងការអត្ថាធិប្បាយដោយអ្នកត្រួតពិនិត្យកម្មវិធីរេដ (REDD-Monitor) ហើយអាចរក បាននៅ៖
http://www.redd-monitor.org/2011/11/29/indias-first-redd-project-in-the-east-khasi-hills-when-you-say-that-i-need-permission-to-cut-my-own-tree-i-have-lost-my-right-to-my-land/

(៥) មីហ្សូរ៉ាំ (Mizoram) ត្រូវបានជ្រើសរើសសម្រាប់អនុវត្តគម្រោងរេដបូក
http://www.mizoramtourism.org/mizoram-news/mizoram-selected-among-others-for-redd-project ហើយគំនិតផ្ដួចផ្ដើម ICFRE ស្ដីពីរេដបូក (REDD+) យ៉ាងហោចណាស់មាន ១០ផ្ទាំង (ស្លែដ៍/slides) សំដៅលើគម្រោងរេដបូក (REDD+ project) នៅមីហ្សូរ៉ាំ។ អាចរកបាននៅ:
http://www.ignfa.gov.in/photogallery/documents/REDD-plus%20Cell/Modules%20for%20forest%20&%20Climate%20Change2016/Presentations/Resource%20Persons/TPSingh_IGNFA18Oct2016.pdf

# ឥណ្ឌូនេស៊ី៖
# ច្បាប់ដែលបានស្នើឡើងបានគំរាមនឹងផ្តល់ឲ្យក្រុមហ៊ុនសាជីវកម្មគ្រប់គ្រងឡើងវិញលើកសិជីវៈចម្រុះ

នៅឆ្នាំ២០១២ តុលាការធម្មនុញ្ញនៃសាធារណរដ្ឋឥណ្ឌូនេស៊ីបានថ្លែងចាត់ទុកជាមោឃៈលើមាត្រាសំខាន់ៗ នៃច្បាប់ឆ្នាំ១៩៩២មួយស្តីពីប្រព័ន្ធរុក្ខវប្បកម្ម ។ មាត្រាទាំងនេះបានហាមឃាត់កសិករមិនឲ្យបន្តការអនុវត្តតាមក្បួនចាស់បុរាណក្នុងការទុក និងបង្កាត់រុក្ខជាតិ ពោលគឺការអនុវត្តដែលបាននាំឲ្យកើតមាននូវកសិជីវៈចម្រុះយ៉ាងច្រើនសន្ធឹកសន្ធាប់រហូតមកដល់សព្វថ្ងៃនេះ។ (១) នាពេលបច្ចុប្បន្ន ច្បាប់ដែលបានស្នើឡើងស្តីពីការអភិរក្សនិងជីវៈចម្រុះ និងច្បាប់ស្តីពីដូងប្រេង កំពុងតែគំរាមកំហែងនឹងផ្តល់ឲ្យមានការគ្រប់គ្រងឡើងវិញដោយក្រុមហ៊ុនសាជីវកម្មលើភាពសម្បូរបែបនៃដំណាំកសិកម្ម ដែលនេះត្រូវបានចោទក្រមនៅតុលាការធម្មនុញ្ញចាត់ទុកថាមិនស្របតាមរដ្ឋធម្មនុញ្ញទេនៅក្នុងសាលក្រមឆ្នាំ២០១២។ បើអនុម័តព្រមគ្នា ច្បាប់ដែលស្នើឡើងទាំងពីរនេះ នឹងបន្តទៅមុខកាន់តែជ្រៅ ពោលគឺច្បាប់ទាំងនេះនឹងដាក់កម្រិតសហគមន៍នូវលទ្ធភាពទទួលបាន ប្រើប្រាស់និងបង្កាត់រុក្ខជាតិ ដែលរុក្ខជាតិនោះត្រូវបានការពារដោយច្បាប់ ឬរុក្ខជាតិដែលក្រុមហ៊ុនបានចុះប៉ាតង់រួចហើយ។

នៅចន្លោះឆ្នាំ១៩៨០និងឆ្នាំ២០០០ រដ្ឋាភិបាលឥណ្ឌូនេស៊ីបានធ្វើការជំរុញយ៉ាងខ្លាំងនូវការធ្វើកសិកម្មបែប «ទំនើបកម្ម» ដែលស្តែងចេញតាមរយៈការប្រើប្រាស់ជីគីមី គ្រាប់ពូជបង្កាត់ ថ្នាំសម្លាប់សត្វល្អិត ត្រាក់ទ័រ និងម៉ាស៊ីនធុនធ្ងន់ផ្សេងៗទៀត។ ជាផ្នែកមួយនៃ «ទំនើបកម្ម»នោះ រដ្ឋាភិបាលបានចេញនូវច្បាប់លេខ១២នៃច្បាប់ឆ្នាំ១៩៩២ ស្តីពីប្រព័ន្ធរុក្ខវប្បកម្ម ។ ច្បាប់នេះត្រូវបានអនុម័តដោយគ្មានការពិគ្រោះយោបល់ជាមួយនឹងសមាគមកសិករ ឬសហគមន៍កសិកម្មជាមុននោះទេ បើទោះបីវាមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ទៅលើជីវិតរស់នៅរបស់ពួកគេក្តី។ ច្បាប់នេះបានហាមឃាត់កសិករមិនឲ្យបង្កាត់រុក្ខជាតិដែលប្រើប្រាស់សម្រាប់ជាដំណាំកសិកម្ម ឬក៏រុក្ខជាតិជាឱសថដែលក្រុមហ៊ុនសាជីវកម្មបានចុះប៉ាតង់ហើយ។ ប៉ុន្តែការទុកពូជ និងការបង្កាត់រុក្ខជាតិរបស់កសិករ គឺជាផ្នែកដ៏ចាំបាច់មួយនៅក្នុងប្រព័ន្ធធ្វើកសិកម្ម និងជាសសរគ្រឹះនៃអារ្យធម៌ផងដែរ។

ត្រឹមឆ្នាំ២០១១ មានកសិករជាច្រើនដែលបានបន្តអនុវត្តនូវការបង្កាត់រុក្ខជាតិដែលជាប្រភេទស្បៀងអាហារ ត្រូវបានជាប់ទោសបន្ទាប់ពីរងការប្តឹងពីក្រុមហ៊ុនសាជីវកម្ម ដែលអះអាងថាខ្លួនគឺជាម្ចាស់កម្មសិទ្ធិប៉ាតង់លើរុក្ខជាតិទាំងនោះ។ (២) សេចក្តីសម្រេចរបស់តុលាការធម្មនុញ្ញ លេខ៩៩នៃឆ្នាំ២០១២ បានប្រកាសទុកជាមោឃៈនូវមាត្រាទាំងនោះក្នុងច្បាប់ឆ្នាំ១៩៩២ ដែលបានផ្តល់នូវសិទ្ធិផ្តាច់មុខលើរុក្ខជាតិនិងគ្រាប់ពូជសម្រាប់ប្រើក្នុងវិស័យកសិកម្មដល់ក្រុមហ៊ុនសាជីវកម្ម។ កសិករត្រូវបានអនុញ្ញាតឲ្យជាថ្មីម្តងទៀតដោយគ្មានហានិភ័យនៃការដាក់ទោសទណ្ឌ ក្នុងការទុកពូជ និងការបង្កាត់រុក្ខជាតិដែលពួកគេត្រូវប្រើ ដូចដែលពួកគេធ្លាប់បានធ្វើកន្លងមក។

នៅក្នុងឆ្នាំ២០១៦ ច្បាប់ដែលបានស្នើទាំងពីរនេះ ត្រូវបានណែនាំក្នុងប្រទេសឥណ្ឌូនេស៊ី ដែលច្បាប់មួយស្តីពីការអភិរក្សនិងជីវៈចម្រុះ និងច្បាប់មួយទៀតគឺស្តីពីដូងប្រេង។ សេចក្តីព្រាងច្បាប់ស្តីពីការអភិរក្សនិងជីវៈចម្រុះ បានណែនាំជាថ្មីម្តងទៀតពីភាពផ្តាច់មុខរបស់ក្រុមហ៊ុនសាជីវកម្មលើការបង្កាត់រុក្ខជាតិ ដែលស្រដៀងគ្នានឹងសិទ្ធិក្រុមហ៊ុនសាជីវកម្មមានចែងនៅក្នុងមាត្រារបស់ច្បាប់លេខ១២នៃឆ្នាំ១៩៩២ (មាត្រាដែលបានប្រកាសទុកជាមោឃៈដោយតុលាការធម្មនុញ្ញនៅក្នុងឆ្នាំ២០១២)។ ជាងនេះទៅទៀត ច្បាប់ដែលបានស្នើឡើងស្តីពីការអភិរក្សនិងជីវៈចម្រុះ នឹងហាមឃាត់មិនឲ្យសហគមន៍អាចទៅរកប្រើប្រាស់ ឬបង្កាត់នូវប្រភេទរុក្ខជាតិមួយចំនួន ដែលមានចុះនៅក្នុងបញ្ជីឧបសម្ព័ន្ធពីការអភិរក្ស ឬក៏សម្រាប់ក្រុមហ៊ុនដូចជា ក្រុមហ៊ុនផលិតឱសថ ឬក្រុមហ៊ុនដូងប្រេងដែលបានដាក់ប័ណ្ណប៉ាតង់រួច។ នៅក្រោម *អាដេត* (ច្បាប់ប្រពៃណីទំនៀមទម្លាប់) សហគមន៍ត្រូវបានអនុញ្ញាតឲ្យប្រើនូវប្រភេទរុក្ខជាតិការពារមួយចំនួន ដែលធ្លាប់បានប្រើតាំងពីបុរាណមកម្ល៉េះ ឧទាហរណ៍ ក្នុងការប្រើប្រាស់ជាឱសថបុរាណ ប្រសិនបើពួកគេបានចុះបញ្ជីប្រភេទរុក្ខជាតិទាំងនេះជា «ធនធាន»បង្កាត់ សម្រាប់ការប្រើប្រាស់តាមបែបប្រពៃណីជាមួយនឹងអាជ្ញាធររដ្ឋ។

ការហាមឃាត់ទាំងនេះដែលមានក្នុងច្បាប់ស្នើឡើង គឺហាក់ដូចជាមុខទាំងសងខាងរបស់កាក់មួយពោលគឺទោះបីជាអ្នកបង្វែរទៅម្ខាងណាក៏ដោយ ច្បាប់នេះនឹងប៉ះពាល់ដល់ច្បាប់*អាដេត*របស់សហគមន៍ដែរ។ ប្រសិនបើសហគមន៍ប្រើប្រាស់នូវរុក្ខជាតិទាំងនេះដោយគ្មានការអនុញ្ញាតពីរដ្ឋាភិបាលទេ ពួកគេនឹងប្រឈមមុខនឹងបទឧក្រិដ្ឋ។ ប្រសិនបើសហគមន៍ស្នើសុំនូវការអនុញ្ញាតប្រើប្រាស់ វានឹងក្លាយជាហានិភ័យធំមួយដោយកម្មសិទ្ធិបញ្ញាតាមបែបប្រពៃណីទំនៀមទម្លាប់របស់ពួកគេលើធនធានឱសថចេញពីរុក្ខជាតិនោះ នឹងត្រូវបានលួចយកទៅដោយក្រុមហ៊ុនសាជីវកម្មឱសថ មុនពេលដែលចំណេះដឹងរបស់សហគមន៍ត្រូវបានទទួលស្គាល់ត្រឹមត្រូវតាមលក្ខត្តិកៈនៃច្បាប់ដែលបានស្នើមក។ ក្រុមហ៊ុនសាជីវកម្មកំពុងតែប្រមាញ់រកនូវព័ត៌មានអំពីការប្រើប្រាស់រុក្ខជាតិជាឱសថបុរាណនេះ ដែលសហគមន៍បានដាក់បញ្ចូលទៅក្នុងបែបបទស្នើសុំសិទ្ធិប្រើប្រាស់របស់ពួកគេ។ ដំបូង សហគមន៍អាចទទួលបានការអនុញ្ញាតឲ្យប្រើប្រាស់ ប៉ុន្តែក្រោយមក ក្រុមហ៊ុននឹងចុះប៉ាតង់ ហើយការប្រើប្រាស់និងការបង្កាត់រុក្ខជាតិតាមបែបប្រពៃណីនឹងត្រូវបានហាមឃាត់តាមច្បាប់ ដោយសារមានស្ថាប័ន(ក្រុមហ៊ុនសាជីវកម្ម) មួយផ្សេងទៀតបានចុះប៉ាតង់លើរុក្ខជាតិនោះហើយ។ ទោះជាតាមរបៀបណាក៏ដោយ ច្បាប់ដែលបានស្នើឡើងស្តីពីការអភិរក្សនិងជីវៈចម្រុះនេះ បានបង្ហាញនូវការគំរាមកំហែងយ៉ាងធំមួយដល់ការប្រើប្រាស់ និងការបង្កាត់រុក្ខជាតិរបស់សហគមន៍ ទោះរុក្ខជាតិទាំងនោះត្រូវបានប្រើប្រាស់តាមបែបប្រពៃណីសម្រាប់បរិភោគជាចំណីអាហារ ឬក៏ថ្នាំសង្កូវក្តី។

តាមប្រវត្តិសាស្ត្រ មានករណីរួចមកហើយទាក់ទងទៅនឹងចំណេះដឹងរបស់ប្រជាជនឥណ្ឌូនេស៊ីអំពីឱសថផ្សំពីជីបែបបុរាណ ដែលត្រូវបានដណ្តើមយកទៅដោយក្រុមហ៊ុនឱសថ។ បន្ទាប់មក ព័ត៌មាននេះត្រូវបានយកទៅធ្វើជាពាណិជ្ជកម្ម ហើយដាក់ប៉ាតង់ដោយក្រុមហ៊ុនឧស្សាហកម្ម ដោយគ្មានការយល់ព្រមពីអ្នកប្រើប្រាស់តាមបែបបុរាណ និងអ្នកដែលមានចំណេះដឹងពីឱសថបុរាណនេះឡើយ។ ឱសថជីបុរាណដែលប្រើសម្រាប់ព្យាបាលជំងឺផ្សេងៗ ក៏ត្រូវបានប្រើប្រាស់សម្រាប់ការស្រាវជ្រាវជាន់ខ្ពស់បែបស៊ីជម្រៅ ផងដែរ។

ការស្រាវជ្រាវនេះ និងការប្រែក្លាយទៅជាមុខជំនួញពាណិជ្ជកម្មបែបនេះ បានបង្កទៅជាការលួចកម្មសិទ្ធិបញ្ញា ពីព្រោះការជ្រើសរើសប្រភេទដីណាមួយសម្រាប់ធ្វើជាថ្នាំព្យាបាលជំងឺជាក់លាក់ណាមួយនោះ និងធាតុផ្សំ ព្រម ទាំងការអនុវត្តនានាដើម្បីផលិតនិងប្រើប្រាស់ថ្នាំបុរាណទាំងនេះ គឺជាលទ្ធផលនៃការស្រាវជ្រាវជាបន្តបន្ទាប់ ដែលធ្វើឡើងដោយសមាជិករបស់សហគមន៍ ហើយបានផ្ទេរពីមួយជំនាន់ទៅមួយជំនាន់។ ប៉ុន្តែចំណេះដឹងនេះ មិនត្រូវបានទទួលស្គាល់ថាជាការស្រាវជ្រាវស៊ីជម្រៅនោះទេ ពីព្រោះវាមិនបានធ្វើទៅតាមគោលការណ៍នៃការ ស្រាវជ្រាវជាន់ខ្ពស់នាសម័យបច្ចុប្បន្ននេះ។

គោលបំណងរបស់ច្បាប់ដែលស្នើឡើងស្តីពីដូងប្រេង គឺដើម្បីកំណត់ន័យដូងប្រេងជាប្រភេទរុក្ខជាតិមួយ ដែលដុះដោយឯកឯងតាមធម្មជាតិនៅក្នុងប្រទេសឥណ្ឌូនេស៊ី។ ប៉ុន្តែគោលបំណងនេះនឹងបិទបាំងនូវការពិត ដែលដូងប្រេងជាប្រភេទរុក្ខជាតិមួយមានដើមកំណើតនៅភាគខាងលិចនិងភាគកណ្តាលនៃទ្វីបអាហ្វ្រិចដែលត្រូវ បានដាំដុះនិងប្រើប្រាស់សម្រាប់ជាផលិតផល និងការប្រើប្រាស់នានា ហើយត្រូវបានណែនាំមកប្រទេស ឥណ្ឌូនេស៊ីដោយឧស្សាហកម្មដូងប្រេង។(៣) នៅពេលដូងប្រេងត្រូវបានចាត់ចូលជាប្រភេទរុក្ខជាតិដុះដោយ ឯកឯងតាមធម្មជាតិនៅក្នុងប្រទេសឥណ្ឌូនេស៊ីនោះ ក្រុមហ៊ុនចម្ការដូងប្រេងអាចដាក់ប៉ាតង់លើវា ហើយជា មួយនឹងមាត្រា១៥ នៃច្បាប់ដែលបានស្នើឡើងស្តីពីការអភិរក្សនិងជីវៈចម្រុះ អាចឲ្យពួកគេរិតត្បិតសហគមន៍ ពីការប្រើប្រាស់ដូងប្រេងយកផ្លែ ដែលក្រុមហ៊ុនមានចំណាប់អារម្មណ៍ក្នុងការទិញផ្លែនោះដែរ។ ប៉ុន្តែការប្រើ ប្រាស់របស់សហគមន៍នូវផ្នែកផ្សេងទៀតរបស់រុក្ខជាតិនេះ អាចនឹងត្រូវបានហាមឃាត់ នៅពេលដូងប្រេងត្រូវបាន ប្រកាសថាជាប្រភេទរុក្ខជាតិដុះតាមធម្មជាតិនៅក្នុងប្រទេសឥណ្ឌូនេស៊ី ដែលច្បាប់ស្នើឡើងស្តីពីការអភិរក្សនិង ជីវៈចម្រុះក៏អាចនឹងត្រូវអនុវត្តលើនោះផងដែរ។ ដូចនេះ ការប្រកាសថាដូងប្រេងគឺជាប្រភេទរុក្ខជាតិដែលដុះតាម ធម្មជាតិនៅឥណ្ឌូនេស៊ី អាចនឹងនាំឲ្យមានការដណ្តើមយកដីធ្លីរបស់កសិករដែលដាំដូងប្រេងនៅលើដីរបស់ ពួកគេ និងសហគមន៍ដែលរស់នៅជុំវិញចម្ការរបស់ក្រុមហ៊ុនសាជីវកម្មជាលើកទីពីរ ពីព្រោះក្រុមហ៊ុនដូងប្រេង អាចដាក់កំណត់លើការប្រើប្រាស់របស់សហគមន៍លើដូងប្រេងត្រឹមតែផ្លែរបស់វានោះទេ ដែលជាផ្នែកមួយ ក្រុមហ៊ុនមានចំណាប់អារម្មណ៍លើ។ ប្រសិនបើច្បាប់ទាំងនេះត្រូវអនុម័ត វាក៏នឹងកាន់តែលំបាកសម្រាប់កសិករ ក្នុងការទាមទារដីរបស់ពួកគេមក វិញ។

ប្រសិនបើច្បាប់ដែលបានស្នើឡើងទាំងពីរនេះត្រូវបានពិចារណារួមគ្នានោះ វានឹងកាន់តែច្បាស់ថា ចេតនារបស់រដ្ឋាភិបាល គឺមិនមែនដោះស្រាយបញ្ហាបន្ទាន់មួយចំនួនដែលកំពុងតែប៉ះពាល់លើសហគមន៍ មូលដ្ឋាននៅក្នុងប្រទេសឥណ្ឌូនេស៊ីនោះទេ។ ផ្ទុយមកវិញ ច្បាប់ដែលបានស្នើឡើងនេះ សំដៅឲ្យក្រុមហ៊ុន សាជីវកម្មគ្រប់គ្រងកាន់កាប់កាន់តែច្រើនទៀតទៅលើកសិជីវៈចម្រុះ និងដីដែលជាប្រយោជន៍ដល់ពួកគេ។ ការផ្លាស់ប្តូរច្បាប់ទាំងនេះត្រូវបានមើលឃើញប្រាកដណាស់ថាជាយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនសាជីវកម្ម ដែលត្រូវ បានគ្រោងទុកនិងរៀបចំយ៉ាងល្អ ដើម្បីពង្រីកវិសាលភាពនៃការគ្រប់គ្រងរបស់ខ្លួនដែលមិនត្រឹមតែការគ្រប់គ្រង លើដីសហគមន៍ប៉ុណ្ណោះទេ ថែមទាំងលើការប្រើប្រាស់ «ជីវៈចម្រុះ» របស់សហគមន៍ផងដែរ។ ការស្នើនូវ បទប្បញ្ញត្តិដូចជាច្បាប់ដែលបានស្នើឡើងទាំងពីរ ដែលមួយស្តីពីការអភិរក្សនិងជីវៈចម្រុះ និងមួយទៀតស្តីពីដូង ប្រេងនៅឥណ្ឌូនេស៊ី ត្រូវបានមើលឃើញយ៉ាងច្បាស់ថា ជាផ្នែកមួយនៃរឹបអូសយកនូវប្រភពនៃជីវិតរបស់ប្រជា

ជនដោយស្របច្បាប់។ ការអនុម័តលើច្បាប់ទាំងនេះក៏នឹងផ្តល់នូវការការពារដោយស្របច្បាប់ផងដែរ ប្រសិនបើគ្មាននិទណ្ឌភាពលើបទឧក្រិដ្ឋដែលក្រុមហ៊ុនសាជីវកម្ម ចំពោះការលួចយកចំណេះដឹងបែបប្រពៃណីអំពីការប្រើប្រាស់រុក្ខជាតិដែលសហគមន៍បានរក្សាទុក និងផ្ទេរពីមួយជំនាន់ទៅមួយជំនាន់ពោលគឺ តុលាការធម្មនុញ្ញរបស់ឥណ្ឌូនេស៊ីបានធ្វើការសម្រេចរួចហើយថា ភាពផ្តាច់មុខលើការបង្កាត់និងការប្រើប្រាស់រុក្ខជាតិគឺមិនមាននៅក្នុងរដ្ឋធម្មនុញ្ញនោះទេ។ យ៉ាងណាមិញ រដ្ឋាភិបាលកំពុងតែជួយពន្លឿននូវកម្មវិធីរបស់ក្រុមហ៊ុនសាជីវកម្មដោយបានស្នើឲ្យមានច្បាប់ទាំងពីរនេះឡើង ក្នុងគោលបំណងដើម្បីសម្រួលឲ្យមាននូវការគ្រប់គ្រងផ្តាច់មុខឡើងវិញលើកសិជីវៈចម្រុះ គ្រាប់ពូជ និងភាពចម្រុះនៃសេនេទិចរបស់ពូជរុក្ខជាតិនានា ដែលតុលាការធម្មនុញ្ញឥណ្ឌូនេស៊ីបានប្រកាសរួចជាស្រេចថាមិនមាននៅក្នុងរដ្ឋធម្មនុញ្ញនោះទេ។

គតិបណ្ឌិតតាមបែបប្រពៃណី ឬរបស់សហគមន៍ ដែលមាននៅក្នុងច្បាប់ប្រពៃណីទំនៀមទម្លាប់ *អាដេត* និងភាពសម្បូរបែបដ៏ច្រើនលើសលប់នៃពូជរុក្ខជាតិផ្សេងៗ ដែលត្រូវបានប្រើប្រាស់ដោយសហគមន៍បុរាណនិងកសិករសព្វថ្ងៃនេះ គឺជាការចង្អុលបង្ហាញពីដំណើរការបន្សាំដ៏យូរមួយរវាងធម្មជាតិ ភាពចម្រុះនៃរុក្ខជាតិនិងសហគមន៍។ ជីវៈចម្រុះ នេះ ព្រមទាំងសហគមន៍ដែលបង្កើតវា បន្តការរស់នៅអាស្រ័យផលដោយការប្រើប្រាស់និងការទទួលបានដីដោយសេរីដែលជាទីជម្រនៃរុក្ខជាតិដែលសហគមន៍ប្រើប្រាស់។ ការប្រើប្រាស់និងការទទួលបានដីនិងរុក្ខជាតិដោយសហគមន៍នេះហើយ ដែលច្បាប់ស្តីពីការអភិរក្សនិងជីវៈចម្រុះ និងច្បាប់ស្តីពីដូងប្រេងកំពុងតែបង្កឲ្យមានហានិភ័យលើនោះ ។

បទឧក្រិដ្ឋក្រុមហ៊ុនសាជីវកម្មមិនអាចគ្រាន់តែយល់ថាជាបទឧក្រិដ្ឋនៃការរឹបអូស លួច ឬក៏យកទ្រព្យសម្បត្តិរបស់រដ្ឋតែប៉ុណ្ណោះទេ។ ជាងនេះទៅទៀត ការគ្រប់គ្រងរបស់ក្រុមហ៊ុនសាជីវកម្មតាមរយៈច្បាប់ និងការការពារកម្មសិទ្ធិបញ្ញាដែលផ្តល់ឲ្យក្រុមហ៊ុនសាជីវកម្មនូវភាពផ្តាច់មុខមួយលើរុក្ខជាតិនិងគ្រាប់ពូជ បានរឹបអូសយកដីរបស់សហគមន៍ ព្រមទាំងចំណេះដឹងរបស់ពួកគេ លើការប្រើប្រាស់ដីទាំងនេះតាមបែបប្រពៃណី។ បទឧក្រិដ្ឋបែបនេះ បានជំរុញនូវដំណើរការផ្លាស់ប្តូរដល់មូលដ្ឋានគ្រឹះសហគមន៍ពោលគឺ ប្តូរពីម្ចាស់ទៅជាអ្នកប្រើប្រាស់ទៅវិញ ដែលប្រើប្រាស់រុក្ខជាតិនិងគ្រាប់ពូជដែលជាទំនិញស្ថិតក្រោមប៉ាតង់របស់ក្រុមហ៊ុនសាជីវកម្ម។ ច្បាប់ដែលស្នើឡើងស្តីពីការអភិរក្សនិងជីវៈចម្រុះ និងច្បាប់ស្តីពីដូងប្រេង គឺជាផ្នែកមួយនៃដំណើរការដាក់ឲ្យស្របច្បាប់នូវការលួចយកចំណេះដឹងរបស់សហគមន៍និងការប្រើប្រាស់ «ជីវៈចម្រុះ» ដោយក្រុមហ៊ុនសាជីវកម្ម។

*ហ្សិនហ្ស៊ី ស៊ូហាឌី* (*Zenzi Suhadi*)
វ៉ាល់ហ៊ី (WALHI) ប្រធានផ្នែកស្រាវជ្រាវ ការតស៊ូមតិ និងច្បាប់បរិស្ថាន

(១) សេចក្តីសម្រេចចិត្តលេខ 99/PP-X/2012 របស់តុលាការធម្មនុញ្ញបានចាត់ទុកជាមោឃៈចំពោះ មាត្រា ៥ ៦ ៩ ១២ និង៦០ នៃច្បាប់ឆ្នាំ១៩៩២ លេខ១២ ស្តីពីប្រព័ន្ធដាំដុះដំណាំបែបវប្បកម្ម

(២) សូមមើល៖ កសិករឥណ្ឌូនេស៊ីត្រូវបានកាត់ទោសដោយសារតែបង្កាត់គ្រាប់ពូជរបស់ពួកគេ។ http://www.alt.no-patents-on-seeds.org/index.php?option=com_content&task=view&id=59&Itemid=42

(៣) ចំពោះចំណាប់អារម្មណ៍លើភាពសម្បូរបែបនៃការប្រើប្រាស់ប្រភេទដូងប្រេងប្រពៃណីផ្សេងៗគ្នា នៅអាហ្វ្រិចខាងលិចនិងអាហ្វ្រិចកណ្តាល សូមមើលឧទាហរណ៍អំពី «អាហ្វ្រិច៖ ជ្រុងមួយទៀតនៃដូង ប្រេង។

ជាប្រវត្តិដ៏វែងឆ្ងាយមួយ និងភាពទូលំទូលាយនៃជីវៈចម្រុះ» ដោយហ្គ្រេន (GRAIN) https://www.grain.org/article/entries/5035-a-long-history-and-vast-biodiversity និងភាពយន្ត «ស្ត្រីនៅអាហ្វ្រិចការពារចំពោះប្រេងដូងប្រពៃណី» http://www.farmlandgrab.org/post/view/26141-video-west-african-women-defend-traditional-palm-oil

## ប្រយុទ្ធនឹងបណ្តាសានៃសម្បទាននៅកម្ពុជា

ក្រុមហ៊ុនភាពីម៉ិចគ្រុប មានឈ្មោះល្បីរន្ទឺទាំងនៅក្នុងប្រទេសកម្ពុជានិងបរទេសលើផ្នែកគម្រោងវិនិយោគខ្នាតធំ ដែលអនុញ្ញាតឲ្យពួកគេទទួលបាននូវព្រៃឈើ ដី និងទឹកដោយគ្មានការរិតត្បិត រីឯម្ចាស់ក្រុមហ៊ុនវិញគឺជា «ប្តីប្រពន្ធដ៏មានអំណាច» ពីព្រោះតែឥទ្ធិពលនយោបាយនិងហិរញ្ញវត្ថុរបស់ពួកគេ។ (១) អត្ថបទខាងក្រោមដែលបានផ្សាយចេញលើកទីមួយក្នុងព្រឹត្តិបត្ររបស់ចលនាព្រៃស្រោងពិភពលោក កាលពីឆ្នាំ២០១៣ នឹងពិពណ៌នាអំពីដីសម្បទានសេដ្ឋកិច្ចភាពីម៉ិច នៅពាសពេញខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង។ ការសម្បទាននេះត្រូវបានដឹងឮសុសសាយពីភាពអាក្រក់ដែលពួកគេទទួលបានដីក្នុងទំហំដ៏ធំសម្បើម និងការបំផ្លិចបំផ្លាញប្រព័ន្ធអេកូឡូស៊ី ហើយបង្កឲ្យមានជម្លោះជាមួយសហគមន៍មូលដ្ឋានលើដីស្រែ វាលស្មៅ និងដីព្រៃ ព្រមទាំងប្រភពទឹក។

នៅក្នុងឆ្នាំ២០១៦ ក្រោយពីការតស៊ូអស់រយៈពេល១៦ឆ្នាំ សហគមន៍រងគ្រោះនៅក្នុងខេត្តកំពង់ឆ្នាំងបានឈ្នះក្នុងការប្រយុទ្ធប្រឆាំងរបស់ពួកគេជាមួយនឹងក្រុមហ៊ុនភាពីម៉ិច។ ក្រុមហ៊ុនបានយល់ព្រមប្រគល់ដីចំនួន ១៧០.០០០ហិចតា នៃចំនួនផ្ទៃដីសម្បទានសរុបដែលមានប្រហែលជា ១៧៦.០០០ហិចតា ឲ្យទៅអ្នកទាមទារដែលត្រឹមត្រូវស្របច្បាប់។ បើតាមប្រជាជនមូលដ្ឋាន ក្រុមហ៊ុនបានជួបវិបត្តិដោយសារតម្លៃដំឡូងមីបានធ្លាក់ចុះ ការបះបោរពីកម្មករនៅក្នុងចម្ការ និងស្ថានភាពតានតឹងរវាងបុគ្គលិករបស់ក្រុមហ៊ុននិងសហគមន៍រងគ្រោះ។ កម្មករនៅក្នុងចម្ការមិនបានទទួលនូវប្រាក់ឈ្នួលទៀងទាត់ ហើយបានចាប់ផ្តើមបំផ្លាញប្រតិបត្តិការរបស់ក្រុមហ៊ុនដោយលួចយកគ្រឿងបន្លាស់របស់ម៉ាស៊ីនជាដើម។ ចៅហ្វាយខេត្តមានទំនោរគាំទ្រភាគច្រើនលើការទាមទារដីនិងព្រៃរបស់សហគមន៍រងគ្រោះ។

ក្រុមហ៊ុនភាភីម៉ិចមិនទាន់បានដកចេញពីខេត្តពោធិ៍សាត់នៅឡើយទេ ទោះបីជាការប្រតិបត្តិការការងារត្រូវបានកាត់បន្ថយអស់ច្រើនក្តី។ ផ្ទុយពីឆ្នាំមុនៗ បច្ចុប្បន្ននេះមានការដ្ឋានធ្វើការតែប្រាំកន្លែងប៉ុណ្ណោះកំពុងតែដំណើរការ ដោយមានបុគ្គលិកពី២០ទៅ៣០នាក់ ហើយគ្មានបុគ្គលិកមើលថៃ ដំឡូងមីដែលបានដាំរួចមកហើយនោះទេ។ នៅក្នុងឆ្នាំ២០១៦ កម្មករបានចាប់ផ្តើមទាមទារប្រាក់ឈ្នួលមកវិញពីក្រុមហ៊ុន ហើយរបាយការណ៍ថ្មីៗនេះបានបង្ហាញថាការបំផ្លាញប្រឆាំងនឹងប្រតិបត្តិការរបស់ក្រុមហ៊ុនហាក់ដូចជាចាប់ផ្តើមតាំងពីពេលនោះដែរ។ ការសម្បទានដីសេដ្ឋកិច្ច នៅពោធិ៍សាត់ដែលមានផ្ទៃដីចំនួន១៣០.០០០ហិចតា មានដីចំនួន៣០.០០០ហិចតាត្រូវបានឈូសឆាយ។ គេមិនទាន់ដឹងនៅឡើយទេថាតើក្រុមហ៊ុននឹងរក្សាទុកដីក្នុងតំបន់សម្បទានទាំងអស់រហូតដល់ពេលកំណត់សម្បទាន ឬក៏នឹងប្រគល់ដីជម្លោះមកឲ្យសហគមន៍រងគ្រោះវិញដូចដែលបានព្រមព្រៀងគ្នាដូចក្នុងករណីនៅខេត្តកំពង់ឆ្នាំងដែរឬយ៉ាងណា។

ស្ថានភាពពាក់ព័ន្ធនឹងការសម្បទានឲ្យភាពីមិុចនៅខេត្តកំពង់ឆ្នាំង គឺជាជ័យជំនះពេញលេញមួយសម្រាប់សហគមន៍មូលដ្ឋាន ហើយអាចនឹងកើតមានឡើងដូចគ្នាដែរនៅក្នុងខេត្តពោធិ៍សាត់។ ទោះជាយ៉ាងនេះក្តី ក្រុមហ៊ុននិងម្ចាស់ក្រុមហ៊ុន គឺពិបាកនឹងផ្តួលណាស់នៅក្នុងប្រទេស។ ក្រុមហ៊ុនភាពីមិុច បានចូលរួមបណ្តាក់ទុន ជាមួយនឹងក្រុមហ៊ុនវ៉ូហ្ស៊ីហ្សាន អ៊ែលអ៊ែស (Wuzhishan LS) នៅខេត្តមណ្ឌលគិរី ដែលជាក្រុមហ៊ុនដំណាំឧស្សាហកម្មចិនមួយ និងជាមួយក្រុមហ៊ុនអភិវឌ្ឍន៍វិនិយោគទុនកម្ពុជាអន្តរជាតិគ្រុប ដែលជាក្រុមហ៊ុនរុករករ៉ែរបស់ចិន។ (២) ម្ចាស់ក្រុមហ៊ុនភាពីមិុចក៏ជាម្ចាស់របស់ក្រុមហ៊ុនស៊ូកាគូអ៊ីន (Shukaku Inc)ដែរ ដែលជាក្រុមហ៊ុនសាជីវកម្មអភិវឌ្ឍន៍អចលនទ្រព្យនៅលើតំបន់បឹងកក់ និងមានចំណែកយ៉ាងសំខាន់ក្នុងការផ្តល់សម្បទានរ៉ែទៅក្រុមហ៊ុនសាជីវកម្មអាលែកស៍ នៅក្នុងខេត្តមណ្ឌលគិរី។ (៣) ពួកគេក៏មានទំនាក់ទំនងជាមួយនឹងក្រុមហ៊ុនស៊ីណូហាយដ្រូ (កម្ពុជា) យូណាយធីត អ៊ែលធីឌី (Sinohydro (Cambodia) United Ltd) ផងដែរ ដែលជាក្រុមហ៊ុនមួយទទួលបានកិច្ចសន្យាលើគម្រោងទំនប់វារីអគ្គិសនីនៅអារ៉ែង ក្នុងតំបន់ជួរភ្នំក្រវាញ ហើយដែលបច្ចុប្បន្នវាត្រូវបានលុបចោលវិញនោះ។ ការផ្តល់សម្បទានរុករករ៉ែ សម្រាប់ក្រុមហ៊ុនអភិវឌ្ឍន៍វិនិយោគទុនកម្ពុជាអន្តរជាតិគ្រុប មានរួមបញ្ចូលទាំងដីប្រពៃណីដូនតារបស់ក្រុមជនជាតិដើមព្នង ដែលបានបង្ហាញនូវក្តីកង្វល់អំពីផលប៉ះពាល់ទៅលើព្រៃស័ក្តិសិទ្ធិ និងវាលកប់សពរបស់ពួកគេ។ ជនជាតិដើមព្នង ដែលមានចំនួនប្រជាជនប្រហែលពាក់កណ្តាលនៃចំនួនប្រជាជនសរុបក្នុងខេត្តនោះ បានប្រឈមរួចមកហើយនឹងការរំលោភបំពានបែបនេះនៅក្នុងតំបន់ដីសម្បទានរបស់ ក្រុមហ៊ុនវ៉ូហ្ស៊ីហ្សានអ៊ែលអ៊ែស នៅពេលដែលដីប្រពៃណីដូនតារបស់ពួកគេត្រូវរងការប្រមាថពីប្រតិបត្តិការរបស់ក្រុមហ៊ុន។ ដោយមានការគាំទ្រពីសំណាក់បណ្តាញសកម្មជនដើម្បីសិទ្ធិសហគមន៍ដែលកំពុងមានចំនួនការកើនឡើងនោះ ពួកគេកំពុងរៀបចំបញ្ឈប់ប្រតិបត្តិការរបស់ ក្រុមហ៊ុនឲ្យបានមុនពេលដែនដីដូនតារបស់ពួកគេត្រូវបានរំខានឬក៏រំលោភបំពាន។

នៅឆ្នាំ២០១៧ បណ្តាសានៃការផ្តល់សម្បទាននៅតែបន្តនៅប្រទេសកម្ពុជា ហើយការតស៊ូរបស់ប្រជាជនក៏នៅតែបន្តដែរ។ វាប្រៀបដូចជាទំពាំងនិងឫស្សី ដែលប្រជាពលរដ្ឋម្នាក់មកពីក្រាំងស្មៀ ក្នុងខេត្តកំពង់ឆ្នាំងបានលើកឡើងក្នុងអត្ថបទរបស់ព្រឹត្តិបត្ររបស់ចលនាព្រៃស្រោងពិភពលោក ឆ្នាំ២០១៣ ដែលបានចេញផ្សាយឡើងវិញនៅខាងក្រោមនេះ ស្តីពីការតស៊ូរបស់សហគមន៍ប្រឆាំងជាមួយនឹងសម្បទានភាពីមិុច ការតស៊ូរបស់ពួកគេដើម្បីបញ្ចប់នូវបណ្តាសានេះដោយទាមទារដី ព្រៃ និងទឹកមកវិញ ហើយស្តារប្រព័ន្ធអេកូឡូស៊ីដែលរងការខូចខាតឲ្យមានភាពរឹងមាំជាងមុន។

## បណ្តាសានៃសម្បទាននៅកម្ពុជា

*អត្ថបទដែលបានចេញផ្សាយមុនគេនៅក្នុងព្រឹត្តិបត្ររបស់ចលនាព្រៃស្រោងពិភពលោក១៩៣ ខែកញ្ញា ឆ្នាំ២០១៣។*

«ក្រុមហ៊ុនបានសន្យាថានឹងបង្កើនគម្របព្រៃឈើ ប៉ុន្តែពួកគេបែរជាដាំដំឡូងមីទៅវិញ។ ដំឡូងមីមិនមែនជាដើមឈើទេ។ ចម្ការដំណាំដំឡូងមីមួយមិនមែនជាព្រៃទេ។» ប្រជាជនមកពី អន្សាចំបក់ ខេត្តពោធិ៍សាត់ នៃប្រទេសកម្ពុជាបាននិយាយ។

ចាប់តាំងពីឆ្នាំ២០០០មក ប្រជាជននៅក្នុងភូមិជាង១១១ភូមិ បាននិងកំពុងតស៊ូប្រឆាំងនឹងសម្បទានដីយ៉ាងធំសម្បើមមួយ ដែលមានទំហំ ៣១៥.០២៨ ហិចតា នៅទូទាំងខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង នៅប្រទេសកម្ពុជា។ កិច្ចព្រមព្រៀងសម្បទានបានអនុញ្ញាតឲ្យភាពីម៉ិច ដែលជាក្រុមហ៊ុនកម្ពុជាដ៏មានអំណាចមួយក្នុងការដណ្ដើមយកដីស្រែ ដីព្រៃ និងដីសមូហភាព ដើម្បីដាំដើមអាកាស្យា និងដំឡូងមីធ្វើជាចម្ការដំណាំឧស្សាហកម្មវប្បកម្ម (ការដាំដំណាំតែមួយមុខ) ត្រូវបានប្រជាជនកម្ពុជាជាច្រើនចាត់ទុកក្រុមហ៊ុនភាពីម៉ិចគ្រុប (Pheapimex Group) ដែលកាន់កាប់ដោយឈ្មោះ ជឿង សុភាព និងប្ដីឈ្មោះ ឡៅ ម៉េងឃីន ជាសមាជិកព្រឹទ្ធសភាមកពីគណបក្សកាន់អំណាចគឺគណបក្សប្រជាជនកម្ពុជា គឺមិនអាចប៉ះពាល់បានឡើយ ពីព្រោះតែទំនាក់ទំនងយ៉ាងស្អិតរមួតរវាងម្ចាស់ក្រុមហ៊ុននិងនាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន សែន និងការឧបត្ថម្ភដ៏ច្រើនសន្ធឹកសន្ធាប់ពីក្រុមហ៊ុនភាភីម៉ិច ដល់គណបក្សប្រជាជនកម្ពុជា។

ទោះបីជាច្បាប់បច្ចុប្បន្ននេះបានកំណត់នូវទំហំដីសម្រាប់សម្បទានត្រឹម១ម៉ឺនហិចតាក្តីក្រុមហ៊ុនភាពីម៉ិចបានចុះកិច្ចព្រមព្រៀងតាំងពីឆ្នាំ១៩៩៧ដោយសុវត្ថិភាព មុនពេលច្បាប់កំណត់លើដីសម្បទានសេដ្ឋកិច្ច (ELCs) បានបង្កើតទៅទៀត។ ផែនការដំបូងរបស់គេ គឺបង្កើតនូវចម្ការដើមប្រេងខ្យល់ និងកំទេចឬសំណល់ឈើព្រមទាំងរោងម៉ាស៊ីនកិនក្រដាស ដែលស្ថិតក្រោមការសហការជាដៃគូជាមួយនឹងក្រុមហ៊ុនសហប្រតិបត្តិការកសិដ្ឋានចិនគ្រុប និងទទួលហិរញ្ញប្បទានពីធនាគារអាហារណែនីហារណែចិន។ ភាពីម៉ិច (Pheapimex) ក៏ជាដៃគូនៅកម្ពុជារបស់ក្រុមហ៊ុនដំណាំឧស្សាហកម្មវ៉ូហ្ស៊ីហ្សាន (Wuzhishan) របស់ចិនដែរ។ ចាប់តាំងពីចេញច្បាប់ស្តីពីដីសម្បទានសេដ្ឋកិច្ចមក ក្រុមហ៊ុនភាពីម៉ិចបានសហការជាមួយនឹងឈ្មួញកណ្តាល និងក្រុមហ៊ុនផ្សេងៗទៀត ដែលទទួលបានដីក្នុងទំហំកំណត់ដោយច្បាប់ ប៉ុន្តែក្រុមហ៊ុនទាំងនោះនៅតែជាផ្នែកមួយនៃប្រតិបត្តិការដ៏ធំសម្បើមរបស់ក្រុមហ៊ុនភាពីម៉ិចដែរ។

ត្រឹមឆ្នាំ២០០២ ក្រុមហ៊ុនបានចាប់ផ្តើមឈូសឆាយដីព្រៃនិងដីស្រែ សាងសង់ផ្លូវនិងប្រឡាយ ហើយនិងកន្លែងបណ្តុះកូនឈើនៅក្នុងឃុំអន្សាចំបក់ ស្រុកក្រគរ ខេត្តពោធិ៍សាត់។ នៅពេលធ្វើបាតុកម្ម ប្រជាជនក្នុងភូមិបានបិទផ្លូវនិងដាក់ពាក្យបណ្តឹងទៅគណៈរដ្ឋមន្ត្រីនៅភ្នំពេញ ដែលជារាជធានីរបស់ប្រទេស។ ទោះបីជារដ្ឋាភិបាលជាតិមិនបានឆ្លើយតបតាមអ្វីដែលអ្នកភូមិចង់បានក្តី ក៏ការធ្វើបាតុកម្មនៅមូលដ្ឋានបានផ្អាកនូវប្រតិបត្តិការនៅឃុំអន្សាចំបក់មួយរយៈពេលខ្លីដែរ។ ផ្ទុយមកវិញ ក្រុមហ៊ុន នៅតែបន្តទាមទារព័ទ្ធរបង និងឈូសឆាយដីនៅក្នុងតំបន់ផ្សេងៗទៀត។ ត្រឹមឆ្នាំ២០០៨ កន្លែងបណ្តុះកូនឈើនៅអន្សាចំបក់គឺមានប្រតិបត្តិការពេញទំហឹងតែម្តង ហើយភាភីម៉ិចបានចាប់ផ្តើមបណ្តេញប្រជាជនចេញពីដីរបស់ពួកគេនៅក្នុងតំបន់ផ្សេងៗទៀតដែលស្ថិតនៅក្នុងដីសម្បទាន ដោយហាមឃាត់រារាំងមិនឲ្យប្រជាជនមូលដ្ឋាន ចូលទៅក្នុងព្រៃ ហើយបានដាំដំឡូងមី និងអាកាស្យា ព្រមទាំងសង់នូវការដ្ឋានសម្រាប់ធ្វើការទៀតផង។

ចាប់តាំងពីពេលនោះមក ប្រតិបត្តិការរបស់ក្រុមហ៊ុនបានពង្រីកនិងបង្កើនល្បឿន ហើយគ្រឿងចក្រធុនធ្ងន់ដូចជាម៉ាស៊ីនឈូសឆាយ(អាប៊ុល) និងម៉ាស៊ីនកាយដីត្រូវបានដឹកជញ្ជូនយកទៅដាក់ពាសពេញតំបន់សម្បទានទាំងមូល។ ការពង្រីកនេះត្រូវបានអនុវត្តឡើងជាជំហានៗបន្តបន្ទាប់ ប៉ុន្តែសហគមន៍រងគ្រោះពុំបានទទួលដំណឹងជាមុននោះទេអំពីផែនការរបស់ក្រុមហ៊ុន ហើយជាញឹកញាប់សហគមន៍តាមទាន់ដោយមិនដឹងជាមុន។ ក្រុមហ៊ុនប្រើនូវមធ្យោបាយផ្សេងៗដើម្បីធានាឲ្យបាននូវ «កិច្ចសហប្រតិបត្តិការ» នៅមូលដ្ឋានរាប់តាំងពីការសូកប៉ាន់ និងការប្រើល្បិច រហូតដល់ការបង្ខិតបង្ខំ ការប្រើអំពើហិង្សា និងការចាប់ដាក់គុក។ នៅក្នុងឆ្នាំ២០១០ ក្រុមហ៊ុនភាពីម៉ិចបានរៀបចំកម្មវិធី «ចែកអំណោយ» មួយនៅក្នុងឃុំអន្លង់ចំបក់ ដែលប្រជាជននៅទីនោះទទួលបាន អង្ករ មីកញ្ចប់ និងក្រមា ដើម្បីជាភស្តុតាងពីបំណងល្អរបស់ក្រុមហ៊ុន។ មន្ត្រីរដ្ឋាភិបាលក្រោយមកបានលើកសរសើរអំពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមហ៊ុនភាពីម៉ិច ក្នុងការពាំនាំមកនូវភាពរុងរឿងសម្រាប់តំបន់នេះ និងបានណែនាំឲ្យសហគមន៍សហការជាមួយផងដែរ ពីព្រោះពួកគេក៏បានទទួលលាភសក្ការៈពីក្រុមហ៊ុនដែរ។

មន្ត្រីឃុំ និងមន្ត្រីស្រុកបានប្រាប់សហគមន៍រងគ្រោះថាក្រុមហ៊ុនភាភីម៉ិច គឺមិនអាចតស៊ូឬក៏បញ្ឈប់បានទេ ហើយថាប្រជាជនក្នុងភូមិគួរតែព្រមទទួលយកនូវសំណងអ្វីក៏ដោយដែល ក្រុមហ៊ុនអាចផ្តល់ឲ្យបាន។ ជាទូទៅក្រុមហ៊ុនភាភីម៉ិច តែងតែប្រើប្រាស់នូវក្រុមសន្តិសុខប្រដាប់អាវុធឯកជនផ្ទាល់របស់ខ្លួន ក៏ដូចជានគរបាលឃុំដែលប្រដាប់ដោយអាវុធ និងកងកំលាំងយោធាដើម្បី «ការពារ» ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននៅពេលដែលប្រឈមនឹងបាតុករមូលដ្ឋាន។ នគរបាលមូលដ្ឋានបានបញ្ជាក់ជាមួយសហគមន៍រងគ្រោះថា ការបញ្ជាមកពួកគេគឺដើម្បីការពារក្រុមហ៊ុន មិនមែនសហគមន៍នោះទេ។

**ការធ្វើឲ្យប្រជាជនក្លាយជាក្រីក្រ**

អ្នកភូមិម្នាក់មកពីផ្សាច់ឡាត់ ខេត្តពោធិ៍សាត់ ប្រទេសកម្ពុជាបាននិយាយថា៖ «មុនពេលដែលមានចម្ការដំណាំឧស្សាហកម្ម ត្រឹមតែដីស្រែនិងព្រៃ១០០ហិចតាប៉ុណ្ណោះ អាចឲ្យប្រជាជនរាប់រយគ្រួសាររស់នៅអាស្រ័យបានជានិរន្ត។ ប៉ុន្តែឥឡូវនេះ ដីរាប់ពាន់ហិចតាត្រូវបានផ្តល់ឲ្យទៅក្រុមហ៊ុនតែមួយគត់ ហើយ [ការរៀបចំបែបនេះ] គឺពុំបានចិញ្ចឹមសម្បីត្រឹមតែមួយគ្រួសារឲ្យបានពេញលេញនោះទេ។»

រឿងរ៉ាវដែលបានមកពីសហគមន៍រងគ្រោះបានបង្ហាញថាការសម្បទានទៅឲ្យភាភីម៉ិច គឺជាការប្លន់យកនូវកេរតំណែលនិងសម្បត្តិធម្មជាតិពីប្រជាជនកម្ពុជា ដែលធ្វើឲ្យសហគមន៍នៅក្នុងនិងនៅជុំវិញតំបន់ដីសម្បទាននោះទទួលរងភាពក្រីក្រ និងបាត់បង់នូវជម្រើសនៃជីវភាពរស់នៅសម្រាប់អនាគតអ្នកជំនាន់ក្រោយ។ តំបន់ដែលផ្តល់ឲ្យទៅក្រុមហ៊ុនភាភីម៉ិច រាប់បញ្ចូលទាំងដីស្រែ វាលស្មៅ ដីទំនាប ដីព្រៃ ឈើ បឹងបួ និងប្រភពធនធានទឹក ដែលទាំងអស់នេះបង្កើតបានចេញជាប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធធម្មជាតិមួយ ដែលប្រជាជននៅជនបទរស់នៅអាស្រ័យលើ ហើយវាក៏បានចិញ្ចឹមជីវិតប្រចាំថ្ងៃនិងសុខុមាលភាពរបស់ពួកគេផងដែរ។ នៅតាមតំបន់ខ្លះ ដំណាំឧស្សាហកម្មបានក្លាយទៅជារនាំងបិទរាំងប្រជាជនមិនឲ្យទៅព្រៃហើយនិងតំបន់វាលស្មៅបាន។

ដោយសារតែបាត់បង់អស់នូវតំបន់ឃ្វាលគោ ដូច្នេះគ្រួសារដែលរងគ្រោះចាប់ផ្តើមលក់គោនិងក្របីរបស់ពួកគាត់ ដែលតាមលក្ខណៈប្រពៃណីបុរាណ នេះគឺជាទ្រព្យសម្បត្តិដ៏សំខាន់នៅតាមជនបទនៃប្រទេសកម្ពុជា។

ការឈូសឆាយព្រៃសម្រាប់ធ្វើសម្បទានគឺជាការបំផ្លាញនូវជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីនៅមូលដ្ឋាន រួមបញ្ចូលទាំងព្រៃសំខាន់ៗដ៏មានតម្លៃ ប្រភពទឹក ត្រី និងសត្វព្រៃ។ ដើមឈើដែលមាន តម្លៃសម្រាប់សេដ្ឋកិច្ច (ដូចជាក្រញ៉ូង បេង នាងនួន ឈើក្រម ធ្នុង និងធ្នឹក) ត្រូវបានហិនហោចអស់ រីឯជម្រកសត្វព្រៃត្រូវបានបាត់បង់ ហើយនិងប្រភពធនធានទឹកដែលហូរកាត់មកកាន់តែរួមតូចទៅៗ។ ក្រុមហ៊ុនបានលុបបំពេញបឹង បិទខ្សែចរន្ត ទឹកហូរ និងបង្វែរទឹកឲ្យហូរចាក់ចូលទៅក្នុងកន្លែងបណ្តុះកូនឈើ និងចម្ការដំណាំឧស្សាហកម្មរបស់ពួកគេតាម ប្រឡាយទឹក។ ស្ទឹងមួយចំនួនបាន រីងស្ងួតព្រមៗគ្នាអស់ទៅហើយ។ អ្នកភូមិមានការព្រួយបារម្ភណាស់ថានេះ នឹងប៉ះពាល់ដល់ការនេសាទនៅមូលដ្ឋាន ជាពិសេសនៅក្នុងបឹងទន្លេសាប។ ចរន្តខ្សែទឹកនាំមកនូវអាហារូបត្ថម្ភ សម្រាប់ត្រីនៅក្នុងបឹង ហើយមានត្រីជាច្រើនដែលធ្វើដំណើរបញ្ច្រាសទឹកដើម្បីទៅពង។ ប្រសិនបើស្ទឹងនិងបឹង ត្រូវបានបិទនោះ សុខភាពនិងគុណភាពនៃការនេសាទនឹងធ្លាក់ចុះ។ រីឯការធ្វើស្រែក៏ក្លាយទៅជាពិបាកជាងមុន ដែរ៖ ប្រជាជនមិនអាចដាំបន្លែ និងដំណាំសម្រាប់ដាំលក់យកប្រាក់នៅក្នុងសួនដំណាំឡើយ ដោយសារតែ ក្រុមហ៊ុនគ្រប់គ្រងលើការអាចទទួលបានទឹកយកមកប្រើប្រាស់។ បើគ្មានព្រៃឈើគ្របពីលើទេ ទឹកភ្លៀងនឹងហូរ ទៅបាត់យ៉ាងឆាប់រហ័ស ភាពសើមចរីលនៃដីមិនត្រូវបានត្រួតពិនិត្យនោះទេ ហើយស្ទឹងពីរបីដែលនៅ សេសសល់នោះកាន់តែរាក់ទៅៗ។

ព្រៃនិងឈើគឺជា «ប្រភព» ស្បៀងនិងឱសថដ៏មានសារៈសំខាន់សម្រាប់សហគមន៍រងគ្រោះ និងជា ប្រភពប្រេង ឧបករណ៍សម្រាប់ផ្ទះ និងអនុផលព្រៃឈើ (NTFPs) ដូច ជាផ្សិត ឬស្សី និងផ្តៅ ទឹកឃ្មុំ វល្លិ៍ ជ័រទឹក ឫសឈើ ស្លឹករុក្ខជាតិព្រៃ និងផ្លែឈើជាដើម។ ព្រៃក៏ផ្តល់នូវគុណតម្លៃវប្បធម៌និងសាសនាដ៏មានសារៈសំខាន់ ផងដែរសម្រាប់សហគមន៍រងគ្រោះ៖ ក្រុមហ៊ុនបានឈូសឆាយព្រៃអារក្សស័ក្តិសិទ្ធិ ដែលជាកន្លែងទីសក្ការៈតាម បែបប្រពៃណីដើម្បីសុំសុខសន្តិភាព សុំឲ្យទទួលបានភោគផលផល្លានុផលល្អ មានសម្បត្តិហូរហៀរ និងមាន សុខភាពល្អ។ ដីព្រៃជាង ៦០០០ហិចតា ដែលបានកំណត់ថាជាដីព្រៃសហគមន៍នោះ ត្រូវបានបាត់បង់នៅក្នុង ឃុំអន្សាចំបក់ និងឃុំក្បាលត្រាច (ខេត្តពោធិ៍សាត់)។ ប្រជាជននៅក្បាលត្រាចបានធ្វើការវាយតម្លៃថាចំណូល ដែលបាត់បង់របស់គ្រួសារនីមួយៗ បើគិតត្រឹមតែពីផលិផតព្រៃនានាដែលមិនមែនជាឈើតែប៉ុណ្ណោះ គឺមាន ចំនួនលើសពីមួយលានរៀល (២៤៥ដុល្លារអាមេរិក) ទៅទៀតក្នុងមួយរដូវ។

ដោយសារតែទំហំគ្រួសាររីកសាយមានសមាជិកច្រើនជាងមុន ក្មេងជំនាន់ក្រោយត្រូវការដីសម្រាប់ធ្វើ ស្រែចម្ការ ដែលឥឡូវនេះគឺគ្មានដីទេសម្រាប់ពួកគេ។ គំនិតផ្តួចផ្តើមមួយក្នុងការផ្តល់នូវប័ណ្ណកម្មសិទ្ធិដីធ្លីនៅក្នុង និងនៅជុំវិញតំបន់ដីសម្បទានសេដ្ឋកិច្ច ដែលដាក់ឲ្យដំណើរការដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុង ឆ្នាំ២០១២ (ហៅថាសារាចរ ០១ ឬ Directive 01BB) ដែលកំណត់ដីចំនួនកាន់កាប់អតិបរមាចំនួន៥ហិចតា ចំពោះដីស្រែនិងដំណាំសម្រាប់បុគ្គលពេញវ័យម្នាក់ៗ ទោះបីជាជាក់ស្តែងទំហំដីពិតប្រាកដគឺមានទំហំតិចជាង នេះច្រើន ភាគច្រើនគឺនៅក្នុងភូមិដែលរងគ្រោះដោយដីសម្បទានភាគីម៉ិច។ ប៉ុន្តែទោះបីជាមានការកំណត់ឲ្យ

ដី៥ហិចតាក្តី ក៏ការកំណត់នេះពុំបានពិចារណាអំពីអនាគតកាលនោះទេ ចំពោះតម្រូវការដីសម្រាប់អ្នកដែលមិនទាន់ក្លាយជាបុគ្គលពេញវ័យនៅឡើយនាពេលបច្ចុប្បន្ន ប៉ុន្តែពួកគេនឹងក្លាយជាបុគ្គលពេញវ័យនៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំខាង មុខទៀត។

ដោយអស់សង្ឃឹម និងគ្មានជម្រើស ប្រជាជនជាច្រើនបានស្វែងរកការងារធ្វើនៅតាមចម្ការដំណាំឧស្សាហកម្ម ដែលជាកន្លែងដែលពួកគេប្រឈមនឹងការរកបានប្រាក់ឈ្នួលទាបគឺចំនួន ៦០០.០០០ រៀល ឬ ១៤៧ដុល្លារអាមេរិកសម្រាប់រយៈពេល៣០ថ្ងៃ ហើយទទួលបានប្រាក់ឈ្នួលមិនទៀងទាត់ទេ ព្រមទាំងមានលក្ខខណ្ឌការងារមិនល្អ។ បច្ចុប្បន្ននេះ មានគ្រួសារជាច្រើនរស់នៅអាស្រ័យលើប្រាក់ឈ្នួលរបស់សមាជិកគ្រួសារម្នាក់ដែលបានមកពីធ្វើការនៅក្នុងចម្ការដំណាំឧស្សាហកម្ម ដែលនេះមិនអាចឲ្យគ្រួសារទាំងមូលរស់នៅបានដោយនិរន្តរភាពនោះទេ ផ្ទុយពីមុននោះគឺពួកគេរស់នៅអាស្រ័យលើស្បៀងនិងប្រាក់ចំណូលបានមកពីស្រែ សួនបន្លែ ព្រៃ និងស្ទឹង។ ជាលទ្ធផលបំណុលកាន់តែកើន ការធ្វើចំណាកស្រុកកាន់តែច្រើន ហើយគ្រួសារក៏បែកខ្ញែកគ្នាអស់ដោយសារតែសមាជិកគ្រួសារទៅទីក្រុង ឬក៏ប្រទេសជិតខាងដូចជាប្រទេសថៃជាដើម ដើម្បីរកការងារធ្វើ។

**បន្តរក្សានូវការតស៊ូ**

តាំងពីបានរៀនអំពីសម្បទានដីមក ប្រជាជននៅក្នុងសហគមន៍រងគ្រោះបានព្យាយាមការពារ ដី ព្រៃឈើ ជីវភាពរស់នៅ និងជីវិតរបស់ពួកគេតាមមធ្យោបាយមួយចំនួន។ ពួកគេបានធ្វើបាតុកម្មនៅការិយាល័យឃុំ ស្រុក និងខេត្ត ហើយបានបិទផ្លូវជាតិលេខ៥ដើម្បីកសាងឲ្យមានការគាំទ្រពីមហាជន បានបញ្ឈប់ម៉ាស៊ីនមិនឲ្យដំណើរការឈូសឆាយដីស្រែនិងព្រៃបាន និងបានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរនៅគ្រប់កម្រិតទាំងអស់។ ពួកគេបានប្រារព្ធនូវពិធីបន់ស្រន់នៅក្នុងភូមិនិងវត្តរបស់ពួកគេ និងនៅមុខការិយាល័យរបស់រដ្ឋាភិបាល ដើម្បីសុំយុត្តិធម៌។ ពួកគេបានធ្វើពិធីបំបួសដើមឈើនៅក្នុងព្រៃស័ក្តិសិទ្ធិរបស់ពួកគេ ហើយនៅក្នុងមួយកន្លែងដែលពួកគេប្រារព្ធពិធីនោះគឺមានដើមឈើចំនួន១០០០ដើមត្រូវបានបំបួស ប៉ុន្តែក្រុមហ៊ុននៅតែបន្តកាត់ដើមឈើទាំងនោះ។

ការកៀរគរនិងរៀបចំប្រជាជននៅក្នុងស្រុកចំនួន៨ដែលស្ថិតនៅក្នុងតំបន់សម្បទាននោះ គឺជាឧបសគ្គដ៏ចម្បងសម្រាប់ប្រជាជន ដែលត្រូវផ្គត់ផ្គង់ចិញ្ចឹមគ្រួសាររបស់ពួកគេផងនិងត្រូវសម្រេចឲ្យបាននូវគោលដៅរបស់គេផង។ ការសម្បទានដីមានលក្ខណៈធំធេងណាស់ មិនមែនតែលើទំហំត្រឹមប៉ុណ្ណោះទេ ប៉ុន្តែវាក៏ទៅលើអំណាចលុយ និងអំណាចនយោបាយផងដែរ។ ចំពោះអ្នកដែលចូលរួមធ្វើបាតុកម្ម ត្រូវបានគេលាបពណ៌ថាជា «អ្នកញុះញង់» ហើយត្រូវបានចាប់ខ្លួនដោយការចោទប្រកាន់ទាំងខុស ត្រូវបានចាប់ដាក់គុកនិងពិន័យជាទឹកប្រាក់ក្នុងចំនួនមួយយ៉ាងច្រើន។ ខណៈដែលមនុស្សជាច្រើនមានការនឿយហត់អស់កម្លាំងនិងបាក់ទឹកចិត្ត មានអ្នកមួយចំនួនផ្សេងទៀត ក៏បានមើលឃើញនូវក្តីសង្ឃឹមដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរនៅក្នុងរយៈពេលយូរអង្វែងខាងមុខទៀត។ ការបោះឆ្នោតជាតិ ដែលបានបញ្ចប់ទៅក្នុងពេលថ្មីៗនេះ បានបង្ហាញថាជាទូទៅមានការធ្លាក់

ចុះចំពោះការគាំទ្រដល់គណបក្សប្រជាជនកម្ពុជា ហើយវាហាក់ដូចជាការគាំទ្រចុះខ្សោយយ៉ាងខ្លាំងចំពោះគណបក្សប្រជាជនកម្ពុជានោះគឺនៅក្នុងតំបន់ដែលមានទំនាស់ដីនិងព្រៃ។

ប្រជាពលរដ្ឋម្នាក់នៅក្រាំងស្បៀ (ខេត្តកំពង់ឆ្នាំង) បាននិយាយថា៖ «ពួកយើង គឺដូចជាឫស្សីអ៊ីចឹង ដែលវាចាប់ផ្តើមឡើងពីមួយដើម។ យើងត្រូវតែនៅចាំបន្តទៀតរហូតដល់មានឫស្សី ផ្សេងៗច្រើនថែមទៀតមកផ្តុំគ្នាឲ្យបានកាន់តែធំកាន់តែមាំ។»

***ហ្សាលម៉ាលី ហ្គុត្តាល់ (Shalmali Guttal )***
*នាយិការបស់ហ្វ័រឃើស អន ដឺ គ្លូលប៊ិលសោធហ៍ (Focus on the Global South)*

*(១)* មហាសេដ្ឋីកំពូលទាំង១០រូបរបស់កម្ពុជា។ http://investvine.com/cambodias-top-10-tycoons/
(២) ក្រុមហ៊ុនរុករករ៉ែរំលោភលើដីដូនតាត (Miner Encroaches on Ancestral Lands)។
http://www.rfa.org/english/news/cambodia/bauxite-06222011171620.html
(៣) ចំណងភាភីម៉ិច «ហេតុដែលបណ្តាលឲ្យមានកង្វល់» (Pheapimex ties 'cause for concern)។
http://www.phnompenhpost.com/national/pheapimex-ties-cause-concern and
https://sahrika.com/2016/12/20/villagers-wary-of-mkiri-mine-project/#more-27000

# ម៉ាឡេស៊ី៖ ក្រុមជនជាតិដើមភាគតិចមកពីជុំវិញពិភពលោក បានអនុម័តសេចក្តីប្រកាសពីការប្រឆាំងនឹងទំនប់

*នៅក្នុងខែធ្នូ ឆ្នាំ២០១៥ ជនជាតិដើមភាគតិចនៅរដ្ឋសារ៉ាវ៉ាក់ (Sarawak) នៃប្រទេសម៉ាឡេស៊ីបានប្រារព្ធនូវជ័យជំនះដ៏ធំមួយ៖ រដ្ឋាភិបាលប្រចាំរដ្ឋបានប្រកាសនូវមោឃភាពលើគម្រោងទំនប់បារ៉ាំ (៤) ហើយនៅឆ្នាំ២០១៦ បានលុបចោលគម្រោងទំនប់ដ៏ចម្រូងចម្រាសនោះ។ ការតស៊ូប្រឆាំងនឹងគម្រោងទំនប់នេះ គឺជាការជំរុញទឹកចិត្តដល់មនុស្សជាច្រើន ហើយត្រូវបានលើកឡើងជាពិសេសនៅក្នុងបទបង្ហាញអំពី «មានអ្វីខ្លះដែលកំពុងកើតមានឡើងចំពោះព្រៃឈើរបស់យើងនៅម៉ាឡេស៊ី?» កាលពីខែវិច្ឆិកា ឆ្នាំ២០១៦ នៅក្នុងការជួបជុំមួយនៅទីក្រុងបាងកកដែលរឿងនេះមាននៅក្នុងផ្នែកវិចារណកថានៃព្រឹត្តិប័ត្រនេះ។ ហេតុដូចនេះហើយ ទើបយើងធ្វើការបោះពុម្ពផ្សាយអត្ថបទនេះឡើងវិញ នៅក្នុងកិច្ចប្រជុំអន្តរជាតិរបស់សកម្មជនប្រឆាំងនឹងទំនប់ ដែលពួកគេបានមកជួបជុំគ្នានៅមាត់ទន្លេបារ៉ាំកាលពីខែតុលា ឆ្នាំ២០១៥ ពោលគឺទើបតែប៉ុន្មានខែប៉ុណ្ណោះ មុនពេលដែលរដ្ឋាភិបាលប្រចាំរដ្ឋប្រកាសនូវមោឃភាពលើការសាងសង់ទំនប់បារ៉ាំនេះ។*

*អត្ថបទត្រូវបានបោះពុម្ពផ្សាយលើកដំបូងគេនៅក្នុងព្រឹត្តិបត្ររបស់ចលនាព្រៃស្រោងពិភពលោក (WRM) ២២០ កាលពីខែធ្នូ ឆ្នាំ២០១៥*

ជនជាតិដើមភាគតិចមកពីជុំវិញពិភពលោកដែលជាអ្នកប្រយុទ្ធប្រឆាំងនឹងទំនប់ បានមកជួបជុំគ្នាកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៥ នៅតាមមាត់ទន្លេបារ៉ាំនៅរដ្ឋសារ៉ាវ៉ាក់ ដែលជារដ្ឋមួយរបស់ប្រទេសម៉ាឡេស៊ី ដែលស្ថិតនៅលើកោះប័រនេអូ ដើម្បីចូលរួមជាសាមគ្គីភាពមួយជាមួយនឹងប្រជាជនក្នុងការប្រយុទ្ធប្រឆាំងនឹងសំណើសុំគម្រោងទំនប់បារ៉ាំ។ នៅថ្ងៃនោះមានការបិទផ្លូវពីរកន្លែងដើម្បីប្រារព្ធខួបពីរឆ្នាំនៃការប្រយុទ្ធប្រឆាំងនឹងទំនប់បារ៉ាំ។ ទំនប់បារ៉ាំគ្របដណ្តប់ពីលើព្រៃជាង៤០០គីឡូម៉ែត្រក្រឡា ហើយអាចនឹងធ្វើឲ្យជនជាតិដើមភាគតិចរហូតដល់ទៅ ២ម៉ឺននាក់ បាត់បង់ទីជម្រក ខណៈដែលថាមពលអគ្គិសនីដែលបានមកពីទំនប់នេះមិនមែនជាតម្រូវការនោះទេ៖ សារ៉ាវ៉ាក់មានភ្លើងប្រើប្រាស់ច្រើនលើសតម្រូវការហើយ។ ដោយអរគុណចំពោះការរារាំងទាំងនោះ ការសាងសង់ទំនប់បារ៉ាំក៏ដូចជាផ្លូវដែលភ្ជាប់ទៅទំនប់ ត្រូវបានបញ្ឈប់ទាំងស្រុងអស់រយៈពេលពីរឆ្នាំមកហើយ។

គណៈប្រតិភូជនជាតិដើមភាគតិចមកពីឥណ្ឌូនេស៊ី ហ្វីលីពីន កម្ពុជា ប្រេស៊ីល សហរដ្ឋអាមេរិក ហុនឌូរ៉ាស់ និងពីទូទាំងប្រទេសម៉ាឡេស៊ី បានមកជួបជុំគ្នានៅសារ៉ាវ៉ាក់ដើម្បីចែករំលែកនូវបទពិសោធន៍របស់ពួកគេ ពង្រឹងនូវចំណងទំនាក់ទំនងរវាងសហគមន៍របស់ពួកគេ និងបង្កើតនូវសេចក្តីថ្លែងការណ៍រួមមួយស្តីអំពីទំនប់។ ព្រឹត្តិការណ៍ដែលមានរយៈពេលមួយសប្តាហ៍ត្រូវបានហៅថា កិច្ចប្រជុំកំពូលរបស់ជនជាតិដើមភាគតិចពិភពលោកស្តីពីបរិស្ថាននិងទន្លេ (វ៉ាយហ្សើរ WISER) ហើយត្រូវបានបណ្តាញប្រជាជនមូលដ្ឋានដើម្បីសង្គ្រោះទន្លេ របស់ សារ៉ាវ៉ាក់ ធ្វើជាម្ចាស់ផ្ទះ (១)។

**បារ៉ាំសម្រាប់ទាំងអស់គ្នា! ទាំងអស់គ្នាសម្រាប់បារ៉ាំ! (Baram for all, all for Baram)**

អ្នកចូលរួមក្នុង វ៉ាយហ្សើរ (WISER) បានទៅទស្សនកិច្ចនៅតាមកន្លែងសំខាន់ៗនានា ដែលមានការក្រោកឈរប្រឆាំងនឹងទំនប់បារ៉ាំ ដូចជានៅទីតាំងបិទផ្លូវទាំងពីរកន្លែង និងទីតាំងសម្រាប់សង់ទំនប់ដែលបានស្នើសុំ។ ភីធើរ ខាលឡាង (Peter Kallang) ប្រធានបណ្តាញសង្គ្រោះទន្លេ (SAVE Rivers) និងជាម្ចាស់ផ្ទះរបស់វ៉ាយហ្សើរ (WISER) បានពន្យល់ថា៖ «យើងមកពីបណ្តាញសង្គ្រោះទន្លេ ចង់ឲ្យអ្នកចូលរួមទទួលបាននូវបទពិសោធន៍អំពីវប្បធម៌របស់ពួកយើង និងឃើញនូវសម្រស់របស់ទន្លេបារ៉ាំដោយខ្លួនពួកគេផ្ទាល់ ដូច្នេះពួកគេនឹងយល់បានប្រសើរជាងមុនអំពីអ្វីដែលជាបញ្ហានិងហានិភ័យ ហើយហេតុអ្វីបានជាយើងតស៊ូដើម្បីវា។»

នៅទីតាំងសាងសង់ទំនប់ដែលបានស្នើឡើង ដែលអាចទៅដល់ទៅនោះបានតាមទូក ភីតធើរ ខាលឡាង បានរៀបរាប់រឿងថាៈ «ក្នុងឆ្នាំ២០១២ ក្រុមហ៊ុនថាមពលរបស់រដ្ឋសារ៉ាវ៉ាក់ និងក្រុមហ៊ុនសាងសង់ទំនប់ដែលមានឈ្មោះថាសារ៉ាវ៉ាក់អ៊ែនណឺជី បានរៀបចំនូវពិធីបន់ស្រន់តាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិចនៅទីតាំងស្នើសម្រាប់សាងសង់ទំនប់ ដើម្បីសុំពរជ័យសេចក្តីសុខសប្បាយក្នុងការសាងសង់ទំនប់។ ភ្លាមៗនោះ សហគមន៍មូលដ្ឋានបានបញ្ចេញប្រតិកម្មដោយធ្វើការតវ៉ានៅលើទូកនៅទីតាំងសាងសង់ដើម្បីប្រឆាំងនឹងការរំលោភលើការបន់ស្រន់តាមបែបប្រពៃណីរបស់ពួកគេ។ នោះគឺជាពេលដ៏សំខាន់មួយក្នុងការកៀរគរការប្រឆាំងនឹងគម្រោងទំនប់។»

រឿងរ៉ាវអំពីការការពារទន្លេបារ៉ាំគឺជានិមិត្តរូបមួយនៃការក្រោកឈរឡើងដើម្បីជោគវាសនារបស់ក្រុមជនជាតិដើមភាគតិចជាច្រើនក្រុមដែលរងការគំរាមកំហែងពីទំនប់។ បើរតា កាសេរ៉េស (Berta Cáceres) ជាជ័យលាភីពានរង្វាន់បុគ្គលផ្នែមផ្នែកបរិស្ថានឆ្នាំ២០១៥ (២) មកពីប្រទេសហុងឌូរ៉ាស់ មានភាពរំជួលចិត្តដោយសារបញ្ហាស្រដៀងគ្នា នៅចន្លោះនៃការគំរាមកំហែងដែលសហគមន៍កំពុងប្រឈម និងបានលើកឡើងនូវសារៈសំខាន់ របស់វ៉ាយស៊ើរ (WISER)៖ «កិច្ចប្រជុំកំពូលស្តីពីជនជាតិដើមភាគ តិចនិងទន្លេនេះគឺមានគុណតម្លៃពិសេសមួយ ដែលថាសកម្មភាពរបស់វាបានផ្តល់នូវកម្លាំងថាមពល ដល់ការក្រោកឈតតាំងជាប្រវត្តិសាស្ត្ររបស់ប្រជាជន ហើយនិងធ្វើឲ្យមើលឃើញនូវការឈ្លានពាន និងជម្លោះដែលកើតចេញពីការធ្វើឯកជនភាវូបនីយកម្មទន្លេ និងការសាងសង់ទំនប់នៅក្នុងសហគមន៍ជនជាតិដើមភាគតិច និងនៅក្នុងតំបន់។»

**សេចក្តីប្រកាសនៃកិច្ចប្រជុំកំពូលរបស់ជនជាតិដើមភាគតិចពិភពលោកស្តីពីបរិស្ថាននិងទន្លេឆ្នាំ ២០១៥ ( The WISER Baram 2015 declaration )**

សិក្ខាសាលាត្រូវបានធ្វើឡើងនៅក្នុងភូមិមួយនៅតាន់ជុងតេប៉ាលីត (Tanjung Tepalit) ដែលជាភូមិមួយក្នុងចំណោមភូមិចំនួន២៦ ដែលទទួលរងគ្រោះពីការជន់លិចដោយសារតែទំនប់បារ៉ាំ។ អ្នកចូលរួមបានពិភាក្សាអំពីការជំរុញលើកទឹកចិត្តរបស់ពួកគេដែលនាំឲ្យមានការប្រឆាំងនឹងគម្រោងទំនប់ ពីឧបសគ្គរបស់យុទ្ធនាការក៏ដូចជារបស់យុទ្ធសាស្ត្រដែលធ្វើឲ្យទទួលបានជោគជ័យក្នុងការកៀរគរមនុស្ស និងកត្តាដែលធ្វើឲ្យការតស៊ូរបស់ពួកគេកាន់តែមានសន្ទុះជាងមុន។

ជេមីស៍ ញ៉ូរ៉ាំង (James Nyurang) អតីតមេដឹកនាំរបស់តាន់ជុងតេប៉ាលីត (Tanjung Tepalit) និងជាម្ចាស់ផ្ទះក្នុងការទទួលគណៈប្រតិភូអន្តរជាតិផងដែរនោះ មានទំនុកចិត្តថាប្រជាជនបារ៉ាំបង្កើនកម្លាំងថាមពលរបស់ពួកគេតាមរយៈកិច្ចប្រជុំកំពូលនេះ ហើយបន្តការតស៊ូរបស់ពួកគេទៅមុខទៀត៖ «ពេលមកជុំគ្នាជាមួយនឹងគណៈប្រតិភូទាំងអស់ដើម្បីចែករំលែកនិងពិភាក្សាអំពីយុទ្ធសាស្ត្រនានា ដើម្បីជំនះឧបសគ្គក្នុងការបញ្ឈប់ទំនប់ដែលមិនចាំបាច់ទាំងអស់នៅក្នុងពិភពលោក ខ្ញុំទទួលបានបទពិសោធន៍ជាច្រើនពីគណៈប្រតិភូទាំងអស់។ ហើយជាមួយនឹងព័ត៌មានទាំងនេះ ខ្ញុំមានការជឿជាក់គ្រប់គ្រាន់ថាបទពិសោធន៍ទាំងនេះ នឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ពួកយើងដែលជាប្រជាជនបារ៉ាំ និងយុទ្ធសាស្ត្ររបស់ពួកយើងក្នុងការបន្តប្រយុទ្ធនិងបញ្ឈប់នូវគម្រោងទំនប់បារ៉ាំ។»

កិច្ចពិភាក្សាបានបញ្ចប់ដោយការអនុម័តនូវ «សេចក្តីប្រកាសនៃវ៉ាយហ្សើរបារ៉ាំ ស្តីពីទំនប់និងសិទ្ធិរបស់ជនជាតិដើមភាគតិច។ (៣) សេចក្តីប្រកាសនេះបានទទួលស្គាល់នូវភាពឈឺចាប់ និងការបំផ្លិចបំផ្លាញកាន់តែខ្លាំងដោយសារទំនប់។ រដ្ឋាភិបាល ក្រុមហ៊ុន និងវិនិយោគិនត្រូវបានស្នើសុំមិនឲ្យបន្តគម្រោងនានា ព្រោះពុំមានការព្រមព្រៀងគ្នា ការជូនដំណឹងជាមុន និងមានលក្ខណៈសេរី ពីសហគមន៍ដែលរងគ្រោះនោះទេ និងត្រូវបានស្នើឲ្យផ្តល់សច្ចាប័ន និងជំរុញអនុវត្តនូវសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ក៏ដូចជាអនុសញ្ញា១៦៩ របស់អង្គការពលកម្មអន្តរជាតិ និងអនុវត្តនូវជម្រើសនៃថាមពលដែលអាច

កើតឡើងវិញលក្ខណៈខ្នាតតូចនៅក្នុងបរិបទជនបទ។ សេចក្ដីប្រកាសនេះក៏បានទាមទារឲ្យផ្ដល់សំណង សម្រាប់សហគមន៍ដែលរងគ្រោះពីទំនប់ ក៏ដូចជាធ្វើការសិក្សាអំពីការរុះរើទំនប់ចេញដែរ។

អ្នកចូលរួមបានសង្កត់ធ្ងន់ថា ទំនប់មិនគួរត្រូវបានបង្ហាញជាកត្តាធ្វើឲ្យមានលំនឹងអាកាសធាតុទៀត នោះទេ ។ បើរតា កាសេរ៉េស (Berta Cáceres) ដែលជាអ្នកប្រឆាំងនឹង ទំនប់អាហ្គូហ្សារកា (Agua Zarca Dam) នៅហុងឌូរ៉ាស (Honduras) បាននិយាយនៅសន្និសីទកាសែតចុងក្រោយរបស់វ៉ាយហ្សឺរ (WISER) នៅក្រុងមីរី (Miri) ថា៖ «យើងសូមធ្វើការអំពាវនាវយ៉ាងទទូចមួយទៅកិច្ចប្រជុំកំពូលស្ដីពីការប្រែប្រួល អាកាសធាតុ លើកក្រោយដែលនឹងធ្វើនៅទីក្រុងប៉ារីសឲ្យទទួលស្ដាប់និងគោរពជនជាតិដើមភាគតិច ព្រមទាំង ជម្រើសផ្សេងៗទៀតដែលសហគមន៍យើងលើកឡើង ឆ្លើយតបនឹងបញ្ហាបំរែបំរួលអាកាសធាតុ»។

## ការតស៊ូនិងក្ដីសង្ឃឹម

អ្នកចូលរួមបានចែករំលែកនូវភាពឈឺចាប់ដែលបណ្ដាលមកពីការបាត់បង់នូវវប្បធម៌ និងកេរតំណែលក៏ ដូចជាបរិស្ថានធម្មជាតិ ដែលជាផ្នែកមួយរបស់ពួកគេនិងសហគមន៍របស់ពួកគេ ទន្ទឹមនឹងការមិនបានដាក់ ពួកគេចូលទៅក្នុងដំណើរការសម្រេចចិត្ត បែរជាដាក់បទឧក្រិដ្ឋកម្ម និងយោធានីយកម្ម មកលើពួកគេទៅវិញ។

ប៉ុន្តែក៏មានរឿងរ៉ាវជោគជ័យជាច្រើនផងដែរ៖ ដៀម គុណឌី និង យឺន ឌីនិត មកពីប្រទេសកម្ពុជាបាន ប្រាប់ពីរបៀបដែលពួកគេសម្រេចបាននូវការផ្អាកដំណើរការគម្រោងទំនប់អារ៉ែងកាលពីដើមឆ្នាំនេះ បន្ទាប់ពីមាន យុទ្ធនាការយ៉ាងខ្លាំងក្លាដោយមានការបិទផ្លូវ យុទ្ធនាការជិះកង់ និងផ្សេងៗទៀត។ ស៊ែមមី និងចន លូក៏ ជេនសរ៍ ជាកុលសម្ព័ន្ធយូរុក (Yurok tribe) នៅកាលីហ្វ័រញ៉ានៃសហរដ្ឋអាមេរិកបានពន្យល់ថា ខណៈដែល ទំនប់ទាំងបួននៅទន្លេក្លាម៉ាតហ៍ (Klamath River) នៅតែបន្តមានរូបរាងនៅទីនោះ និងបន្តគំរាមកំហែងដល់ ជីវិតត្រីសាលម៉ុន (salmon) ដែលជាមូលដ្ឋានសម្រាប់ ទ្រទ្រង់ជីវភាពរស់នៅរបស់កុលសម្ព័ន្ធយូរុក (Yurok tribe) រដ្ឋាភិបាលរបស់សហរដ្ឋអាមេរិកបានចាប់ផ្ដើមបញ្ឈប់ការប្រើប្រាស់ទំនប់នៅកន្លែងដទៃទៀត។ ក្រោយ មកប្រព័ន្ធអេកូឡូស៊ីក៏បានត្រឡប់មកដូចដើមវិញយ៉ាងលឿនគួរឲ្យភ្ញាក់ផ្អើល។

ប្រជាជននៅបារ៉ាំក៏មានសង្ឃឹមកាន់តែខ្លាំងដែរថា ការសាងសង់ទំនប់នឹងត្រូវបញ្ឈប់។ ជាដំបូង ការប្រឆាំងតវ៉ាបានកើនឡើងគួរឲ្យកត់សម្គាល់ ហើយការបិទផ្លូវគឺជាវិធីសាស្ត្រដែលមានប្រសិទ្ធិភាព ក្នុងការ បញ្ឈប់គម្រោង។ នៅខែមិថុនា ភីតធើរ ខាលឡាង និងដានីញ៉េល ខាមមិន ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ កាលីហ្វ័រញ៉ានៅប៊ើកក្លេយ (the University of California, Berkeley) បានជួបជាមួយនឹងប្រធានរដ្ឋមន្ត្រី អាដេណាន សាតេម (Chief Minister Adenan Satem) ប្រចាំរដ្ឋសារ៉ាវ៉ាក់ ដើម្បីពិភាក្សាអំពីជម្រើស ផ្សេងទៀតនៃប្រភពថាមពលក្រៅពីទំនប់។ នៅក្នុងខែវិច្ឆិកា ប្រធានរដ្ឋមន្ត្រី អាដេណា សាតេម នៃរដ្ឋសារ៉ាវ៉ាក់ បានប្រកាសផ្អាកដំណើរការទំនប់បារ៉ាំ។

ប៉ុន្តែ រឿងរបស់ដានីញ៉េល ដា ស៊ីលវ៉ា (Daniela Da Silva) អំពីទំនប់ប៊ែលឡូម៉ុងធ៍ (Belo Monte Dam) នៅព្រៃអាម៉ាហ្សូននៃប្រទេសប្រេស៊ីលវិញ បានរំឭកយើងថាភាពជោគជ័យទាំងនោះគឺមានភាពផុយ

ស្រួយណាស់។ នាងបាននិយាយអំពីរបៀបដែលទំនប់ខារ៉ាវ៉ៅ (Kararao Dam) ដែលជាទំនប់មួយកើតមុនទំនប់ប៉ែលឡូម៉ុង៍ (Belo Monte Dam) ត្រូវបានលុបចោលដោយការរីករាលដាលនៃការធ្វើបាតុកម្មនៅក្នុងចុងទសវត្សឆ្នាំ៨០ ប៉ុន្តែក្រោយមកទៀតវាត្រូវបានដាក់ឈ្មោះថ្មី និងធ្វើឡើងវិញដោយរដ្ឋាភិបាល។ សូម្បីតែសាលក្រមសម្រេចរបស់តុលាការមួយចំនួនដែលប្រឆាំងនឹងគម្រោង ក៏មិនអាចបញ្ឈប់វាបានដែរ។ គួរឲ្យសោកស្តាយ គម្រោងទំនប់ដែលគិតថាត្រូវបានបញ្ឈប់ហើយ ជារឿយៗត្រូវបានដំណើរការសាងសង់ឡើងវិញដោយរដ្ឋាភិបាលដែលនឹកស្មានមិនដល់។

***អាននណា អ៊ែប៊ឺលី (Anna Aeberli)***
មូលនិធិប្រ៊ូណូម៉ានហ្សែរ (Bruno Manser Fund) www.bmf.ch/en

(១) សង្គ្រោះទន្លេ (SAVE Rivers) ត្រូវបានបង្កើតឡើងកាលពីបួនឆ្នាំមុន ជាបណ្តាញសហគមន៍ ដើម្បីប្រឆាំងនឹងបណ្តុំនៃគម្រោងទំនប់ យ៉ាងហោចណាស់ចំនួន១២គម្រោងដែលបានស្នើឡើងដោយរដ្ឋាភិបាលរដ្ឋសារ៉ាវ៉ាក់។ ទំនប់បារ៉ាំក៏បានក្លាយទៅជាគម្រោងដ៏ចម្រូងចម្រាសបំផុតមួយនៅក្នុងចំណោមគម្រោងទាំងនោះ។

(២) ពានរង្វាន់បុគ្គលឆ្នើមផ្នែកបរិស្ថាន (The Goldman Environmental Prize) គឺសម្រាប់ផ្តល់ជាកិត្តិយសដល់អ្នកបរិស្ថាននៅមូលដ្ឋាន និងជាការទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការការពារបរិស្ថានធម្មជាតិ ហើយដែលតែងតែប្រឈមនឹងហានិភ័យខ្ពស់សម្រាប់ខ្លួនពួកគេផ្ទាល់។ ប៊ើរតា កាសេរ៉េស (Berta Cáceres) ត្រូវបានសម្លាប់ក្នុងផ្ទះរបស់នាងផ្ទាល់ បន្ទាប់ពីចំនួនតែប៉ុន្មានខែប៉ុណ្ណោះ ក្រោយពីនាងបានថ្លែងសុន្ទរកថានៅក្នុងពិធីជួបជុំមួយនៅមាត់ទន្លេបារ៉ាំអំពីការតស៊ូរបស់ជនជាតិលែនកា (Lenca peoples) ប្រឆាំងនឹងគម្រោងទំនប់អាគ្វ៉ា ហ្សារកា (Agua Zarca Dam) នៅហុងឌូរ៉ាស (Honduras)។

(៣) អាចសេចក្តីប្រកាស៖ http://www.stop-corruption-dams.org/resources/WISER_Baram_2015_Declaration_Signed.pdf

(៤) អព្ភូតហេតុបារ៉ាំ (The Baram miracle)៖ ផែនការទំនប់ត្រូវបានលុបចោលជាផ្លូវការ។ សារព័ត៌មានរបស់មូលនិធិប្រ៊ូណូម៉ានហ្សែរ (Bruno Manser Fund News)។ http://bmf.ch/en/news/the-baram-miracle-dam-plans-officially-scrapped

# សកម្មភាពរបស់ប្រជាជន

**ហុងឌូរ៉ាស (Honduras)៖ ប្រទេសដែលមានអត្រាស្លាប់ច្រើនជាងគេនៅក្នុងពិភពលោកសម្រាប់ភាពសកម្មផ្នែកបរិស្ថាន។** របាយការណ៍ដែលបោះពុម្ពផ្សាយដោយកម្មវិធីគ្លូប៊លវីតណេស (Global Witness) កាលពីខែមករា ឆ្នាំ២០១៧ បានបង្ហាញថាចាប់តាំងពីឆ្នាំ២០០៩មក មានប្រជាជនច្រើនជាង១២០នាក់ត្រូវបានសម្លាប់នៅក្នុងប្រទេសហុងឌូរ៉ាស (Honduras) ដោយសារការក្រោកឈរតតាំងជាមួយនឹងក្រុមហ៊ុនដែលដណ្តើមយកដី និងកាប់បំផ្លាញព្រៃឈើ។ របាយការណ៍នេះ ជាការឧទ្ទិសរំឭកដល់អ្នកការពារសិទ្ធិមនុស្ស ប៊ើរតា កាសេរ៉េស (Berta Cáceres) ដែលត្រូវបានគេធ្វើឃាតនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ នៅពេលដែលទាហាន

ប្រដាប់អាវុធបានសម្រុកចូលក្នុងផ្ទះនាងនៅពាក់កណ្ដាលអធ្រាត្រហើយសម្លាប់នាង។ បើរតា កាសេរ៉េស (Berta Cáceres) បានកៀរគរគ្នាប្រឆាំងនឹងគម្រោងទំនប់វារីអគ្គិសនីអាហ្គ័រ ហ្សារកា (Agua Zarca hydro dam) នៅលើដីរបស់សហគមន៍នាងដែលស្ថិតនៅក្នុងអ៊ីនទីប៊ូកា (Intibucá) នៃភូមិភាគបស្ចឹមនៃប្រទេសហុងឌូរ៉ាស ដែលទំនប់នេះគំរាមកំហែងដល់ប្រភពទឹកស័ក្ដិសិទ្ធិ និងមានសារៈសំខាន់សម្រាប់ជនជាតិភាគតិចទ្បេនកា ។ របាយការណ៍នេះអាចរកបាននៅ៖
https://www.globalwitness.org/en/campaigns/environmental-activists/honduras-deadliest-country-world-environmental-activism/

**ហ្វ្រេនហ្គុយ៉ាណា (French Guyana)៖ រដ្ឋាភិបាលបារាំងកំពុងតែលើកកម្ពស់ឧស្សាហកម្មរុករករ៉ែមាសដោយស្ងាត់ៗនៅក្នុងតំបន់ហ្វ្រេនហ្គុយ៉ាណា (French Guyana)។** ប្រសិនបើគម្រោងនេះត្រូវសម្រេចឲ្យអនុវត្តនោះ គម្រោងម៉ុងតាញឌ័រ ដែលគ្រោងនឹងចាប់ផ្ដើមរុករករ៉ែនៅក្នុងឆ្នាំ២០១៨ នឹងក្លាយទៅជាការរុករករ៉ែមាសដ៏ធំបំផុតនៅលើដីរបស់បារាំង។ វានឹងមិនត្រឹមតែមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់មនុស្សនិងបរិស្ថានប៉ុណ្ណោះទេ វាថែមទាំងបើកទ្វារសម្រាប់ក្រុមហ៊ុនពហុជាតិដទៃទៀត រុករករ៉ែនៅក្នុងតំបន់ហ្វ្រេនហ្គុយ៉ាណា និងពង្រីកការរុករករ៉ែជាពិសេសសម្រាប់តែទីផ្សារគ្រឿងអលង្ការប្រណីត។ តម្រូវការរបស់ឧស្សាហកម្មមាសនេះមានត្រឹមតែ ៨ភាគរយនៃមាសដែលកំពុងរុករកនាពេលបច្ចុប្បន្ន។ វិស័យកែច្នៃឡើងវិញ បានផ្គត់ផ្គង់បានបីដងតាមតម្រូវការនោះនៅក្នុងឆ្នាំ២០១៥។ សម្រាប់ព័ត៌មានបន្ថែមស្ដីពីការតស៊ូប្រឆាំងនឹងការរុករករ៉ែនៅក្នុងតំបន់ហ្វ្រេនហ្គុយ៉ាណា (French Guyana) (ជាភាសាបារាំង) អាចរកបាននៅ៖

https://sites.google.com/site/maiourinature/or-de-question-cp22fev

ដើម្បីគាំទ្រដល់សហករណ៍ *អ័រ ដឺ កេសស្យុង (Or de question)* ដែលជាសម្ព័ន្ធមួយ របស់បណ្ដាអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាននិងថ្នាក់ជាតិ ដែលកំពុងតែអំពាវនាវឲ្យរដ្ឋាភិបាលបារាំងលុបចោលនូវគម្រោងរុករករ៉ែធំៗទាំងនោះជាបន្ទាន់។ សូមចុះហត្ថលេខានៅលើញត្តិនៅ៖
https://www.rainforest-rescue.org/petitions/1084/no-to-industrial-gold-mining-in-the-forests-of-french-guiana#letter

**ឥណ្ឌា៖ ការស៊ើបអង្កេតរបស់ប៊ីប៊ីស៊ី (BBC) បានបង្ហាញពីចំនួនអ្នកស្លាប់ដោយគោលនយោបាយបាញ់សម្លាប់ នៅក្នុងតំបន់បម្រុងសត្វខ្លា ។** នៅជុំវិញពិភពលោក ជនជាតិដើមភាគតិច ប្រឈមនឹងការចាប់ខ្លួន ការបៀតបៀនទារុណកម្ម និងការសម្លាប់ ក្រោមនាមនៃការអភិរក្សធម្មជាតិ។ ឧទ្យានជាតិ កាហ្ស៊ីរ៉ាន់ហ្កា (Kaziranga National Park) នៅប្រទេសឥណ្ឌា គឺជាឧទាហរណ៍ដ៏អាក្រក់មួយពីទំនោរនៃភាពឃោរឃៅមិនមែនជាមនុស្សនេះ។ ក្នុងអំឡុងពេលបីឆ្នាំចុងក្រោយនេះ មានមនុស្ស៥០នាក់ ត្រូវបានកាត់ទោសនៅក្រៅប្រព័ន្ធតុលាការដោយឧទ្យានុរក្ស នៅក្នុងឧទ្យានជាតិដែលល្បីខាង «បាញ់សម្លាប់»។ ក្រុមកុលសម្ព័ន្ធ ប្រឈមនឹងការបាញ់ប្រហារ ការវាយដំ ទារុណកម្ម និងការសម្លាប់នៅក្នុង ដៃមន្ត្រីគ្រប់គ្រងឧទ្យានដែលមានដោយប្រដាប់អាវុធយ៉ាងច្រើន។ កាលពីឆ្នាំមុន អ្នកយាមបានបាញ់កុមារម្នាក់អាយុ៧ឆ្នាំ ដែលសព្វថ្ងៃនេះកុមារានោះត្រូវពិការអស់មួយជីវិត។ អំពើហិង្សានេះ ត្រូវបានប្រព្រឹត្តឡើងក្រោមឈ្មោះដើម្បីការអភិរក្ស។ អង្គការធំៗដែលធ្វើការខាងផ្នែកអភិរក្ស រួមមានអង្គការមូលនិធិសត្វព្រៃពិភពលោក (WWF) អង្គការសង្គមអភិរក្សសត្វព្រៃ (Wildlife Conservation Society) អង្គការរក្សានិងអភិរក្សធម្មជាតិអន្តរជាតិ (Nature Conservancy and

Conservation International) ដែលនៅក្នុងចំណោមអង្គការផ្សេងៗទៀតនោះ មិនអើពើនឹងការទាមទារពីសហគមន៍ ឲ្យថ្កោលទោសចំពោះការប្រព្រឹត្តបែបនោះទេ។

**ខ្សែភាពយន្ត ល្បែងសត្វខ្លា (*The Tiger Game*) បានបង្ហាញថាការបាញ់ប្រហារនៅក្នុងឧទ្យានជាតិកាហ្សីរ៉ាន់ហ្គា (Kaziranga National Park) មិនមែនជាឧប្បត្តិហេតុដាច់ដោយឡែកនោះទេ។** រដ្ឋាភិបាលរបស់ឥណ្ឌាបានប្រកាសនូវផែនការពង្រីកការអនុវត្តគោលនយោបាយនេះនៅក្នុងតំបន់អភិរក្សសត្វខ្លានៅពាសពេញប្រទេសឥណ្ឌា។ ខ្សែភាពយន្តដែលមានចំណងជើងថា *ល្បែងសត្វខ្លា (The Tiger Game)* ដែលផលិតដោយសកម្មជនឥណ្ឌា និងផលិតករភាពយន្ត ស៊ូមីត្រា ហ្គូស្ហ (Soumitra Ghosh) បានបង្ហាញថាស្ថានភាពនៅក្នុងឧទ្យានជាតិកាហ្សីរ៉ាន់ហ្គា (Kaziranga National Park) មិនមែនជាឧប្បត្តិហេតុដាច់ដោយឡែកនោះទេ ហើយថែមទាំងថាគោលនយោបាយនេះបានអនុវត្តជាក់ស្តែងរួចទៅហើយនៅក្នុងតំបន់អភិរក្សសត្វខ្លាប៊ុហ្សា (Buxa Tiger Reserve) ដែលស្ថិតនៅភាគខាងលិចប៉ែនហ្គាល (West Bengal)។ ភាពយន្តនេះ បានរុករកតំនាលរឿងនៃការកេងប្រវ័ញ្ចជាច្រើនផ្សេងៗគ្នាប៉ុន្តែមានដូចគ្នា អំពីភាពសាហាវឃោរឃៅ និងភាពអយុត្តិធម៌ ការសម្លាប់យ៉ាងព្រៃផ្សៃយង់ឃ្នងទៅលើកុលសម្ព័ន្ធ ដោយបុគ្គលិកផ្នែកសេវាកម្មព្រៃឈើក្រោមនាមដើម្បីអភិរក្សសត្វព្រៃ។

ភាពយន្ត (ជាភាសាអង់គ្លេស) អាចរកបាននៅ៖ https://vimeo.com/124188855

ចូលរួមជាមួយនឹងស្ថាប័នសកម្មភាពឃ្លាំងមើលជនរងគ្រោះអន្តរជាតិ បានអំពាវនាវឲ្យអាជ្ញាធររដ្ឋាភិបាលនៅក្នុងប្រទេសឥណ្ឌាបញ្ឈប់នូវគោលនយោបាយបាញ់សម្លាប់នៅនឹងកន្លែងនៅក្នុងការពារតំបន់ទាំងនោះ៖ http://www.survivalinternational.org/emails/shoot-on-sight

សម្រាប់ព័ត៌មានបន្ថែម (ជាភាសាអង់គ្លេស)៖ http://www.conservation-watch.org/2017/03/10/indias-kaziranga-national-park-and-the-streisand-effect/

**ម៉ាឡេស៊ី៖ អង្គការស្បៀងនិងកសិកម្ម (FAO) ត្រូវបានប្រាប់ឲ្យឈប់ទទួលស្គាល់ថាដំណាំឧស្សាហកម្មគឺជាព្រៃឈើ។** នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ អង្គការមិនមែនរដ្ឋាភិបាលរបស់ម៉ាឡេស៊ីសមាគមអ្នកប្រើប្រាស់នៅប៉េណាង (Consumers' Association of Penang (CAP)) និងសាហាបាតអាឡាំម៉ាឡេស៊ី (Sahabat Alam Malaysia (SAM)) បានចូលរួមសកម្មភាពនៅទូទាំងពិភពលោកដើម្បីប្រឆាំងនឹងនិយមន័យព្រៃឈើរបស់អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ (UN Food and Agriculture Organisation's (FAO))។ ប្រហែលជា ២០០ក្រុម បន្តការអំពាវនាវនេះទៅ FAO ឲ្យកែតម្រូវនិយមន័យនៃព្រៃឈើដែលមានលក្ខណៈភ័ន្តច្រលំរបស់ពួកគេ ដែលនិយមន័យនេះអនុញ្ញាតឲ្យមានការពង្រីកបន្ថែមទៀតនូវការដាំដុះដំណាំឧស្សាហកម្ម។ លិខិតនេះបានអំពាវនាវឲ្យ FAO បញ្ឈប់ការទទួលស្គាល់នូវដំណាំឧស្សាហកម្មថាជាព្រៃឈើដូចដែលបានកំណត់នៅក្នុងនិយមន័យ ពីព្រោះនេះបានអនុញ្ញាតឲ្យឧស្សាហកម្មផ្នែកចម្ការដំណាំលាក់បាំងពីផលប៉ះពាល់ ដែលបំផ្លាញលើប្រព័ន្ធអេកូឡូស៊ី និងសង្គមដោយសារចម្ការដំណាំឯកវប្បកម្មទ្រង់ទ្រាយធំ ដែលស្ថិតនៅក្រោយរូបភាពរីជួមានមួយដែលវាបានជួយដល់ព្រៃឈើ សម្រាប់ការយល់ឃើញជាសាធារណៈ ។ http://www.freemalaysiatoday.com/category/nation/2017/03/21/stop-recognising-plantations-as-forests-un-body-told/

លិខិតដែលបានផ្ញើទៅ FAO នៅក្នុងថ្ងៃនេះអាចរកបាននៅទីនេះ។ វាក៏អាចរកបានជាភាសា អេស្ប៉ាញ បារាំង និងព័រទុយហ្កាល់ផងដែរ។ ចំពោះព័ត៌មានបន្ថែមអំពីការទាមទារយ៉ាងរឹងមាំឲ្យ FAO កែប្រែនិយមន័យដែលធ្វើឲ្យមានការភ័ន្តច្រលំរបស់គេនោះ សូមមើល៖ http://wrm.org.uy/all-campaigns/international-day-of-the-forests-march-21st-2017/

**ឥណ្ឌូនេស៊ី៖ បាតុកម្មនៅចាវ៉ា (Java) ប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើតាមរយៈការពង្រីកឧស្សាហកម្មស៊ីម៉ង់ត៍។** នៅឥណ្ឌូនេស៊ី មានការកើនឡើងនូវការក្រោកឈរប្រឆាំងតទល់នឹងផលិតកម្មស៊ីម៉ង់ត៍របស់ក្រុមហ៊ុនឥណ្ឌូនេស៊ីឈ្មោះថា ស៊ីមែនឥណ្ឌូនេស៊ី (Semen Indonesia) ដែលនឹងត្រូវបំផ្លាញតំបន់ព្រៃខេនឌេងខាស្ត (Kendeng karst) នៃតំបន់ភ្នំចាវ៉ា។ ផាតមី (Patmi) គឺជាស្ត្រីម្នាក់មកពីភូមិមួយនៅក្នុងស្រុករបស់តាំបាក់គ្រូម៉ូ (Tambakromo) ដែលបានធ្វើដំណើរទៅទីក្រុងចាការតា (Jakarta) ដើម្បីចូលរួមធ្វើបាតុកម្មប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើដើម្បីផលិតកម្មស៊ីម៉ង់ត៍។ នាងបានស្លាប់នៅថ្ងៃទី២១ ខែមីនា ប្រហែលដោយសារគាំងបេះដូង បន្ទាប់ពីចូលរួមធ្វើបាតុកម្មដោយអង្គុយអស់ច្រើនថ្ងៃនៅមុខវិមានប្រធានាធិបតីនៅចាការតា (Jakarta)។ មានសកម្មជនកើន ឡើងកាន់តែច្រើនឡើងៗនៅចាការតា (Jakarta) និងនៅទីក្រុងធំៗដទៃទៀតនៅក្នុងប្រទេសបានដាក់ ជើងរបស់ពួកគេទៅក្នុងស៊ីម៉ង់ត៍ ហើយរៀបចំឲ្យមានការអង្គុយស្រដៀងគ្នាផងដែរ ដើម្បីបង្ហាញពីសាមគ្គីភាពរួបរួមគ្នាជាមួយនឹងផាតមី (Patmi) និងប្រជាជនខេនឌេង (Kendeng)។ ក្រុមបាតុករកំពុង តែស្នើសុំឲ្យមានសាមគ្គីភាពពីសហគមន៍អន្តរជាតិក្នុងការគាំទ្រដល់ការតស៊ូនេះ ជាពិសេសនៅពេលដែលប្រធានាធិបតីបានចេញមុខកាលពីដើមខែមេសាឆ្នាំ២០១៧ ថាការផលិតកម្មស៊ីម៉ង់ត៍អាចនឹងបន្តទៅមុខបាន។ គម្រោងនេះកើតមានឡើងនៅក្នុងបរិបទមួយដែលមានការដណ្តើមយកដីនិងទឹកជាលក្ខណៈទ្រង់ទ្រាយធំមិនធ្លាប់មានពីមុនមក ដើម្បីបំពេញតម្រូវការប្រើប្រាស់ថាមពលនិងសម្ភារៈនៅក្នុងតំបន់តាមរយៈការបង្កើតនូវ «ច្រករបៀង» សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដោយជ្រៀតចូលកាន់តែជ្រៅទៅលើព្រៃដែលនៅសេសសល់ក្នុងតំបន់។ សម្រាប់ព័ត៌មានបន្ថែម សូមមើលអត្ថបទខ្លីដែលមានភ្ជាប់មកជាមួយ និងព័ត៌មានមរណភាពជាភាសាអង់គ្លេស ដែលជាការឧទ្ទិសដល់ផាតមី (Patmi)សរសេរដោយហេនដ្រូ សាងកូយ៉ូ (Hendro Sangkoyo)៖ http://wrm.org.uy/other-relevant-information/the-poetic-and-haunting-death-of-patmi-of-mt-kendeng-java-indonesia/

# អនុសាសន៍

**របាយការណ៍ប្រជុំ៖ តើមានអ្វីខ្លះកំពុងតែកើតឡើងចំពោះព្រៃឈើរបស់យើង?** កាលពីថ្ងៃទី២១ ដល់ ២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ មានប្រជាជនប្រហែលជា៥០នាក់ដែលបានចូលរួមតស៊ូដើម្បីការពារ ដែនដី ព្រៃឈើ និងជីវភាពរស់នៅរបស់សហគមន៍ដែលអាស្រ័យផលព្រៃឈើ បានមកជួបជុំគ្នានៅក្នុងប្រទេសថៃដើម្បីធ្វើទស្សនកិច្ចមួយនៅមូលដ្ឋានក្នុងភូមិភាគឥសាននៃប្រទេស ហើយបន្តការប្រជុំចំនួនបីថ្ងៃទៀតនៅបាងកក។ ក្រៅពីគណៈប្រតិភូពីប្រទេសថៃ មានអ្នកចូលរួមផ្សេងៗទៀត ដែលមកពីប្រទេសមីយ៉ាន់ម៉ា កម្ពុជា វៀតណាម ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងឥណ្ឌា។ គោលបំណងរបស់កិច្ចប្រជុំដែលផ្តោតជាចម្បងលើសំណួរគោល

«តើមានអ្វីខ្លះកំពុងតែកើតមានឡើងចំពោះព្រៃឈើរបស់យើង?» បានបញ្ចូលទាំងការលើកកម្ពស់ឲ្យមានកិច្ចសន្ទនា និងផ្លាស់ប្តូរយោបល់លើការគំរាមកំហែងនិងឧបសគ្គទាំងចាស់និងថ្មី ដែលសហគមន៍នៅក្នុងប្រទេសផ្សេងៗកំពុងប្រឈម។ ទោះបីជាមានភាពចម្រុះនៃភាសានិងវប្បធម៌របស់អ្នកចូលរួមក៏ដោយ ពួកគេបានដឹងថាពួកគេមានគុណតម្លៃនិងក្តីកង្វល់រួមគ្នាជាច្រើន ឧទាហរណ៍៖ សារៈសំខាន់របស់ព្រៃឈើសម្រាប់ជីវភាពរស់នៅរបស់ពួកគេ ក៏ដូចជាការគំរាមកំហែងនិងឧបសគ្គដែលពួកគេជួបប្រទះនៅពេលធ្វើការការពារដែនដីនិងព្រៃឈើរបស់ពួកគេពីការដណ្តើមដីធ្លី និងការកាប់បំផ្លាញព្រៃឈើ។ របាយការណ៍និងតំណភ្ជាប់ទៅកាន់បទបង្ហាញរបស់កិច្ចប្រជុំនេះអាចរកបាននៅគេហទំព័រ៖
http://focusweb.org/content/what-happening-our-forests-conference-report-and-presentations (មានតែជាភាសាអង់គ្លេសប៉ុណ្ណោះ)។

**វីដេអូរបស់សង្គ្រោះទន្លេរបស់យើងដែលមានចំណងជើងថា សង្គ្រោះជីវិតពួកយើងពីការ គំរាមកំហែងនៃការរុករករ៉ែមាសទៅទន្លេតានីនថារីនៅប្រទេសមីយ៉ាន់ម៉ា។** អ្នកភូមិម្នាក់មកពីតំបន់អាងទឹកទន្លេតានីនថារីបាននិយាយនៅក្នុងការណែនាំអំពីវីដេអូនេះថា៖ «ទឹកគឺជាជីវិត។ ប្រសិនបើយើង មិនការពារទន្លេតានីនថារីទេ ជីវិតនិងជីវភាពរស់នៅរបស់ប្រជាជនក្នុងភូមិដែលរស់ពឹងផ្អែកលើទន្លេនេះនឹងត្រូវបានបំផ្លាញ»។ គាត់បានពន្យល់ថា «ពួកយើងត្រូវតែទប់ស្កាត់ការបំផ្លាញទន្លេនេះ ដើម្បីប្រយោជន៍អ្នកជំនាន់ក្រោយ។ ពួកយើងមកជួបជុំគ្នានៅទីនេះដើម្បីបង្ហាញនូវការមិនយល់ស្របនឹងការរុករករ៉ែមាសនៅទន្លេតានីនថារី»។ វីដេអូនេះបានចងក្រងជាឯកសារអំពីការបន់ស្រន់អធិដ្ឋានរួមគ្នាមួយរបស់ពុទ្ធបរិស័ទ និងគ្រីស្តបរិស័ទដែលរៀបចំដោយអ្នកស្រុកមកពីតំបន់អាងទឹកទន្លេតានីនថារី ដើម្បីបង្ហាញពីការប្រឆាំងរបស់គេទៅនឹងប្រតិបត្តិការថ្មីៗក្នុងការរុករករ៉ែមាសដោយម៉ាស៊ីនដែលបានចាប់ផ្តើមឡើង ដោយក្រុមហ៊ុន ស្វីធុនភោគ (Shwe Tun Pauk) នៅក្នុងទន្លេតានីនថារីនៃប្រទេសមីយ៉ាន់ម៉ា។ មានអ្នកភូមិជាង២០០នាក់តំណាងឲ្យភូមិចំនួន៦០ ដែលរស់នៅតាមដងទន្លេនេះ បានធ្វើដំណើរតាមទូកចម្ងាយរហូតដល់១៦០គីឡូម៉ែត្រ ដើម្បីមកចូលរួមក្នុងពិធីបន់ស្រន់អធិដ្ឋាននេះ។ ក្រុមនេះក៏បានត្រួតពិនិត្យលើប្រតិបត្តិការរុករករ៉ែនេះដែរ ហើយបានសួររកឯកសារក្រដាសស្នាមដែលបញ្ជាក់ថាក្រុមហ៊ុនស្វីធុនភោគ (Shwe Tun Pauk) ពិតជាទទួលបានការអនុញ្ញាតស្របច្បាប់ដើម្បីរុករករ៉ែនៅក្នុងទន្លេតានីនថារីមែន។ អ្នកភូមិពុំបានទទួលនូវចម្លើយដ៏ពេញចិត្តពីកម្មករនៅក្នុងទីតាំងប្រតិបត្តិការនោះទេ ហើយបានទាមទារឲ្យមានការប្រជុំជាសាធារណៈមួយជាមួយនឹងថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនស្វីធុនភោគ។ កិច្ចប្រជុំសាធារណៈ ជាមួយនឹងថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនស្វីធុនភោគ ត្រូវបានធ្វើ ឡើងថ្ងៃទី៨ ខែមករា ឆ្នាំ២០១៦។ វីដេអូឯកសារពីកិច្ចប្រជុំនេះអាចរកបាននៅ៖
https://www.youtube.com/watch?v=mPolcAAXtqo
https://www.youtube.com/watch?v=3sQ6lFITN9c

ភាពយន្តឯកសារស្តីពីសង្គ្រោះទន្លេយើង សង្គ្រោះជីវិតយើង ជាភាសាអង់គ្លេស អាចរកបាននៅ៖
https://www.youtube.com/watch?v=pxDA_P73ZDM និងជាភាសាភូមានៅ៖
https://www.youtube.com/watch?v=YR2mD__jTU4

**របាយការណ៍៖ មូលហេតុ និងរបៀបរបបនៃការធ្វើកសិកម្មបែបអេកូឡូស៊ី?! សិក្ខាសាលាបណ្តុះបណ្តាលនៅក្នុងសាលាកសិកម្មបែបអេកូឡូស៊ី អេចភីអេ (HEPA Eco-Farming School) នៃប្រ**

**ទេសវៀតណាម។** របាយការណ៍នេះពិពណ៌នាអំពីរបៀបដែលប្រព័ន្ធកសិកម្មបានចាក់ឫសចាក់គល់ទៅ ក្នុងវប្បធម៌ ច្បាប់ទម្លាប់ប្រពៃណី និងបទពិសោធន៍ទៅតាមកន្លែងនានាក្នុងធ្វើកសិកម្មរបស់កសិករ ដែលបានប្រមូលចងក្រងទុកពីច្រើនជំនាន់ ហើយដែលខុសពីកសិកម្មបែបកសិឧស្សាហកម្មដែលបាន បង្ហាញនៅក្នុងអត្ថបទមួយចំនួនរបស់ព្រឹត្តិបត្រនេះ ក្នុងរូបភាពជាការដណ្តើមដីធ្លី និងការគំរាមកំហែងមួយដល់ព្រៃឈើ និងប្រជាជនដែលរស់នៅអាស្រ័យព្រៃឈើនៅក្នុងតំបន់ទន្លេមេគង្គ (និងលើសពីតំបន់នេះទៀត)។ របាយការណ៍នេះ (ជាភាសាអង់គ្លេស) អាចរកបាននៅ៖
http://cendiglobal.org/upload/medias/why-and-how-ecological-farming.pdf

**របាយការណ៍៖ ការកើនឡើងនូវមហន្តរាយ : ក្រុមហ៊ុនលំដាប់កំពូល ៥០០ វិនិយោគលើកសិកម្ម។**

ក្រុមហ៊ុនសាជីវកម្មកសិពាណិជ្ជកម្មដែលធំជាងគេលើពិភពលោក កំពុងតែអនុវត្តកម្មវិធីភាពជាដៃគូរវាងរដ្ឋ និងឯកជន ដើម្បីក្តោបក្តាប់គ្រប់គ្រងលើស្បៀងអាហារ និងកសិកម្មនៅក្នុងពិភពលោកភាគខាងត្បូង។ កម្មវិធីនេះត្រូវបានហៅថា *ហ្គ្រោយ៍ (Grow)* ហើយវាជាផ្នែកមួយនៃ «កសិកម្មក្នុងចក្ខុវិស័យថ្មី»ជាគំនិតផ្តួចផ្តើមមួយរបស់វេទិកាសេដ្ឋកិច្ចពិភពលោក (WEF) ដែលបានដាក់ឲ្យដំណើរការនៅ ក្នុងឆ្នាំ២០០៩ ហើយត្រូវបានដឹកនាំដោយក្រុមហ៊ុនដៃគូរបស់វេទិកាសេដ្ឋកិច្ចពិភពលោកចំនួន៣១ ក្រុមហ៊ុនដែលចូលរួមពាក់ព័ន្ធនឹងជំនួញស្បៀងអាហារ។ ៩០ ភាគរយនៃក្រុមហ៊ុនទាំងនោះមានមូលដ្ឋាននៅសហរដ្ឋអាមេរិកនិងអឺរ៉ុប ហើយគ្មានក្រុមហ៊ុនណាមួយមកពីប្រទេសចិន ប្រេស៊ីល ជប៉ុន កូរ៉េ ថៃ ឬក៏អាហ្វ្រិចខាងត្បូងឡើយ។ ប៉ុន្តែ «កសិកម្មក្នុងចក្ខុវិស័យថ្មី» និងកម្មវិធី *ហ្គ្រោយ៍ (Grow)* របស់ខ្លួន គឺផ្តោតទាំងស្រុងទៅលើអាមេរិកឡាទីន អាហ្វ្រិច និងអាស៊ី ដែលជាទីផ្សារមានការលូតលាស់យ៉ាងសំខាន់ក្នុងឧស្សាហកម្មស្បៀងអាហារពិភពលោក។ ការផ្តោតចំបងនៃគំនិតផ្តួចផ្តើមស្តីពី «កសិកម្មក្នុងចក្ខុវិស័យថ្មី» គឺទៅលើកសិកម្មតាមកិច្ចសន្យា ដែលផ្សារភ្ជាប់កសិករខ្នាតតូចទៅនឹងក្រុមហ៊ុនពហុជាតិ (និងមិនសូវផ្តោតលើ ឧទាហរណ៍ដូចជា ចម្ការដំណាំឧស្សាហកម្មរបស់ក្រុមហ៊ុនសាជីវកម្មនោះទេ)។ របាយការណ៍ជាភាសាអង់គ្លេសដែលចេញផ្សាយដោយហ្គ្រេន (GRAIN) អាចរកបាននៅ៖
https://www.grain.org/article/entries/5622-grow-ing-disaster-the-fortune-500-goes-farming .
វានឹងមានជាភាសាបារាំងនិងអេស្ប៉ាញក្នុងពេលឆាប់ៗនេះ។

**កិច្ចសម្ភាស៖ «គ្មានទេនិរន្តរភាពប្រេងដូងដែលចេញពីឧស្សាហកម្មផលិតកម្មដូងប្រេង»។** នៅក្នុងកិច្ចសន្ទនារវាងស្វីសអ៊ីនហ្វូ (SwissInfo) និងខាធីនី សាមុន (Kartini Samon) មកពីហ្គ្រេន (GRAIN) ពីផលប៉ះពាល់របស់ឧស្សាហកម្មផលិតកម្មដូងប្រេងទៅលើសហគមន៍ និងលើតួនាទីរបស់ធនាគារស្វីសចំពោះការផ្តល់ហិរញ្ញប្បទានលើការដណ្តើមដីធ្លី ដោយផ្តល់ជំនួយលើការពង្រីកដំណាំដូងប្រេងនៅក្នុងប្រទេសឥណ្ឌូនេស៊ី។ កិច្ចសម្ភាសនេះ (ជាភាសាបារាំង) អាចរកបាននៅ៖
http://www.swissinfo.ch/fre/accaparement-des-terres_-il-n-existe-pas-de-production-d-huile-de-palme-industrielle-durable-/43009936

**របាយការណ៍៖ កិច្ចព្រមព្រៀងប្រគល់អធិបតីភាព៖ របៀបដែលកិច្ចព្រមព្រៀងស្តីពីវិនិយោគទុនគំរាមកំហែងដល់បទបញ្ញត្តិលើឧស្សាហកម្មរ៉ែនៅក្នុងប្រទេសហ្វីលីពីន។**

នៅក្នុងទសវត្សចុងក្រោយនេះ ប្រទេសហ្វីលីពីនបានផ្សងសំណាងយ៉ាងខ្លាំងទៅលើឧស្សាហកម្មរ៉ែ ដោយមានគម្រោងរុករករ៉ែខ្នាតធំចំនួន៤៧គម្រោងកំពុងតែប្រតិបត្តិការ និង ភស្តុតាងច្រើនឡើងៗ ពីការប៉ះពាល់លើបរិស្ថាន និងសង្គម ។ សេចក្តីសង្ខេប បានលើកឡើងថាលទ្ធភាពរបស់ប្រទេសក្នុងការអនុវត្តបទបញ្ញត្តិ ឬ បិទចោលនូវការរុករករ៉ែណាដែលបំពុលដល់បរិស្ថាន នឹងត្រូវរងសម្ពាធយ៉ាងធ្ងន់ធ្ងរពីបណ្តាញមួយនៃអនុសញ្ញាវិនិយោគមួយចំនួន ដែលប្រទេសហ្វីលីពីនបានចុះហត្ថលេខាព្រមព្រៀងនោះ ដែលផ្តល់នូវការការពារដ៏លើសលប់ដល់វិនិយោគិនបរទេស។ របាំងផ្លូវច្បាប់ទាំងនេះ នឹងកាន់តែរឹងមាំឡើង ប្រសិនបើរដ្ឋាភិបាលនៅបន្តដំណើរទៅមុនជាមួយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងប្រទេសហ្វីលីពីន និងសហគមន៍អឺរ៉ុប និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចថ្នាក់តំបន់ទូលំទូលាយ ។ របាយការណ៍នេះ (ជាភាសាអង់គ្លេស) អាចរកបា នៅ៖
http://focusweb.org/content/signing-away-sovereignty-how-investment-agreements-threaten-regulation-mining-industry

---

ចុះឈ្មោះទទួលព័ត៌មានជាមួយនឹងព្រឹត្តិបត្ររបស់ចលនាព្រៃស្រោងពិភពលោក
http://wrm.us9.list-manage1.com/subscribe?u=f91b651f7fecdf835b57dc11d&id=ca171adcc2

***ព្រឹត្តិបត្រនេះមានគោលបំណងគាំទ្រនិងរួមចំណែកដល់ការតស៊ូរបស់ជនជាតិដើមភាគតិច និងសហគមន៍ប្រពៃណីដើម្បីព្រៃឈើនិងទឹកដីរបស់ពួកគេ។ ចំពោះការចុះឈ្មោះទទួលព័ត៌មានគឺមិនគិតថ្លៃ។***

**ព្រឹត្តិបត្រប្រចាំខែរបស់ចលនាព្រៃស្រោងពិភពលោក**

ព្រឹត្តិបត្តនេះក៏មានជាភាសាបារាំង អេស្ប៉ាញ និងព័រទុយហ្គាល់
នាយកនិពន្ធ៖ វីនហ្វ្រីឌុស អូវើប៊ីក (Winfridus Overbeek)
ប្រធានផ្នែកនិពន្ធ៖ ចូអានណា ខាប៉ែលឡូ (Joanna Cabello)
ជំនួយការផ្នែកនិពន្ធ៖ អេលីហ្សាប៉ែត ឌាស (Elizabeth Díaz) ជូត្តា ឃាល (Jutta Kill) ផ្លាវីយ៉ូ ប៉ាហ្សូស (Flavio Pazos) ធេរីសា ប៉ារ៉េស៍ (Teresa Perez)

**អគ្គលេខាធិការដ្ឋានរបស់ចលនាព្រៃស្រោងពិភពលោកអន្តរជាតិ**
Avenida General María Paz 1615 office 3. CP 11400. Montevideo, Uruguay
ទូរស័ព្ទ/ទូរសារ៖ +៥៩៨ ២៦០៥៦៩៤៣
wrm@wrm.org.uy - http://www.wrm.org.uy